ខុមហ្វ្រែល COMFREL

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា

COMMITTEE FOR FREE AND FAIR ELECTIONS IN CAMBODIA

# របាយការណ៍
# ការឃ្លាំមើលយេនឌ័រផ្នែកនយោបាយ

## សភា និងតំណាងរាស្ត្រស្ត្រី និងការផ្តល់អំណាចឱ្យស្ត្រី ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការ នៅថ្នាក់មូលដ្ឋាន



ផ្នែកអប់រំ និងយេនឌ័រ

ខែកុម្ភៈ ឆ្នាំ២០២០

# របាយការណ៍

# ការឃ្លាំមើលយេនឌ័រផ្នែកនយោបាយៈ
# សភា និងតំណាងរាស្ត្រស្ត្រី និងការផ្តល់អំណាចឱ្យស្ត្រី
# ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន



## សមភាពយេនឌ័រ

# មាតិកា


**បុព្វកថា** ..................... i

**I.សេចក្តីផ្តើម** ..................... 1

**II.ការឃ្លាំមើលសភា និងតំណាងរាស្ត្រស្ត្រី** ..................... 7

**១. ដំណើរការសម័យប្រជុំសភា** ..................... 7

១.១. ការបញ្ចេញមតិយោបល់ជាបរិមាណរបស់សមាជិកសភាស្ត្រីនៅក្នុងពេលប្រជុំពេញអង្គរដ្ឋសភា ..................... 11

- តារាងទី១៖ ចំនួន និងភាគរយតំណាងរាស្ត្រស្ត្រី ឡើងបញ្ចេញមតិធៀបនឹងតំណាងរាស្ត្របុរស ..................... 11

១.២. គុណភាពមតិពិភាក្សារបស់អ្នកតំណាងរាស្ត្រស្ត្រី ..................... 12

- តារាងទី២៖ ការបង្ហាញពីអ្នកតំណាងរាស្ត្រស្ត្រីឡើងបញ្ចេញមតិ ..................... 12

១.៣. មតិយោបល់របស់តំណាងរាស្ត្រស្ត្រី និងបុរសដែលបានលើកឡើងទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ ..................... 13

**២. សកម្មភាពរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះមូលដ្ឋាន** ..................... 13

- តារាងទី៣៖ ចំនួន និងគោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រទាំងស្ត្រី និងបុរស ..................... 13

២.១. ការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី ..................... 15

- តារាងទី៤៖ ចំនួន និងគោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រស្ត្រី ..................... 15
- តារាងទី៥៖ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មធៀបនឹងអ្នកតំណាងរាស្ត្របុរស ..................... 16
- តារាងទី៦៖ ចំនួនចុះបេសកកម្មនៃអ្នកតំណាងរាស្ត្រស្ត្រីម្នាក់ៗ ..................... 16

**៣. ការបំពេញការសន្យារបស់រដ្ឋាភិបាលទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ** ..................... 18

- តារាងទី៧៖ កម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា នីតិកាលទី៦ (២០១៨-២០២៣) ..................... 18
- កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦នៃរដ្ឋសភា ..................... 19

**III.ស្ថានភាពអ្នកនយោបាយស្ត្រីកម្ពុជា** ..................... 21

**IV.ការសិក្សាលើក្រុមគោលដៅស្តីពីការផ្តល់អំណាចឱ្យស្ត្រីក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងការបំពេញកិច្ចការនៅក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែល** ..................... 24

**១. ព័ត៌មានទូទៅទាក់ទងនឹងការចូលរួមនយោបាយរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់** ..................... 24

១.១. ព័ត៌មានទូទៅរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ..................... 24

- ក្រាហ្វិកទី១៖ ..................... 25

១.២. ចំនួនអាណត្តិរបស់ស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់ ..................... 25

- ក្រាហ្វិកទី២៖ ..................... 26

១.៣. តួនាទីរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ..... 26
ក្រាហ្វិកទី៣៖ ..... 26
១.៤. មូលហេតុនៃការចូលប្រឡូកក្នុងកិច្ចការនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ ..... 27
ក្រាហ្វិកទី៤៖ ..... 27
២. ស្ថានភាពស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន ..... 28
២.១. ការរើសអើងស្ត្រី ..... 28
២.១.១. អារម្មណ៍របស់អ្នកជិតខាង អ្នកស្គាល់ មិត្តភក្តិ និងគ្រួសារ ចំពោះស្ត្រីក្រុមប្រឹក្សា ឃុំ សង្កាត់ ..... 28
២.១.២. អាកប្បកិរិយារបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបុរសដែលបានបំពេញកិច្ចការជាមួយស្ត្រី ..... 29
ក្រាហ្វិកទី៥៖ ..... 29
២.២. ការទទួលបានភារកិច្ចការងារ និងសិទ្ធិអំណាចពេញលេញរបស់ស្ត្រីស្របតាមច្បាប់ ..... 30
២.២.១. ការប្រគល់តួនាទី ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ទៅសមាជិការបស់ខ្លួន ..... 30
ក្រាហ្វិកទី៦៖ ..... 30
២.២.២. ការបញ្ឈប់សមាជិកស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ..... 31
២.២.៣. ការចុះចូលគណបក្សផ្សេងរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ..... 32
២.៣. ការបំពេញការងារទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ និងភាពសកម្មរបស់ស្ត្រី ..... 33
២.៤. ការចូលរួមធ្វើសេចក្តីសម្រេចចិត្ត ..... 34
២.៤.១. ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ និងកិច្ចប្រជុំប្រចាំខែ ..... 34
២.៤.២. ការបញ្ចេញមតិយោបល់ ឬសំណើររបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងកិច្ចប្រជុំ ..... 34
តារាងទី៨៖ ..... 35
២.៤.៣. ការឆ្លើយតបទៅលើយោបល់ ឬសំណើររបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងកិច្ចប្រជុំ ..... 36
តារាងទី៩៖ សំណើរ និងយោបល់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានសម្រេចក្នុងកិច្ចប្រជុំ និងដំណោះស្រាយ ..... 36
៣. ថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារនៅឃុំ សង្កាត់ ..... 37
តារាងទី១០៖ ថវិកាសរុបប្រចាំឆ្នាំ ..... 37
៣.១. តម្លាភាពថវិកា ..... 38
ក្រាហ្វិកទី៧៖ ..... 38
៣.២. ការជកថវិកា ..... 39

🗐 ក្រាហ្វិកទី៨៖ ការដកថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ........ 39
**៤. ករណីសិក្សា**........ 41
៤.១. «សកម្មភាពលេចធ្លោរបស់ស្ត្រីនៅថ្នាក់មូលដ្ឋាន»........ 41
🗎 ករណីសិក្សាទី១........ 41
🗎 ករណីសិក្សាទី២........ 44
V.**សេចក្តីសន្និដ្ឋាន និងសង្ខេប**........ 47
VI.**អនុសាសន៍**........ 49

# បុព្វកថា

**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា ហៅកាត់ថា "ខុមហ្វ្រែល"** ធ្វើការដើម្បីលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការចូលរួមរបស់ប្រជាពលរដ្ឋតាមគោលការណ៍អភិវឌ្ឍន៍សមត្ថភាពរបស់បណ្តាញទូទាំងប្រទេស និងសហប្រតិបត្តិការជាមួយអង្គការជាសមាជិក និងជាដៃគូ ។ ប្រជាធិបតេយ្យមិនមែនត្រឹមតែការបោះឆ្នោតប៉ុណ្ណោះទេ ក៏ប៉ុន្តែជាការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ជាលក្ខខណ្ឌចាំបាច់នៃលទ្ធិប្រជាធិបតេយ្យ ។ បន្ថែមពីលើនេះទៀត ការមានគណនេយ្យភាពរបស់គណបក្សជាប់ឆ្នោត និងមន្ត្រីជាប់ឆ្នោតក្នុងការបំពេញតាមការសន្យារបស់ខ្លួន ការលើកស្ទួយ ការការពារការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្តខាងនយោបាយ និងការដឹកនាំ ការបំពេញនូវតួនាទី ភារកិច្ច និងការទទួលបានសិទ្ធិអំណាចពេញលេញជារឿងសំខាន់បំផុតក្នុងអភិក្រមប្រជាធិបតេយ្យ ។

របាយការណ៍ស្តីពី *« ការឃ្លាំមើលយេនឌ័រផ្នែកនយោបាយ ៖ សភា និងតំណាងរាស្ត្រស្ត្រី និងការផ្តល់អំណាចឲ្យស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន»* គឺជាទម្រង់នៃការវិភាគទៅលើទិន្នន័យ និងមតិយោបល់របស់តំណាងជាប់ឆ្នោតស្ត្រីចូលរួមក្នុងកិច្ចការនយោបាយ និងក្នុងដំណើរការសម្រេចចិត្ត ជាពិសេស ការឃ្លាំមើលតាមដាន និងការពិនិត្យមើលលើស្ថានភាពការងាររបស់តំណាងជាប់ឆ្នោតស្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានក្នុង រយៈពេល ១ឆ្នាំ កន្លងទៅនេះ។

របាយការណ៍នេះ បង្ហាញការវាយតម្លៃលើការផ្តល់អំណាចឲ្យស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ សភា និងតំណាងរាស្ត្រស្ត្រីក្នុងអំឡុងពេលបំពេញការងារទាក់ទងនឹងការបញ្ចេញមតិយោបល់ជាបរិមាណ និងគុណភាពរបស់សមាជិកសភាជាស្ត្រីនៅក្នុងពេលប្រជុំពេញអង្គរដ្ឋសភា និងសកម្មភាព និងគោលបំណងរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះមូលដ្ឋានតាមមណ្ឌលរាជធានី ខេត្តនានា ចំនួន និងភាគរយតំណាងរាស្ត្រស្ត្រីធៀបនឹងតំណាងរាស្ត្របុរសដែលបានចុះបេសកកម្ម ភាគរយអ្នកតំណាងរាស្ត្រស្ត្រី និងស្ថានភាពអ្នកនយោបាយស្ត្រីកម្ពុជា ។ បន្ថែមលើនេះទៀត របាយការណ៍នេះក៏បានបង្ហាញផងដែរ អំពីផែនការ និងការប្តេជ្ញាចិត្ត ព្រមទាំងការប្រឈមក្នុងការបំពេញការសន្យារបស់រដ្ឋាភិបាលទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ ។ របាយការណ៍នេះ ក៏ផ្តល់នូវលទ្ធផលនៃការសិក្សាលើក្រុមគោលដៅស្តីពី ការផ្តល់អំណាចឲ្យស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែល និងករណីសិក្សាចំនួនពីរផងដែរ ។

**ខុមហ្វ្រែល** សង្ឃឹមថា របាយការណ៍ឃ្លាំមើលយេនឌ័រផ្នែកនយោបាយនេះ ជាឯកសារដ៏សំខាន់ និងមានប្រយោជន៍សម្រាប់អ្នកអនុវត្តន៍សកម្មភាព ជាពិសេសមន្ត្រីរដ្ឋាភិបាល សមាជិកសភា សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គណបក្សនយោបាយ បុគ្គលិកសមាគម អង្គការមិនមែនរដ្ឋាភិបាល តំណាងរបស់ដៃគូអភិវឌ្ឍន៍ អ្នកស្រាវជ្រាវ ដើម្បីជួយលើកស្ទួយស្ត្រីចូលរួមកាន់តែច្រើនក្នុងវិស័យនយោបាយ និងថ្នាក់សម្រេចចិត្ត ។

សូមថ្លែងអំណរគុណជាពិសេសចំពោះក្រុមការងាររបស់ខុមហ្វ្រែល ដូចជា លោកស្រី **សឺនកេត សិរីលក្ខណ៍** ជាអ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រនៃខុមហ្វ្រែលដែលជាអ្នកសរសេររបាយការណ៍នេះ ។ លោកស្រីក៏ជាអ្នកដឹកនាំក្រុមការងារ ដូចជា លោកស្រី **អ៊ឹម ស៊ីវត្ថា**ជាមន្ត្រីអប់រំ និងយេនឌ័រនៃខុមហ្វ្រែល លោក **នាង សុវណ្ណ** ជាមន្ត្រីអប់រំ និងយេនឌ័រនៃខុមហ្វ្រែល កញ្ញា **យ៉ឹង នីម**ជាមន្ត្រីស្ម័គ្រចិត្ត និង**អ្នកសង្កេតការណ៍ស្ត្រី**ជាជនបង្គោលស្ត្រីមូលដ្ឋាននៃអង្គការខុមហ្វ្រែលដែលបានខិតខំអនុវត្តតាមផែនការសកម្មភាព ដើម្បីប្រមូលទិន្នន័យ និងរចនារបាយការណ៍នេះ ដោយមានការគាំទ្រពីផ្នែកអង្កេត និងលេខាធិការខេត្តខុមហ្វ្រែលទាំង២៥ខេត្ត ក្រុង រាជធានី។ យើងខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះលោក **គល់ បញ្ញា** ជាទីប្រឹក្សានៃអង្គការខុមហ្វ្រែល ដែលបានផ្តល់យោបល់គាំទ្រធ្វើឲ្យរបាយការណ៍នេះកាន់តែមានភាពល្អប្រសើរថែមទៀត ។

រាជធានីភ្នំពេញ ថ្ងៃព្រហស្បត្តិ៍ ៥កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ត្រូវនឹងថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០
**នាយកប្រតិបត្តិខុមហ្វ្រែល**

**គីម ឈន**

# I.សេចក្តីផ្តើម

ការបង្កើនសមាមាត្រស្ត្រីនៅក្នុងស្ថាប័នសាធារណៈធ្វើឲ្យស្ត្រីក្លាយជាអ្នកតំណាងកាន់តែច្រើន បង្កើនការច្នៃប្រឌិត កែលំអការសម្រេចចិត្ត និងផ្តល់ផលប្រយោជន៍ដល់សង្គមទាំងមូល[1]។

យោងតាមលទ្ធផលនៃការអនុវត្តន៍ការងារលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីរបស់រាជរដ្ឋាភិបាលកម្ពុជា និងផ្អែកតាមការសិក្សាស្រាវជ្រាវនៅក្នុងពិភពលោក ភស្តុតាងមួយចំនួនបានបង្ហាញយ៉ាងច្បាស់ថា ការចូលរួម**ស្របច្បាប់ និងពេញលេញ**របស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចអាចធ្វើឲ្យគោលនយោបាយ ច្បាប់ និងកម្មវិធីនានាកាន់តែឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជនទាំងអស់ ជាពិសេសលើបញ្ហាសុខុមាលភាពគ្រួសារ និងសង្គម ដែលជាមូលដ្ឋានគ្រឹះក្នុងការកាត់បន្ថយភាពក្រីក្រឈានឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព[2]។

បញ្ហាវិសមភាពនៃតំណាងជាប់ឆ្នោតជាអ្នកដឹកនាំជាស្ត្រី និងបុរសនៅតែបន្តនៅក្នុងប្រទេសកម្ពុជា ។ ជាក់ស្តែង ស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំ គឺមានចំនួនតិចតួចទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ខណៈដែលបុរសមានចំនួនច្រើនលើសលុបក្នុងរចនាសម្ព័ន្ធនៃការដឹកនាំ ។ តាមបទពិសោធបានបង្ហាញឲ្យឃើញថា កាលណាក្រុមណាមួយ ឬក៏ ភេទណាមួយ មានគំលាតចំនួនធំជាងគ្នាខ្លាំង វានឹងធ្វើឲ្យក្រុម ឬភេទដែលមានចំនួនតិចពុំសូវមានឥទ្ធិពល និងមានសិទ្ធិអំណាចតិចក្នុងការចូលរួមធ្វើសេចក្តីសម្រេច និងអនុវត្តការងារដោយពេញលេញ និងប្រសិទ្ធភាព ហើយក្រុមនោះនឹងទទួលរងនូវការគ្របសង្កត់ដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីពីក្រុម ឬភេទដែលមានចំនួនដ៏ច្រើនលើសលុប ។ បញ្ហាវិសមភាពយេនឌ័រនេះ គឺដោយសារៈ *(១)* ខ្វះនូវគោលនយោបាយជាក់លាក់មួយចំនួន និងខ្វះការអនុវត្តច្បាប់ និងយន្តការដែលមានស្រាប់មួយចំនួនឲ្យបានតឹងរ៉ឹង និងប្រសិទ្ធិភាពដើម្បីគាំទ្រ គាំពារ និងផ្តល់ឱកាសឲ្យស្ត្រីចូលរួមដោយស្មើភាព ពេញលេញក្នុងកិច្ចការសាធារណៈ និងវិស័យនយោបាយ។ *(២)* បន្តការរើសអើងមកលើស្ត្រីក្នុងតួនាទីដឹកនាំ និងកិច្ចការនយោបាយ ។ *(៣)* រាជរដ្ឋាភិបាលកម្ពុជា ខកខានការអនុវត្តកាតព្វកិច្ចជារដ្ឋភាគីនៃអនុសញ្ញាអន្តរជាតិ ស្តីពី « ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ»(ស៊ី-ដរ/CEDAW)ដែលកម្ពុជាជារដ្ឋហត្ថលេខីតាំងពីឆ្នាំ១៩៩២ ។ *(៤)* អ្នកដឹកនាំជាបុរសនៅតែចង់រក្សាអំណាចនយោបាយ និងមិនចង់ចុះចេញពីតំណែង ។ ក្នុងនាមជារដ្ឋភាគីនៃអនុសញ្ញាស៊ី-ដរ រាជរដ្ឋាភិបាលកម្ពុជាបានរំលឹកថា ការរើសអើងប្រឆាំងនឹងស្ត្រី គឺរំលោភលើគោលការណ៍ស្មើភាពគ្នានៃការគោរព និងសេចក្តីថ្លៃថ្នូរបស់មនុស្ស វាគឺជាឧបសគ្គចំពោះការចូលរួមរបស់ស្ត្រីស្មើភាពនឹងបុរសក្នុងជីវិតនយោបាយ សង្គម សេដ្ឋកិច្ច និងវប្បធម៌ ។ ការរើសអើងប្រឆាំងនឹងស្ត្រីបានរារាំងការរីកចម្រើនរុងរឿងនៃសង្គម និងគ្រួសារ ហើយធ្វើឲ្យមានការលំបាកកាន់តែខ្លាំងចំពោះការអភិវឌ្ឍន៍ពេញលេញនៃសក្តានុពលរបស់ស្ត្រី ។

[1] Antonio Guterres, United Nations Secretary-General, Message on International Women's Day 2017

[2] សុន្ទរកថារបស់លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយសភា ព្រឹទ្ធសភា និងអធិការកិច្ចក្នុងពិធីបើកវេទិកា ជាតិ ស្តីពី «ស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ» នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥

ក្រៅពីការបន្តបញ្ហាវិសមភាពនៃតំណាង និងការអនុវត្តសិទ្ធិរវាងស្ត្រី និងបុរសនៅកម្ពុជានៅគ្រប់លំដាប់ថ្នាក់ ការសង្កេត តាមដាន និងការពិនិត្យមើលលើស្ថានភាពការងាររបស់តំណាងជាប់ឆ្នោតស្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានថាតើមានភាពប្រឈមយ៉ាងណា តើស្ត្រីទាំងនោះធ្វើការមានលទ្ធផលយ៉ាងណាខ្លះ? មានការរើសអើងដែរឬទេ? តើអ្វីជាការបរាជ័យរបស់ពួកគាត់? គឺជារបៀបវារៈសំខាន់បំផុតដែលត្រូវស្វែងយល់ និងឃ្លាំមើលដោយយកចិត្តទុកដាក់ពីគ្រប់ភាគីពាក់ព័ន្ធ ប្រយោជន៍លើកស្ទួយ ការពារការចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តខាងនយោបាយ និងការដឹកនាំ រួមទាំងការបំពេញ និងទទួលបាននូវតួនាទី ភារកិច្ច និងសិទ្ធអំណាចពេញលេញរបស់ស្ត្រីផងដែរ ។

របាយការណ៍ឃ្លាំមើលយេនឌ័រផ្នែកនយោបាយរបស់ខុមហ្វ្រែលប្រចាំឆ្នាំ២០១៩នេះ ត្រូវបានធ្វើឡើងតាមវិធីសាស្ត្រសង្កេតការណ៍ដោយផ្ទាល់ តាមដាន ឃ្លាំមើល ការសម្ភាសន៍តាមបែបសំណេះសំណាល (Semi-Interview) ការសម្ភាសន៍ផ្ទាល់ (Interview) និងការពិនិត្យមើលលើស្ថានភាព និងការងាររបស់តំណាងស្ត្រីជាប់ឆ្នោតទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ។ សំណួរចំបង គឺ *តើស្ត្រីជាប់ឆ្នោតទាំងនោះធ្វើការបានលទ្ធផលយ៉ាងណាខ្លះ? មានការរើសអើងដែរឬទេ? តើអ្វីជាការប្រឈមរបស់ស្ត្រី? និងមូលហេតុអ្វី? តើអ្នកតំណាងរាស្ត្រស្ត្រី និងបុរសបានចុះមូលដ្ឋានកម្រិតណា? ក្នុងគោលបំណងអ្វីខ្លះ? ថាតើការការពារការចូលរួម របស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចខាងនយោបាយ និងការដឹកនាំ ការបំពេញ និងទទួលបាននូវតួនាទីភារកិច្ចស្របតាមច្បាប់ ព្រមទាំងទទួលបានសិទ្ធិអំណាចពេញលេញកម្រិតណា?*

## *អ្នកតំណាងរាស្ត្រស្ត្រីឡើងបញ្ចេញមតិក្នុងកិច្ចប្រជុំពេញអង្គរដ្ឋសភា*

តំណាងរាស្ត្រស្ត្រីដែលបានឡើងបញ្ចេញមតិក្នុងកិច្ចប្រជុំសភាពេញអង្គសម្រាប់ឆ្នាំទី១ នីតិកាលទី៦នេះមានចំនួន ១នាក់ ស្មើនឹង ៣,៨៤% នៃតំណាងរាស្ត្រស្ត្រីសរុប២៦នាក់។ តំណាងរាស្ត្របុរសមានចំនួន ១១នាក់ ស្មើនឹង ១១,១១% នៃតំណាងរាស្ត្របុរសសរុប ៩៩នាក់។ ចំនួននៃការឡើងបញ្ចេញមតិនេះ គឺមានកម្រិតទាបបំផុត ៩,៦០% បើធៀបនឹងចំនួនអ្នកតំណាងរាស្ត្រសរុប ១២៥នាក់។

*លោកជំទាវ* ***ឡោក ខេង*** អ្នកតំណាងរាស្ត្រស្ត្រីនៅមណ្ឌលរាជធានីភ្នំពេញ បានឡើងបញ្ចេញមតិចំនួន១ដងក្នុងន័យ**វិជ្ជមាន** ដោយផ្តោតទៅលើការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ និងបានបង្ហាញពីការគាំទ្រច្បាប់នេះដែលបាននាំផលប្រយោជន៍ជូនប្រជាពលរដ្ឋ និងធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនទៅមុខយ៉ាងលឿន ព្រមទាំងគាំទ្រសមិទ្ធផល កិច្ចខិតខំប្រឹងប្រែងពាក់ព័ន្ធនឹងការកសាង និងការជួយឧបត្ថម្ភផ្សេងៗដល់ប្រជាពលរដ្ឋ។

## *សកម្មភាពរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះមូលដ្ឋាន*

សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ ក្នុងរយៈពេលចាប់ពីខែកញ្ញា ឆ្នាំ២០១៨ រហូតដល់ ខែសីហា ឆ្នាំ២០១៩ មានតំណាងរាស្ត្រចំនួន**៦៤នាក់** ក្នុងនោះមាន**ស្ត្រី១៨នាក់**ក្នុងចំណោមតំណាងរាស្ត្រសរុប

១២៥នាក់បានចុះមូលដ្ឋានសរុបចំនួន**១១៥៦លើក**។ ចំនួននេះបាន**ថយចុះ**ចំនួន **៥០៩លើក** ពី **១៦៦៥លើក** នីតិកាលទី៥ ឆ្នាំ២០១៦[3] មកត្រឹម **១១៦៥លើក** នីតិកាលទី៦ ក្នុងឆ្នាំទី១។

*ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រស្ត្រីបានចុះបេសកកម្ម* ***ប្រហាក់ប្រហែលនឹងភាគរយសរុបរបស់អ្នកតំណាងរាស្ត្របុរសដែលបានចុះបេសកកម្ម*** គឺ **៥៣,៨៤%** ស្មើនឹងចំនួនតំណាងរាស្ត្រស្ត្រី១៤នាក់ក្នុងចំណោមសមាជិកសភាស្ត្រី២៦នាក់ ច្រើនជាងបន្តិចភាគរយរបស់អ្នកតំណាងរាស្ត្របុរសចំនួន **៥០,៥០%** ស្មើនឹង៥០នាក់ក្នុងចំណោមសមាជិកសភាបុរស៩៩នាក់។ បើប្រៀបធៀបនឹងនីតិកាលទី៥ដែលគណបក្សចំនួនពីរមានអាសនៈនៅក្នុងរដ្ឋសភា(គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ) ភាគរយអ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្ម មានការ**ថយចុះខ្លាំង** ពី ៨៣,៣៣% នីតិកាលទី៥ ឆ្នាំ២០១៦ មកត្រឹម៥៣,៨៤% នីតិកាលទី៦ ឆ្នាំ២០១៩ ខណៈដែលភាគរយអ្នកតំណាងរាស្ត្របុរសចុះបេសកកម្មក៏មានការ**ថយចុះខ្លាំងដែរ** គឺ ពី ៧៨,៧៩% នីតិកាលទី៥ ឆ្នាំ២០១៦ មកត្រឹម ៥០,៥០ % នីតិកាលទី៦ ឆ្នាំ២០១៩។

តំណាងរាស្ត្រស្ត្រីចំនួន១៤នាក់មកពីគណបក្សប្រជាជនកម្ពុជាតែមួយគត់ដែលមានអាសនៈនៅក្នុងរដ្ឋសភាបានធ្វើសកម្មភាពនៅមូលដ្ឋានសរុបចំនួន **២២៩លើក**។ ចំនួនសកម្មភាពនេះ បាន**ថយចុះ**ចំនួន **១១០លើក** ពី **៣៣៩លើក** នីតិកាលទី៥ ឆ្នាំ២០១៦ មកត្រឹម **២២៩លើក** នីតិកាលទី៦ ក្នុងឆ្នាំ២០១៩។ បើប្រៀបធៀប ពីគោលបំណងមួយទៅគោលបំណងមួយនៃការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រីបង្ហាញឲ្យឃើញថា មានការ**ខុសគ្នាឆ្ងាយ**រវាងតួលេខនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាដែលមានចំនួន**១៧៣លើក** **(៧៥,៥៤%)** ជាមួយនឹងការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋមានចំនួន **០លើក (០%)**។ ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សចំនួន ៣៥លើក។ ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំមានចំនួន២១លើក។ ចំណែកឯ ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិល និងការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋ* គឺពុំឃើញមានអ្នកតំណាងរាស្ត្រស្ត្រីណាម្នាក់យកចិត្តទុកដាក់ចូលរួម និងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋឡើយ។ តួលេខនេះ នៅតែបង្ហាញយ៉ាងច្បាស់ថា សកម្មភាពនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានានៅតែជាសកម្មភាពអាទិភាព និងសកម្មដដែល ខណៈដែលការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សក៏ជាសកម្មភាពអាទិភាពផងដែរ។*

តំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្ម**ច្រើនជាងគេបំផុត** នៅក្នុងឆ្នាំទី១ នីតិកាលទី៦នេះ គឺ **លោកជំទាវ ម៉ែន សំអន** តំណាងរាស្ត្រមណ្ឌលខេត្តស្វាយរៀងមានចំនួន **៥៨លើក គឺមានការកើនឡើងជិត៤ដង** បើធៀបនឹងនីតិកាលទី៥ ឆ្នាំ២០១៦ មានចំនួនតែ ១៥លើក។ អ្នកដែល**ច្រើនបន្ទាប់** គឺ **លោកជំទាវ ចាន ស្រីមុំ** តំណាងរាស្ត្រមណ្ឌលខេត្តប៉ៃលិន មានចំនួន **៥២លើក គឺបានកើនឡើងខ្លាំង ១៣ដង** បើធៀបនឹងនីតិកាលទី៥ ឆ្នាំ២០១៤ មានចំនួនតែ ៤លើក។ អ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះមូលដ្ឋាន**ច្រើនបន្ទាប់** គឺ លោក

[3] របាយការណ៍ខុមហ្វ្រែល ឃ្លាំមើលយេនឌ័រផ្នែកនយោបាយ៖ សភា និងតំណាងរាស្ត្រស្ត្រី និងស្ត្រីក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ ចេញផ្សាយនៅខែមីនា ឆ្នាំ២០១៧ (COMFREL's Website: www.comfrel.org)

ជំទាវ **ឡោក ខេង** តំណាងរាស្ត្រមណ្ឌលរាជធានីភ្នំពេញ មានចំនួន **៣៨លើក** **គឺប្រហាក់ប្រហែលនឹងនីតិ**កាលទី៥ ឆ្នាំ២០១៦ មានចំនួន ៣៩លើក។

## ស្ថានភាពអ្នកនយោបាយស្ត្រីកម្ពុជា

ចន្លោះពីដើមឆ្នាំ ដល់ពាក់កណ្តាលឆ្នាំ២០១៩ អ្នកនយោបាយស្ត្រីដែលប្រើប្រាស់សិទ្ធិនយោបាយរបស់ខ្លួន និងសិទ្ធិស្ត្រីដើម្បីចូលរួមក្នុងដំណើរការប្រជាធិបតេយ្យនៅប្រទេសកម្ពុជាត្រូវបានប្រឈមការចោទប្រកាន់តាមផ្លូវតុលាការ ការរើសអើង ការឃាយី ការគំរាមកំហែង និងការវិតត្បិតពីសំណាក់អាជ្ញាធរ សូម្បីតែការជួបប្រជុំគ្នា ការពិភាក្សាគ្នាអំពីរឿងនយោបាយរបស់ស្ត្រីក៏ត្រូវបានរំខាន ដូចជា សារព្រមានរបស់លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន**ចំពោះក្រុមស្ត្រីជួបប្រជុំគ្នាពិភាក្សារឿងនយោបាយ។ អតីតចៅសង្កាត់អូចារ ខេត្តបាត់ដំបង ត្រូវបានតុលាការកោះហៅជាបន្តបន្ទាប់។ ការជួបជុំទទួលទានអាហាររួមគ្នារបស់អតីតសមាជិកនិងមន្ត្រីបក្សសង្គ្រោះជាតិត្រូវបានអាជ្ញាធររំខាន មិនអនុញ្ញាត។ ក្រុមស្ត្រីជាប់ឆ្នោតជាមេឃុំ សមាជិកក្រុមប្រឹក្សាខេត្ត និងស្រុកនៃអតីតគណបក្សសង្គ្រោះជាតិក្នុងខេត្តកំពង់ស្ពឺ ចំនួន **៦រូប**ត្រូវបង្ខំចិត្តរត់គេចខ្លួនដើម្បីសុវត្ថិភាពចៀសពីការធ្វើទុក្ខបុកម្នេញពីអាជ្ញាធររបបក្រុងភ្នំពេញ។

សកម្មភាពរបស់រដ្ឋាភិបាល និងទង្វើរបស់អាជ្ញាធរ ជាការប្រព្រឹត្តិផ្ទុយនឹងអនុសញ្ញាស៊ី-ដរ មាត្រា៣ចែងថា « ក្នុងគ្រប់វិស័យ ជាពិសេសវិស័យ នយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីធានាការអភិវឌ្ឍន៍ និងការរីកចំរើនពេញលេញរបស់ស្ត្រីដើម្បីធានាឲ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដោយសមភាពជាមួយបុរស »។ និងមាត្រា៧ បានចែងថា « រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្រប ដើម្បីលុបបំបាត់ចោលការរើសអើងប្រឆាំងនឹងស្ត្រីក្នុងជីវភាពនយោបាយ និងសាធារណៈរបស់ប្រទេស ។… » ។ ទង្វើទាំងនេះ ក៏ជាការរំលោភបំពានមកលើ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានការពារសិទ្ធិសេរីភាពបញ្ចេញមតិ និងការជួបប្រជុំដែលមានចែងក្នុងមាត្រា៤១ « ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។…» និងបានរំលោភបំពានយ៉ាងខ្លាំងចំពោះកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៩ កថាខណ្ឌ២ ចែងថា « ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ។…» ។

## ចំនួនអាណត្តិរបស់ស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់

ស្ត្រីភាគច្រើនក្នុងចំណោមស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៣៦នាក់ មិនមានឱកាសបានធ្វើជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៤អាណត្តិឡើយ ទោះបីពួកគេខិតខំប្រឹងប្រែង និងមានបទពិសោធយ៉ាងណាក៏ដោយ ហើយកាន់តែមានឱកាសតិចតួចទៅទៀតចំពោះស្ត្រីដែលនឹងត្រូវជាប់ឆ្នោតថ្មីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ នេះអាចមកពីខ្វះការយកចិត្តទុកដាក់ពីប្រធានគណបក្សនៅថ្នាក់ក្រោមជាតិ(ខេត្ត ស្រុក ឃុំ) ជាពិសេសប្រធានគណបក្សនៅថ្នាក់ឃុំ សង្កាត់ដែលភាគច្រើនជាបុរសមានតួនាទីជាមេឃុំ ចៅសង្កាត់ និងខ្វះនូវគោលនយោបាយលើកស្ទួយស្ត្រីនៅក្នុងគណបក្សរបស់ខ្លួនផងដែរ។

## ការលើកស្ទួយ និងការចូលរួមធ្វើសេចក្ដីសម្រេច

អាកប្បកិរិយារើសអើងចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មានការ**ថយចុះខ្លាំង** ខណៈដែលមានការគាំទ្រ និងលើកកម្ពស់ស្ត្រីខ្លាំងពីបុរសក្រុមប្រឹក្សាឃុំ សង្កាត់ និងមេភូមិ ដោយបុរសទាំងនោះមានការផ្លាស់ប្ដូរអាក្បកិរិយាឲ្យតម្លៃស្ត្រី បានយល់ដឹងពីយេនឌ័រ គោរពសិទ្ធិស្ត្រី និងបានសហការល្អជាមួយស្ត្រីក្នុងការធ្វើការងារ ការដោះស្រាយបញ្ហា និងការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន។ ទោះបីយ៉ាងណាក៏ដោយ ការរើសអើងចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួននៅតែបន្តមាននៅឡើយ ដោយបុរសក្រុមប្រឹក្សាឃុំ សង្កាត់ខ្លះមិនចង់សហការ និងមានការរិះគន់ចំពោះស្ត្រី។ បើប្រៀបធៀបនឹងអាណត្តិទី៣ ឆ្នាំ២០១៥ ការគាំទ្រស្ត្រី ការលើកទឹកចិត្តស្ត្រី ការឲ្យតម្លៃស្ត្រី និងការសហការជាមួយស្ត្រីមានការកើនឡើង ពី ៨២,៩២% នៅឆ្នាំ២០១៥ (អាណត្តិទី៣) ឡើងដល់ ៩៧,២២% នៅឆ្នាំ២០១៩ (អាណត្តិទី៤) ខណៈដែលការរើសអើងមានការថយចុះ គឺពី ១២,១៩% ឆ្នាំ២០១៥ មកត្រឹម ២,៧៧% នៅឆ្នាំ២០១៩។

ចំណែកឯការរើសអើងទាក់ទងនឹងការប្រគល់តួនាទី ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ទៅសមាជិកស្ត្រីស្របតាមតួនាទីរបស់ខ្លួននោះ របាយការណ៍ខុមហ្វ្រែលរកឃើញថា ប្រធានក្រុមប្រឹក្សាបានប្រគល់តួនាទី ភារកិច្ចជូនស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ភាគច្រើនដូចមានចែងក្នុងច្បាប់ ខណៈដែលស្ត្រីក្រុមប្រឹក្សាឃុំ**ភាគតិចមិនត្រូវបាន**ប្រធានក្រុមប្រឹក្សាឃុំប្រគល់តួនាទី ភារកិច្ចឲ្យខ្លួនទាល់តែសោះ។ បើប្រៀបធៀបនឹងឆ្នាំ២០១៥ ការរើសអើងមិនប្រគល់ភារកិច្ចជូនដល់សមាជិកស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ មានការ**ថយចុះ** ពី ៩,៧៥% ឆ្នាំ២០១៥ (អាណត្តិទី៣) មកត្រឹម ២,៧៧% ឆ្នាំ២០១៩ (អាណត្តិទី៤)។ បើទោះបីតួលេខរើសអើងនេះមានការថយចុះក៏ដោយ ក៏នៅតែបង្ហាញនូវការរើសអើងកាន់តែខ្លាំងថែមទៀតមិនធ្លាប់បានឮពីមុន ដែលជាបញ្ហាបន្ទាន់ត្រូវយកចិត្តទុកដាក់ដោះស្រាយជាចាំបាច់ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាដែលមិនបានទទួលតួនាទី ភារកិច្ចរបស់ខ្លួនសោះ ឬទទួលមិនបានពេញលេញដើម្បីអនុវត្តការងារស្របតាមច្បាប់ ស្ដីពី « *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់* » ដែលបានធានាដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវតែមានភារកិច្ចទៅតាមតួនាទីរៀងៗខ្លួន។

មានភាពប្រសើរក្នុងការចូលរួមបញ្ចេញមតិ យោបល់ និងការចូលរួមធ្វើសេចក្ដីសម្រេចចិត្តរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ដូចបុរសដែរ បើទោះបីចំនួនបុរសមានច្រើនជាងស្ត្រីក៏ដោយ។ ស្ត្រីបានបង្ហាញពីសក្ដានុពលរបស់ខ្លួន ភាពជឿជាក់លើខ្លួនឯង និងបានប្រើប្រាស់សិទ្ធិក្នុងការឡើងបញ្ចេញមតិយោបល់ក្នុងពេលធ្វើការងារ និងក្នុងកិច្ចប្រជុំដែលភាគច្រើនផ្ដោតលើបញ្ហាស្ត្រី កុមារ និងចាស់ជរារួមទាំងកិច្ចអភិវឌ្ឍន៍ផងដែរ។

## ភាពសកម្មរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់

ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ បាន និងកំពុងមមាញឹកធ្វើការយ៉ាងសកម្មនាពេលបច្ចុប្បន្នក្នុងតួនាទីរបស់ខ្លួនទាំងស្ត្រីដែលមានតួនាទីជាជំទប់ទី១ ជំទប់ទី២ សមាជិកក្រុមប្រឹក្សាឃុំ និងស្ត្រីមេឃុំ ចៅសង្កាត់។ ពួកគាត់កំពុងជាប់រវល់ជាមួយនឹងការដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារ បញ្ហាអំពើហិង្សា បញ្ហារំលោភផ្លូវភេទ បញ្ហាសុខភាព និងអនាម័យ ទំនាស់ដីធ្លី ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យមានការយល់ដឹងអំពីយេនឌ័រ

ចុះស្រង់ស្ថិតិគ្រួសារក្រីក្រ និងជនពិការ និងចែកអំណោយដល់ប្រជាពលរដ្ឋក្រីក្រ ជាពិសេសផ្សព្វផ្សាយឲ្យស្ត្រីកំពុងមានផ្ទៃពោះ និងស្ត្រីសម្រាលកូនរួចបានយល់ដឹងអំពីការថែទាំសុខភាពមុន និងក្រោយពេលសម្រាលកូន ព្រមទាំងផ្សព្វផ្សាយអំពីបញ្ហាគ្រឿងញៀន និងគ្រឿងស្រវឹងនៅតាមសាលារៀន និងតាមមូលដ្ឋាន។ បន្ថែមលើនេះទៀត ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនេះបានចុះតាមផ្ទះប្រជាពលរដ្ឋដើម្បីសួរសុខទុក្ខ និងផ្តល់ជាស្បៀង ថវិកាដល់ស្ត្រីមេម៉ាយ ចាស់ជរាគ្មានទីពឹងទីទាល់ក្រលំបាក ជួយដល់ស្ត្រីចាស់ជរា និងក្មេងកំព្រាគ្មានទីពឹង។ ការចុះអន្តរាគមន៍ដល់ប្រជាពលរដ្ឋ សម្របសម្រួលនៅក្នុងគ្រួសារដែលមានអំពើហឹង្សា ជួយពង្រឹងការងារដល់ស្ត្រីសមាជិកភូមិ ចុះតាមដានវាយតម្លៃគណៈកម្មការស្ត្រីនៅតាមភូមិ និងការទទួលខុសត្រូវរួមលើការគ្រប់គ្រងឃុំ សង្កាត់ ដើម្បីឲ្យឃុំ សង្កាត់របស់ខ្លួនមានការអភិវឌ្ឍន៍ និងសុវត្ថិភាព។

## ថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ

តម្លាភាពថវិកានៅមានកម្រិតសម្រាប់កិច្ចការស្ត្រី និងកុមារនៅឃុំ សង្កាត់មួយចំនួន។ ឃុំ សង្កាត់ភាគច្រើនមានភាពងាយស្រួលក្នុងការដកថវិកាមកប្រើប្រាស់លើកិច្ចការស្ត្រី និងកុមារ ប៉ុន្តែថវិកានៅមានចំនួនតិច រីឯឃុំមួយចំនួនតូចមានការពិបាកក្នុងការដកថវិកា។

ក្នុងចំណោម ១៩ឃុំ សង្កាត់ មាន**១៦ឃុំ**មានភាព**ងាយស្រួល**ក្នុងការដកថវិកាមកប្រើប្រាស់លើកិច្ចការស្ត្រី និងកុមារ។ រីឯ **៣ឃុំ**ទៀតមាន**ការពិបាក**ក្នុងការដកថវិកាពីរតនាគារ ស្មៀនជាអ្នកចាត់ចែងថវិកា និងពុំមានបែងចែកកញ្ចប់ថវិកាច្បាស់លាស់ទៅតាមផ្នែកនីមួយៗ។ ឃុំដែលមានការពិបាកដកថវិកាគឺ ឃុំអញ្ចាញរូង និងឃុំពពេល (ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង) និង ឃុំក្រាំងស្គារ (ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង)។ ដោយឡែកមានមតិផ្ទុយគ្នានៅក្នុង ឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ម្នាក់ថាងាយស្រួលដក ម្នាក់ទៀតថាពិបាកដក។

# II. ការឃ្លាំមើលសភា និងតំណាងរាស្ត្រស្ត្រី

ក្រោយពីគណបក្សសង្គ្រោះជាតិត្រូវបានរំលាយកាលពីដើមឆ្នាំទី៥ នៃនីតិកាលទី៥ យើងឃើញមានគណបក្សចំនួន៤មានអាសនៈក្នុងរដ្ឋសភា គឺគណបក្សហ្វ៊ុនស៊ិនប៉ិច គណបក្សខ្មែរអភិវឌ្ឍសេដ្ឋកិច្ច គណបក្សខ្មែរឈប់ក្រ[4] និងគណបក្សប្រជាជនកម្ពុជា។ ពហុបក្សនៃរដ្ឋសភាក្នុងឆ្នាំទី៥ (២០១៨) នៃនីតិកាលទី៥ បានដំណើរការបានត្រឹមតែមួយឆ្នាំប៉ុណ្ណោះ។ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សម្រាប់នីតិកាលទី៦ (ឆ្នាំ២០១៨-ឆ្នាំ២០២៣)ត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដោយការបោះឆ្នោតនេះមានគណបក្សនយោបាយចំនួន ២០ បានចូលរួមប្រកួតប្រជែង ដោយមិនមានវត្តមានគណបក្សប្រឆាំងដ៏ធំគឺគណបក្សសង្គ្រោះជាតិកម្ពុជារួមមាន៖ (១)គណបក្សខ្មែររួបរួមជាតិ (២)គណបក្សមាតុភូមិយើង (៣)គណបក្សពន្លឺថ្មី (៤)គណបក្សសញ្ជាតិកម្ពុជា (៥)គណបក្សខ្មែរក្រោក (៦)គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ (៧)គណបក្សប្រជាធិតេយ្យមូលដ្ឋាន (៨)គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ (៩)គណបក្សរស្មីខេមរា (១០)គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ (១១)គណបក្សខ្មែរសាធារណរដ្ឋ (១២)គណបក្សខ្មែរឈប់ក្រ (១៣)គណបក្សហ្វ៊ុនស៊ិនប៉ិច (១៤)គណបក្សខ្មែរអភិវឌ្ឍសេដ្ឋកិច្ច (១៥)គណបក្សយុវជនកម្ពុជា (១៦)គណបក្សធម្មាធិបតេយ្យ (១៧)គណបក្សឆន្ទៈខ្មែរ (១៨)គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា (១៩)គណបក្សខ្មែរតែមួយ និង(២០)គណបក្សប្រជាជនកម្ពុជា។ ជាលទ្ធផលនៃការបោះឆ្នោតនេះមានតែគណបក្សប្រជាជនកម្ពុជាមួយប៉ុណ្ណោះ ដែលទទួលបានទាំង១២៥អាសនៈនៅក្នុងរដ្ឋសភាសម្រាប់នីតិកាលទី៦។

នៅក្នុងនីតិកាលទី៦ រដ្ឋសភាជាតិកម្ពុជាត្រូវបានដឹកនាំដោយឯកបក្ស គឺគណបក្សប្រជាជនកម្ពុជា ដើម្បីធ្វើការអនុម័តច្បាប់នានា ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត ការដោះស្រាយនូវតម្រូវការ និងជម្លោះជូនម្ចាស់ឆ្នោត និងការចុះមូលដ្ឋាន។ល។

នៅឆ្នាំទី១នៃនីតិកាលទី៦ ខុមហ្វ្រែលបានដាក់មន្ត្រីដើម្បីតាមដាន និងអង្កេតលើដំណើរការនៃការប្រព្រឹត្តិទៅរបស់រដ្ឋសភារួមមាន សម័យប្រជុំរដ្ឋសភា ការឡើងបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រ ការចុះអន្តរាគមន៍របស់អ្នកតំណាងរាស្ត្រ និងការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រនៅតាមមណ្ឌលបោះឆ្នោត។

## ១. ដំណើរការសម័យប្រជុំសភា

រដ្ឋសភាកម្ពុជា នីតិកាលទី៦ ក្នុងឆ្នាំទី១នេះ បានបើកសម័យប្រជុំពេញអង្គសាមញ្ញសាធារណៈរបស់ខ្លួនចំនួនពីរលើក និងបើកកិច្ចប្រជុំវិសាមញ្ញសាធារណៈចំនួនមួយលើក។ សម័យប្រជុំពេញអង្គសាមញ្ញសាធារណៈចំនួនពីរលើក គឺ**លើកទី១** ចាប់ពីដើមខែកញ្ញា ឆ្នាំ២០១៨ រហូតដល់ដើមខែមករា ឆ្នាំ២០១៩ និង **លើកទី២** គឺចាប់ពីដើមខែមេសា ឆ្នាំ២០១៩ រហូតដល់ដើមខែកក្កដា ឆ្នាំ២០១៩។ ចំណែកឯកិច្ចប្រជុំវិសាមញ្ញ

[4] គណបក្សហ្វ៊ុនស៊ិនប៉ិចគណបក្ស គណបក្សខ្មែរអភិវឌ្ឍសេដ្ឋកិច្ច គណបក្សខ្មែរឈប់ក្រ ត្រូវបាន គ.ជ.ប បែងចែកអាសនៈរបស់គណបក្សសង្គ្រោះជាតិ ក្រោយពីគណបក្សមួយនេះត្រូវបានតុលាការកំពូលរំលាយចោលកាលពីខែវិច្ឆកា ឆ្នាំ២០១៧ ។

សាធារណៈរដ្ឋសភាបានបើកកិច្ចប្រជុំនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៩ ក្នុងសម័យប្រជុំនេះរដ្ឋសភាបានរៀបចំកិច្ចប្រជុំចំនួន ៩កិច្ចប្រជុំ ដោយក្នុងនោះភាគច្រើនចំណាយពេលមួយព្រឹកក្នុងមួយកិច្ចប្រជុំ។

រដ្ឋសភាមានរបៀបវារៈចំនួន២៩ ដែលសម័យប្រជុំពេញអង្គសាមញ្ញសាធារណៈលើកទី១ បានរួមបញ្ចូលទាំងការសម្រេចអំពីសុពលភាពនៃអាណត្តិរបស់បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ ១២៥រូប នីតិកាលទី៦នៃរដ្ឋសភាចំនួន១ដង។ អនុម័តបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នីតិកាលទី៦ចំនួន១ដង។ ការបោះឆ្នោតជាកញ្ចប់ដើម្បីជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា និងផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាលចំនួន១ដង។ ការអានព្រះរាជសាររបស់ព្រះមហាក្សត្រជូនសម័យប្រជុំចំនួន១ដង។ ក្នុងសម័យប្រជុំពេញអង្គសាមញ្ញសាធារណៈលើកទី២ គឺរបាយការណ៍សង្ខេបស្តីពីសកម្មភាពរដ្ឋសភានៅចន្លោះសម័យរដ្ឋសភាចំនួន១។ សេចក្តីព្រាងច្បាប់ចំនួន១៤ សេចក្តីស្នើវិសោធនកម្មច្បាប់ចំនួន៣ ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំនួន៦ដង និងការកោះហៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មកបំភ្លឺចំនួន១ដង។

សេចក្តីព្រាងច្បាប់ចំនួន១៤ ដែលត្រូវបានរដ្ឋសភាពិភាក្សា និងអនុម័តរួមមាន៖ *(១).*ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសភាសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។ *(២).*ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ (ក).កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការជៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។ (ខ).កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី ស្តីពីការជៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។ *(៣).*ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។ *(៤).*ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី។ *(៥).*សេចក្តីព្រាងច្បាប់ ស្តីពីការការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុនស្នេថេកខូអិលធីឌី។ *(៦).*សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុនអេសភីអេលភី(ខេមបូឌា)។ *(៧).*សេចក្តីព្រាងច្បាប់ ស្តីពី ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃកិច្ចព្រមព្រៀង ស្តីពី វិធានការរដ្ឋម្ចាស់កំពង់ផែ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការនេសាទខុសច្បាប់ គ្មានរបាយការណ៍ និងគ្មានការអនុញ្ញាត។ *(៨).*សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣។ *(៩).*សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុនស្នេថេករីញូវេបិល។ *(១០).*ការពិភាក្សា និងអនុម័តសេចក្តីព្រៀងច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត។ *(១១).*ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស ស្តីពីការជម្រុញ និងការការពារទៅវិញទៅមកនៃវិនិយោគ។ *(១២).*ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយលល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រ

កម្ពុជា និងសហភាពអារ៉ាប់មីរ៉េត ស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃការវិនិយោគ។ *(១៣)*.ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋទូកគីស្តីពីការជំរុញ និងការការពារទៅវិញទៅមកនៃការវិនិយោគ។ *(១៤)*.ការពិភាក្សា និងអនុម័ត្រសេចក្តីព្រាងច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គការបណ្តាញអន្តរជាតិសម្រាប់ឫស្សី និងផ្តៅ។

## សេចក្តីស្នើវិសោធនកម្មច្បាប់ចំនួន៣ ដែលរដ្ឋសភាបានអនុម័ត និងពិភាក្សារួមមាន៖

*(១)*.សេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មមាត្រា៤៥ថ្មី(ស្ទួន)នៃច្បាប់ស្តីពីគណបក្សនយោបាយ។
*(២)*.សេចក្តីស្នើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។
*(៣)*.សេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំនួន៦លើក ដែលរដ្ឋសភាបានអនុម័ត និងពិភាក្សារួមមាន៖

*(១)*.ការបោះឆ្នោតជ្រើសតាំងឯកឧត្តម **ច័ន្ទ សុផល** ជាសមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធា រណៈ។
*(២)*.ការបោះឆ្នោតជ្រើសតាំងឯកឧត្តម **ប្រាជ្ញ ច័ន្ទ** ជាសមាជិកគណៈកម្មការសិទ្ធិមនុស្សទទួលពាក្យបណ្តឹងអង្កេត និងទំនាក់ទំនងរដ្ឋសភា និងព្រឹទ្ធសភា។
*(៣)*.ការបោះឆ្នោតជ្រើសតាំងលោកជំទាវ **លី ខួចឡេង** ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញសម្រាប់អាណត្តិឆ្នាំ ២០១៩-២០២៨។
*(៤)*. ការសម្រេចអំពីសុពលភាពនៃ អាណត្តិរបស់ឯកឧត្តម **សុខ ផេង** ជាតំណាងរាស្រ្តមណ្ឌលខេត្តព្រៃវែង ជំនួសឯកឧត្តម **ពៅ សាមី** ដែលបានទទួលមរណភាពដោយរោគាពាធ។
*(៥)*.ការបោះឆ្នោតជ្រើសតាំងឯកឧត្តម **អ៊ិត រ៉ាឌី** ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រាប់អាណត្តិថ្មី ជ្រើសដោយរដ្ឋសភានីតិកាលទី៦។ និង
*(៦)*.ការធ្វើសេចក្តីសម្រេច អំពីសុពលភាពនៃអាណត្តិរបស់បេក្ខជនជាប់ឆ្នោតតំណាងរាស្រ្ត ចំនួន៣៨រូប។

## តំណាងរាស្រ្តជំនួសតំណាងរាស្រ្តដែលបានលាលែងពីសមាជិករដ្ឋសភា នីតិកាលទី៦ រួមមាន៖

| ល.រ | ឈ្មោះតំណាងរាស្រ្តជំនួស | ឈ្មោះតំណាងរាស្រ្តលាលែង | មណ្ឌល |
|---|---|---|---|
| ១ | ឯកឧត្តម ភូ ពុយ | ឯកឧត្តម អង្គវង្ស វឌ្ឍនា | ខេត្តបាត់ដំបង |
| ២ | ឯកឧត្តម សៀង ស៊ិតថង | ឯកឧត្តម សក់ សេដ្ឋា | ខេត្តបាត់ដំបង |
| ៣ | ឯកឧត្តម ម៉ា ឈឿន | ឯកឧត្តម ខៀវ កាញារិទ្ធ | ខេត្តកំពង់ចាម |
| ៤ | ឯកឧត្តម អ៊ី សំអុល | ឯកឧត្តម ហង់ជួន ណារ៉ុន | ខេត្តកំពង់ចាម |
| ៥ | លោកជំទាវ ស្រី គឹមឆយ | ឯកឧត្តម វ៉េង សាខុន | ខេត្តកំពង់ចាម |

| | | | |
|---|---|---|---|
| ៦ | លោកជំទាវ ខុង ស៊ុនអេង | ឯកឧត្តម ប៉ាន សូរស័ក្តិ | ខេត្តកំពង់ចាម |
| ៧ | លោកជំទាវ កុល ផារិន | ឯកឧត្តម លូ គឹមឈន់ | ខេត្តកំពង់ចាម |
| ៨ | លោកជំទាវ កែ ច័ន្ទមុនី | ឯកឧត្តម អ៊ុក រ៉ាប៊ុន | ខេត្តកំពង់ឆ្នាំង |
| ៩ | ឯកឧត្តម ខួង ស្រ៊ាង | ឯកឧត្តម ត្រាំ អ៊ីវតឹក | ខេត្តកំពង់ឆ្នាំង |
| ១០ | ឯកឧត្តម អ៊ូ សំអូន | ឯកឧត្តម ឆាយ ថន | ខេត្តកំពង់ស្ពឺ |
| ១១ | ឯកឧត្តម សំ រិទ្ធី | លោកជំទាវ ខេង សំដារ៉ា | ខេត្តកំពង់ស្ពឺ |
| ១២ | ឯកឧត្តម តុង សេង | ឯកឧត្តម រិន វារៈ | ខេត្តកំពង់ស្ពឺ |
| ១៣ | លោកជំទាវ លឹម ផល្លា | ឯកឧត្តម ថោង ខុន | ខេត្តកំពង់ធំ |
| ១៤ | ឯកឧត្តម ង៉ោ សុវណ្ណ | ឯកឧត្តម លឹម គានហោ | ខេត្តកណ្តាល |
| ១៥ | ឯកឧត្តម អ៊ុក ដាមរី | ឯកឧត្តម ស៊ុន ចាន់ថុល | ខេត្តកណ្តាល |
| ១៦ | ឯកឧត្តម សុះ មុះសិន | ឯកឧត្តម សុខ ចិន្តាសោភា | ខេត្តកណ្តាល |
| ១៧ | ឯកឧត្តម ជីម សុខុន | ឯកឧត្តម វង្សី វិស្សុត | ខេត្តកណ្តាល |
| ១៨ | ឯកឧត្តម ទី សុគន្ធ | ឯកឧត្តម ហ្សាការីយ៉ា អាដាម | ខេត្តកណ្តាល |
| ១៩ | លោកជំទាវ ស៊ុន សាភឿន | ឯកឧត្តម ពេជ្រ ប៊ុនធិន | ខេត្តក្រចេះ |
| ២០ | ឯកឧត្តម សួន រិនឌី | ឯកឧត្តម អ៊ិត សំហេង | រាជធានីភ្នំពេញ |
| ២១ | ឯកឧត្តម ឃុត ចាន់ដារ៉ា | ឯកឧត្តម ម៉ម ប៊ុនហេង | រាជធានីភ្នំពេញ |
| ២២ | ឯកឧត្តម ម៉ក់ វណ្ណស៊ីថា | លោកជំទាវ អ៊ឹង កន្ថាផាវី | រាជធានីភ្នំពេញ |
| ២៣ | លោកជំទាវ ម៉ាណ ណាវី | ឯកឧត្តម អូស្មាន ហាស្សាន់ | រាជធានីភ្នំពេញ |
| ២៤ | ឯកឧត្តម ជាម ប៉េអា | ឯកឧត្តម ព្រុំ សុខា | ខេត្តព្រៃវែង |
| ២៥ | ឯកឧត្តម ទេព សាម៉ន | ឯកឧត្តម ស សុខ | ខេត្តព្រៃវែង |
| ២៦ | ឯកឧត្តម ពេជ្រ ជីវ័ន | ឯកឧត្តម ញឹម វណ្ណដា | ខេត្តព្រៃវែង |
| ២៧ | ឯកឧត្តម ថោង វរលក្ខណ៍ | ឯកឧត្តម ហ៊ី បាវី | ខេត្តព្រៃវែង |
| ២៨ | ឯកឧត្តម ខៀវ ភារិទ្ធ | ឯកឧត្តម ស្បោង សារ៉ាត | ខេត្តព្រៃវែង |
| ២៩ | ឯកឧត្តម សារី កោសល្យ | ឯកឧត្តម ស៊ុយ សែម | ខេត្តពោធិ៍សាត់ |
| ៣០ | ឯកឧត្តម រ៉ូហ្វី អូស្មាន | ឯកឧត្តម កែវ រតនៈ | ខេត្តពោធិ៍សាត់ |
| ៣១ | ឯកឧត្តម ខូយ សុខា | ឯកឧត្តម ទី នរិន្ទ | ខេត្តពោធិ៍សាត់ |
| ៣២ | ឯកឧត្តម នេន ម៉ាល័យ | ឯកឧត្តម ប៉ុល សារឿន | ខេត្តព្រះសីហនុ |
| ៣៣ | ឯកឧត្តម តាក វណ្ណថា | ឯកឧត្តម គឹម ស៊ីថន | ខេត្តព្រះសីហនុ |
| ៣៤ | ឯកឧត្តម អ៊ិត សុខ | ឯកឧត្តម សុខ ផេង | ខេត្តតាកែវ |
| ៣៥ | ឯកឧត្តម ងួន បឿន | ឯកឧត្តម ចម ប្រសិទ្ធ | ខេត្តកែប |

| | | | | | |
|---|---|---|---|---|---|
| ៣៦ | ឯកឧត្តម | នៅ សំ | ឯកឧត្តម | គន់ គីម | ខេត្តឧត្តរមានជ័យ |
| ៣៧ | ឯកឧត្តម | យិន ប៊ុនណាង | ឯកឧត្តម | វង សូត | ខេត្តត្បូងឃ្មុំ |
| ៣៨ | ឯកឧត្តម | សន សារ៉ាណា | ឯកឧត្តម | សាយ សំអាល់ | ខេត្តត្បូងឃ្មុំ |

ការកោះហៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មកឆ្លើយបំភ្លឺចំនួន១លើក។ រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ ឯកឧត្តម **អង្គវង្ស វឌ្ឍនា** ត្រូវបានគណៈកម្មការជំនាញទី៦ (គណៈកម្មការនីតិកម្ម និងយុត្តិធម៌) កោះហៅសាកសួរកាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៩ អំពីការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៦ តើក្រសួងយុត្តិធម៌មានផែនការសកម្មភាពបែបណាខ្លះទាក់ទិនកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដូចជា ការកសាងហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន មានសាលាដំបូងខេត្ត រាជធានី សាលាឧទ្ធរណ៍ និងទិសដៅក្នុងការបង្កើតសាលាដំបូងខេត្តកែប ការផ្តល់ជំនួយផ្នែកច្បាប់ និងយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ រហូតមកទាល់ពេលនេះបានរៀបចំបង្កើតគ្រប់ខេត្ត ក្រុង រាជធានីហើយឬនៅ? ប្រសិនបើនៅតើមានខេត្តណាខ្លះ? អំពីការការបណ្តុះធនធានមនុស្ស តើការពង្រឹងសមត្ថភាពជំនាញដល់មន្ត្រីតុលាការ អយ្យការ និងការលើកកំពស់វិស័យយុត្តិធម៌ និងច្បាប់ពាក់ព័ន្ធ ដើម្បីជំរុញការដោះស្រាយ និងការពង្រឹងយុត្តិធម៌ជូនប្រជាពលរដ្ឋឲ្យសមស្របនឹងពេលវេលវេលា តាមនីតិវិធីដែលបានកំណត់នៅក្នុងច្បាប់កិច្ចដំណើរការរបស់តុលាកា អយ្យការ នៅតាមបណ្តាខេត្ត រាជធានី និងការបំពេញតួនាទីរបស់ខ្លួនបានហើយឬនៅ ពិសេសការពង្រឹងសមត្ថភាពជំនាញដល់មន្ត្រីតុលាការ អយ្យការតុលាការ? តើមានផែនការបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ដើម្បីបំពេញមុខងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាពបែបណា?

## ១.១. ការបញ្ចេញមតិយោបល់ជាបរិមាណរបស់សមាជិកសភាស្ត្រីនៅក្នុងពេលប្រជុំពេញអង្គរដ្ឋសភា

តារាងទី១ ៖ ចំនួន និងភាគរយតំណាងរាស្ត្រស្ត្រី ឡើងបញ្ចេញមតិធៀបនឹងតំណាងរាស្ត្របុរស

| ចំនួនតំណាងរាស្ត្រ ក្នុងគណបក្សប្រជាជនកម្ពុជា | | | ចំនួនតំណាងរាស្ត្រ បានឡើងបញ្ចេញមតិតាមភេទ | | |
|---|---|---|---|---|---|
| ១២៥នាក់ | | | ១២នាក់ | | |
| ស្ត្រី | ២៦នាក់ | ២០,៨០% | ស្ត្រី | ០១នាក់ | ៣,៨៥% |
| បុរស | ៩៩នាក់ | ៧៩,២០% | បុរស | ១១នាក់ | ១១,១១% |

ការឡើងបញ្ចេញមតិរបស់អ្នកតំណាងរាស្ត្រគិតជាបរិមាណសរុបចំនួន**១២នាក់** ក្នុងសម័យប្រជុំពេញអង្គរដ្ឋសភាសម្រាប់របាយការណ៍ឆ្នាំទី១នៃនីតិកាលទី៦នេះ ក្នុងនោះ តំណាងរាស្ត្រស្ត្រីមានចំនួន **១នាក់** ស្មើនឹង **៣,៨៤%** នៃតំណាងរាស្ត្រស្ត្រីសរុប**២៦នាក់**។ តំណាងរាស្ត្របុរសមានចំនួន **១១នាក់** ស្មើនឹង **១១,១១%** នៃតំណាងរាស្ត្របុរសសរុប **៩៩នាក់**។ ចំនួននៃការឡើងបញ្ចេញមតិនេះ គឺមានកម្រិតទាបបំផុត **៩,៦០%**បើធៀបនឹងចំនួនអ្នកតំណាងរាស្ត្រសរុប **១២៥នាក់**។

## ១ .២. គុណភាពមតិពិភាក្សារបស់អ្នកតំណាងរាស្ត្រស្ត្រី

ខ្លឹមសារមតិរបស់អ្នកតំណាងរាស្ត្រដែលបានបញ្ចេញនៅក្នុងអំឡុងពេលប្រជុំពេញអង្គ ត្រូវបានវិភាគដោយបែងចែកជា**បីសូរ (Tone)** គឺ៖ **អព្យាក្រឹត្យ វិជ្ជមាន** និង**អវិជ្ជមាន** ចំពោះស្ថាប័ន របៀបវារៈ ឬតួអង្គ/ស្ថាប័នរដ្ឋាភិបាលណាមួយដែលអ្នកតំណាងរាស្ត្រនិយាយសំដៅទៅ។

- .ខ្លឹមសារ**អព្យាក្រឹត្យ** គឺសំដៅលើមតិធម្មតាទៅលើតួអង្គ ឬស្ថាប័នណាមួយ។
- **.ខ្លឹមសារវិជ្ជមាន** គឺផ្តោតលើការលើកសរសើរពីគុណសម្បត្តិសេចក្តីព្រាងច្បាប់គោលនយោបាយ ឬតួអង្គ ឬស្ថាប័នណាមួយ។
- **.ខ្លឹមសារអវិជ្ជមាន** គឺនិយាយពីគុណវិបត្តិរបស់តួអង្គ ឬស្ថាប័នណាមួយ។

តារាងទី២ ៖ ការបង្ហាញពីអ្នកតំណាងរាស្ត្រស្ត្រីឡើងបញ្ចេញមតិ

| ល.រ | ឈ្មោះ តំណាងរាស្ត្រស្ត្រី | គណបក្ស | ចំនួនឡើងបញ្ចេញមតិ | ការបញ្ចេញមតិក្នុងន័យ (គិតជានាទី) | | | ចំនួននាទីឡើងបញ្ចេញមតិសរុប |
|---|---|---|---|---|---|---|---|
| | | | | អព្យាក្រឹត្យ | វិជ្ជមាន | អវិជ្ជមាន | |
| ១ | ឡោក ខេង | ប្រជាជនកម្ពុជា | ១ | ០ | ៧ | ០ | ៧ |
| សរុប | | | ១ | ០ | ៧ | ០ | ៧ |

តារាងខាងលើបង្ហាញថា អ្នកតំណាងរាស្ត្រស្ត្រីចំនួន១នាក់ដែលបានឡើងបញ្ចេញមតិមានចំនួន១ដងចំណាយពេលសរុបអស់៧នាទី។ ការបញ្ចេញមតិក្នុងន័យ**វិជ្ជមាន** ដោយផ្តោតទៅលើការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩។ ***លោកជំទាវ ឡោក ខេង*** *បង្ហាញពីការគាំទ្រច្បាប់នេះដែលបាននាំផលប្រយោជន៍ជូនប្រជាពលរដ្ឋ និងធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនទៅ*

*មុខយ៉ាងលឿន ព្រមទាំងគាំទ្រសមិទ្ធផល កិច្ចខិតខំប្រឹងប្រែងពាក់ព័ន្ធនឹងការកសាង និងការជួយឧបត្ថម្ភផ្សេងៗដល់ប្រជាពលរដ្ឋ។*

### ១.៣. មតិយោបល់របស់តំណាងរាស្ត្រស្ត្រី និងបុរសដែលបានលើកឡើងទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ

មិនខុសពីនីតិកាលមុន ការសង្កេតបង្ហាញឲ្យឃើញថា ក្នុងឆ្នាំទី១នៃនីតិកាលទី៦នេះ **បញ្ហាស្ត្រី និងកុមារ** មិនត្រូវបានលើកយកមកដាក់ក្នុងរបៀបវារៈនៃកិច្ចប្រជុំទេ។ បន្ថែមទៅលើនោះទៀត រាល់កិច្ចពិភាក្សាពុំបានឆ្លុះបញ្ចាំងពីផលប្រយោជន៍ និងផលប៉ះពាល់ដល់ស្ត្រី និងកុមារទេ នេះរួមទាំងអ្នកតំណាងរាស្ត្រស្ត្រីទាំងបុរសផងដែរ។ លើសពីនេះទៀត ពួកគាត់ក៏មិនបានលើកឡើងអំពីស្ត្រី និងកុមារដែលបាន និងកំពុងរងគ្រោះនូវគ្រប់ទម្រង់នៃការរើសអើង និងការរំលោភបំពាន ជាពិសេសកើតចេញពីផែនការអភិវឌ្ឍន៍ ទោះបីជាគណបក្សជាប់ឆ្នោតបានសន្យាថា នឹងដោះស្រាយបញ្ហាស្ត្រី និងកុមារនៅក្នុងកម្មវិធីនយោបាយរបស់ខ្លួនក៏ដោយ។

នេះបង្ហាញឲ្យឃើញថា ការដោះស្រាយបញ្ហាស្ត្រី និងកុមារ ពុំបានស្ថិតនៅក្នុងការចាប់អារម្មណ៍ និងយកចិត្តទុកដាក់របស់អ្នកតំណាងរាស្ត្រឡើយ ហើយក៏ជាប្រធានបទដែលស្ថិតក្នុងការតម្កល់ទុកលើធ្នើចោលផងដែរ ថ្វីបើប្រជាពលរដ្ឋស្ត្រីមានចំនួនប្រមាណ**៥៣%** និងចំនួនកុមារមានប្រមាណ**៧០%**នៃប្រជាពលរដ្ឋសរុបក៏ដោយ។

## ២. សកម្មភាពរបស់អ្នកតំណាងរាស្ត្រស្ត្រីចុះមូលដ្ឋាន

<u>តារាងទី៣</u> ៖ ចំនួន និងគោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រទាំងស្ត្រី និងបុរស

| គោលបំណងនៃការចុះមូលដ្ឋានទាំង១១៥៦លើក របស់អ្នកតំណាងរាស្ត្រទាំងស្ត្រី-បុរសចំនួន៦៤នាក់ | គណបក្សនយោបាយ | | សរុប |
|---|---|---|---|
| | ស្ត្រី ១៤នាក់ | បុរស ៥០នាក់ | ៦៤នាក់ |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋ | ០ លើក | ៨ លើក | **៨ លើក ០.៦៩%** |
| ជួបសំណេះសំណាលសាកសួរសុខទុក្ខ និងចែកអំណោយ និងសម្ពោធសមិទ្ធិផលនានា | ១៧៣ លើក | ៦២៣ លើក | **៧៩៦ លើក ៦៨.៨៥%** |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស | ៣៥ លើក | ១១៩ លើក | **១៥៤ លើក ១៣.៣២ %** |

| | | | |
|---|---|---|---|
| ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិល | ០ លើក | ០ លើក | **០លើក ០ %** |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ២១ លើក | ១៧៧ លើក | **១៩៨ លើក ១៧.១២%** |
| **សរុបរួម** | **២២៩ លើក ១៩.៨០%** | **៩២៧ លើក ៨០.១៩%** | **១១៥៦ លើក ១០០%** |

តាមទិន្នន័យដែលអ្នកសង្កេតការណ៍ខុមហ្វ្រែលទទួលបានអំពី សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ តាមរយៈបណ្តាញទំនាក់ទំនងសង្គមរបស់អ្នកតំណាងរាស្ត្រ បង្ហាញថា ក្នុងរយៈពេលចាប់ពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែសីហា ឆ្នាំ២០១៩ មានតំណាងរាស្ត្រចំនួន**៦៤នាក់** ក្នុងនោះមាន**ស្ត្រី ចំនួន ១៤នាក់** ក្នុងចំណោមតំណាងរាស្ត្រ**១២៥នាក់**នៃគណបក្សប្រជាជនកម្ពុជា បានចុះមូលដ្ឋានសរុបចំនួន**១១៥៦លើក**។ បើប្រៀបធៀបនឹងនីតិកាលទី៥ដែលមានពីរគណបក្សនយោបាយនៅក្នុងរដ្ឋសភា (គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិកម្ពុជា) សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រសម្រាប់នីតិកាលទី៦ ឆ្នាំទី១នេះ គឺមានការ**ថយចុះ**ចំនួន **៥០៩លើក** ពី **១៦៦៥លើក** នីតិកាលទី៥ ឆ្នាំ២០១៦[5] មកត្រឹម **១១៦៥លើក** នីតិកាលទី៦ ក្នុងឆ្នាំទី១ដែលមានគណបក្សប្រជាជនកម្ពុជាតែមួយគត់មានអាសនៈនៅក្នុងរដ្ឋសភា ។

គ្រប់សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ គឺបានធ្វើឡើងតែក្នុងគោលបំណងសំខាន់ចំនួន**៤**ប៉ុណ្ណោះក្នុងចំណោមគោលបំណងសំខាន់ៗចំនួន**៥** រួមមាន*(១).ការជួបសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយជូនប្រជាពលរដ្ឋ និងសម្ពោធសមិទ្ធិផលនានា។ (២).ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស។ (៣).ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ។ (៤).ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការស៊ីវិល និង(៥).ការចុះជួយអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។*

គោលបំណងសំខាន់ចំនួន**៤** នៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ បង្ហាញថា *ការជួបសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយជូនប្រជាពលរដ្ឋ និងសម្ពោធសមិទ្ធិផលនានា*មានចំនួនដល់ទៅ***៧៩៦លើក (៦៨,៨៥%)*** ជាតួលេខខ្ពស់ជាងគេបំផុត ខណៈដែល*ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ មានចំនួន* ***១៩៨លើក (១៧,១២%)*** និង *ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សមានចំនួន* ***១៥៤លើក (១៣,៣២%)*** ជាតួលេខខ្ពស់បន្ទាប់ ។ ផ្ទុយទៅវិញ ការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋ គឺមានកម្រិតទាបបំផុតចំនួនតែ **៨លើក** (០,៦៩%)។ *រីឯ ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិល* ពុំមានអ្នកតំណាងរាស្ត្រណាម្នាក់យកចិត្តទុកដាក់ចូលរួមឡើយ។

[5] របាយការណ៍ខុមហ្វ្រែល ឃ្លាំមើលយេនឌ័រផ្នែកនយោបាយ៖ សភា និងតំណាងរាស្ត្រស្ត្រី និងស្ត្រីក្នុងដំណើរការចុះឈ្មោះបោះឆ្នោតថ្មី ឆ្នាំ២០១៦ ចេញផ្សាយនៅខែមីនា ឆ្នាំ២០១៧ (COMFREL's Website: www.comfrel.org)

## ២.១. ការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី

តារាងទី៤ ៖ ចំនួន និងគោលបំណងនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រស្ត្រី

| **គោលបំណង នៃការចុះមូលដ្ឋានទាំង២២៩លើក របស់អ្នកតំណាងរាស្ត្រស្ត្រីចំនួន១៤នាក់** | **គណបក្សនយោបាយ** | |
|---|---|---|
| | **ស្ត្រី ១៤នាក់** | **ភាគរយ** |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋ | 0 លើក | 0 |
| ជួបសំណេះសំណាលសាកសួរសុខទុក្ខ និងចែកអំណោយ និងសម្ពោធសមិទ្ធិផលនានា | ១៧៣ លើក | ៧៥,៥៥% |
| ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្ស | ៣៥ លើក | ១៥,២៨% |
| ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិល | 0 លើក | 0 |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ២១ លើក | ៩,១៧% |
| **សរុបរួម** | **២២៩ លើក** | **១០០%** |

ក្នុងរយៈពេលនេះ អ្នកតំណាងរាស្ត្រស្ត្រីទាំង១៤នាក់មកពីគណបក្សប្រជាជនកម្ពុជាតែមួយគត់ដែលមានអាសនៈនៅក្នុងរដ្ឋសភា បានធ្វើសកម្មភាពនៅមូលដ្ឋានសរុបចំនួន**២២៩លើក** ក្នុងនោះ *ជួបសំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានាមានចំនួន**១៧៣លើក** ដែលជាតួលេខខ្ពស់ជាងគេ។ ការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សចំនួន ៣៥លើក។ ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំមានចំនួន**២១លើក**។ ចំណែកឯ ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិល និងការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋ* គឺពុំឃើញមានអ្នកតំណាងរាស្ត្រស្ត្រីណាម្នាក់យកចិត្តទុកដាក់ចូលរួម និងដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋឡើយ។ បើប្រៀបធៀបនឹងនីតិកាលទី៥ ចំនួនសកម្មភាពនេះ បាន**ថយចុះ**ចំនួន **១១០លើក** ពី **៣៣៩លើក** នីតិកាលទី៥ ឆ្នាំ២០១៦ មកត្រឹម **២២៩លើក** នីតិកាលទី៦ ក្នុងឆ្នាំ២០១៩។

បើប្រៀបធៀប ពីគោលបំណងមួយទៅគោលបំណងមួយនៃការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រស្ត្រី បង្ហាញឲ្យឃើញថា មានការ **ខុសគ្នាឆ្ងាយ** រវាងតួលេខ នៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ភោធសមិទ្ធិផលនានាដែលមានចំនួន១៧៣លើក (៧៥,៥៩%) ជាមួយនឹងការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋមានចំនួន***០លើក*** (០%)។* តួលេខនេះ នៅតែបង្ហាញយ៉ាងច្បាស់ថា សកម្មភាពនៃ*ការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ភោធសមិទ្ធិផលនានានៅតែជាសកម្មភាពអាទិភាព និងសកម្មដដែល ខណៈដែលការចុះពង្រឹងផ្ទៃក្នុង និងបណ្ដាញគណបក្សក៏ជាសកម្មភាពអាទិភាពផងដែរ។*

តារាងទី៥ ៖ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មធៀបនឹងអ្នកតំណាងរាស្ត្របុរស

| តំណាងរាស្ត្របានចុះបេសកកម្ម៦៤នាក់ | | |
|---|---|---|
| ស្ត្រី | ១៤នាក់ | ៥៣,៨៥% |
| បុរស | ៥០នាក់ | ៥០,៥០% |

***ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រស្ត្រីបានចុះបេសកកម្ម ប្រហាក់ប្រហែលនឹងភាគរយសរុបរបស់អ្នកតំណាងរាស្ត្របុរសដែលបានចុះបេសកកម្ម*** គឺ **៥៣,៨៥%** ស្មើនឹងចំនួនតំណាងរាស្ត្រស្ត្រី១៤នាក់ក្នុងចំណោមសមាជិកសភាស្ត្រី២៦នាក់ ច្រើនជាងបន្តិចភាគរយរបស់អ្នកតំណាងរាស្ត្របុរសចំនួន **៥០,៥០%** ស្មើនឹង៥០នាក់ក្នុងចំណោមសមាជិកសភាបុរស៩៩នាក់។ បើប្រៀបធៀបនឹងនីតិកាលទី៥ ភាគរយអ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្ម មានការ***ថយចុះខ្លាំង*** ពី **៨៣,៣៣%** នីតិកាលទី៥ ឆ្នាំ២០១៦ មកត្រឹម**៥៣,៨៥%** នីតិកាលទី៦ ឆ្នាំ២០១៩ ខណៈដែលភាគរយអ្នកតំណាងរាស្ត្របុរសចុះបេសកកម្មក៏មានការ***ថយចុះខ្លាំងដែរ*** គឺពី **៧៨,៧៩%** នីតិកាលទី៥ ឆ្នាំ២០១៦ មកត្រឹម **៥០,៥០ %** នីតិកាលទី៦ ឆ្នាំ២០១៩។

តារាងទី៦៖ ចំនួនចុះបេសកកម្មនៃអ្នកតំណាងរាស្ត្រស្ត្រីម្នាក់ៗ

អក្សរ គោល/តំណាង គោលបំណងនៃបេសកកម្មទាំង៥គឺ៖
(ក) ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋ
(ខ) ជួបសំណេះសំណាលសាកសួរសុខទុក្ខ និងចែកអំណោយ និងសម្ភោធសមិទ្ធិផលនានា
(គ) ការចុះពង្រឹងផ្ទៃក្នុង និងបណ្ដាញគណបក្ស
(ឃ) ការចូលរួមក្នុងវេទិកាសាធារណៈរបស់អង្គការសង្គមស៊ីវិល
(ង) ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ

| ល.រ | ឈ្មោះតំណាងរាស្ត្រស្ត្រី | គណបក្ស | គោលបំណងនៃបេសកកម្ម | | | | | |
|---|---|---|---|---|---|---|---|---|
| | | | (ក) | (ខ) | (គ) | (ឃ) | (ង) | សរុប |
| ១ | ម៉ែន សំអន | ប្រជាជនកម្ពុជា | ០ | ៣៨ | ១០ | ០ | ១០ | ៥៨ |
| ២ | បាន ស្រីមុំ | ប្រជាជនកម្ពុជា | ០ | ៤៥ | ២ | ០ | ៥ | ៥២ |
| ៣ | ឡោក ខេង | ប្រជាជនកម្ពុជា | ០ | ៣៣ | ៣ | ០ | ២ | ៣៨ |
| ៤ | កុប ម៉ារីយ៉ាស | ប្រជាជនកម្ពុជា | ០ | ១០ | ២ | ០ | ១ | ១៣ |
| ៥ | ឃួន សុដារី | ប្រជាជនកម្ពុជា | ០ | ៤ | ៨ | ០ | ១ | ១៣ |
| ៦ | និន សាផុន | ប្រជាជនកម្ពុជា | ០ | ១២ | ០ | ០ | ០ | ១២ |
| ៧ | នួម សោភ័ណ្ឌ | ប្រជាជនកម្ពុជា | ០ | ៨ | ០ | ០ | ២ | ១០ |
| ៨ | ពៅ សុភាព | ប្រជាជនកម្ពុជា | ០ | ៨ | ១ | ០ | ០ | ៩ |
| ៩ | កែ ច័ន្ទមុនី | ប្រជាជនកម្ពុជា | ០ | ៧ | ១ | ០ | ០ | ៨ |
| ១០ | ស៊ុន សាភឿន | ប្រជាជនកម្ពុជា | ០ | ៣ | ៤ | ០ | ០ | ៧ |
| ១១ | ត្រឹង ថារី | ប្រជាជនកម្ពុជា | ០ | ១ | ៤ | ០ | ០ | ៥ |
| ១២ | ខុង ស៊ុនអេង | ប្រជាជនកម្ពុជា | ០ | ២ | ០ | ០ | ០ | ២ |
| ១៣ | ស្រី គឹមឆយ | ប្រជាជនកម្ពុជា | ០ | ១ | ០ | ០ | ០ | ១ |
| ១៤ | គ្រួច សំអាន | ប្រជាជនកម្ពុជា | ០ | ១ | ០ | ០ | ០ | ១ |
| សរុប | | | ០ | ១៧៣ | ៣៥ | ០ | ២១ | ២២៩ |

តារាងទី៦ បង្ហាញថា តំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្ម**ច្រើនជាងគេបំផុត** នៅក្នុងឆ្នាំទី១ នីតិកាលទី៦នេះ គឺ **លោកជំទាវ ម៉ែន សំអន** តំណាងរាស្ត្រមណ្ឌលខេត្តស្វាយរៀងមានចំនួន **៥៨លើក គឺមានការកើនឡើងជិត៤ដង** បើធៀបនឹងនីតិកាលទី៥ ឆ្នាំ២០១៦ មានចំនួនតែ **១៥លើក**។ អ្នកដែល**ច្រើនបន្ទាប់** គឺ **លោកជំទាវ បាន ស្រីមុំ** តំណាងរាស្ត្រមណ្ឌលខេត្តប៉ៃលិន មានចំនួន **៥២លើក គឺបានកើនឡើងខ្លាំង ១៣ដង** បើធៀបនឹងនីតិកាលទី៥ ឆ្នាំ២០១៤ មានចំនួនតែ **៤លើក**។ អ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះមូលដ្ឋាន**ច្រើនបន្ទាប់** គឺ លោក**ជំទាវ ឡោក ខេង** តំណាងរាស្ត្រមណ្ឌលរាជធានីភ្នំពេញ មានចំនួន **៣៨លើក** គឺ**ប្រហាក់ប្រហែល**នឹងនីតិកាលទី៥ ឆ្នាំ២០១៦ មានចំនួន **៣៤លើក**។ រីឯអ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មកម្រិតមធ្យម មានចំនួន៣នាក់ គឺ **លោកជំទាវ ឃួន សុដារី** តំណាងរាស្ត្រមណ្ឌលខេត្តកណ្ដាល និង**លោកជំទាវ កុប ម៉ារីយ៉ាស់** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ឆ្នាំង មានចំនួន**១៣លើក និង ១២លើក** គឺ**លោកជំទាវ និន សាផុន** តំណាងរាស្ត្រមណ្ឌលខេត្តតាកែវ។ ដោយឡែក អ្នកតំណាងរាស្ត្រស្ត្រីដែលបានចុះបេសកកម្មក្នុងកម្រិតទាប មានចំនួន**៨នាក់**។

*សកម្មភាពចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រស្ត្រី និងអ្នកតំណាងរាស្ត្រប្រុសខាងលើ គឺមិនមានបង្ហាញអំពីលទ្ធផលជាក់ស្តែងដែលបានដោះស្រាយ ឬការធ្វើអន្តរាគមន៍របស់ពួកគាត់នៅតាមមណ្ឌលនីមួយៗឡើយ។ អ្នកសង្កេតការណ៍ខុមហ្វ្រែលព្យាយាមទំនាក់ទំនងរកព័ត៌មានទាំងនេះ ប៉ុន្តែនៅតែមិនមានការឆ្លើយតបអំពីរឿងនេះ។ ចំណែកឯ ចំនួននៃការចុះបេសកកម្មរបស់អ្នកតំណាងរាស្ត្រទាំងស្ត្រី និងបុរសសម្រាប់ឆ្នាំទី១ នីតិកាលទី៦នេះ បានតែ**ពាក់កណ្តាល**នៃអាសនៈសរុប **១២៥នាក់**ក្នុងរដ្ឋសភា។*

## ៣. ការបំពេញការសន្យារបស់រដ្ឋាភិបាលទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ

<u>តារាងទី៧ ៖</u> កម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា នីតិកាលទី៦ (២០១៨-២០២៣)

| ល.រ | កម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា សម្រាប់នីតិកាលទី៦ (២០១៨-២០២៣) |
|---|---|
| ១ | អភិវឌ្ឍ និងពង្រឹងប្រព័ន្ធគាំពារសង្គមប្រកបដោយប្រសិទ្ធភាព និងចីរភាព ដែលជួយគាំពារប្រជាជនគ្រប់រូបពីហានិភ័យនានា ដោយមិនទុកឲ្យប្រជាជន ណាម្នាក់ស្ថិតនៅក្រៅប្រព័ន្ធគាំពារសង្គមឡើយ។ បន្តជំរុញអនុវត្តដោយឥតងាករេនូវ «ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០១៦-២០២៥» រៀបចំដាក់ឲ្យអនុវត្តចាប់ពីពាក់កណ្តាលឆ្នាំ២០១៩ទៅនូវកម្មវិធី ឧបត្ថម្ភស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំនៃគ្រួសារក្រីក្រ ដែលការឧបត្ថម្ភនេះនឹងធ្វើឡើងជាពដំណាក់កាល គឺ **ដំណាក់កាលទី១៖** ឧបត្ថម្ភ ៤លើក ក្នុងមួយលើក៤ម៉ឺនរៀលនៅពេលស្ត្រីមានផ្ទៃពោះទៅទទួលយក សេវាពិនិត្យផ្ទៃពោះនៅមូលដ្ឋានសុខាភិបាលរបស់រដ្ឋ។ **ដំណាក់កាលទី២៖** ឧបត្ថម្ភ២០ម៉ឺនរៀលនៅពេលស្ត្រីសម្រាលកូននៅមូលដ្ឋានសុខាភិបាលរបស់រដ្ឋ។ **ដំណាក់កាលទី៣៖** ឧបត្ថម្ភ ១០លើក ក្នុង១លើក៤ម៉ឺនរៀលនៅពេល ស្ត្រីជាម្តាយនាំទារកទៅទទួលថ្នាំបង្ការ ឬសេវាគាំពាររហូតដល់កុមារមាន អាយុ២ឆ្នាំ។ |
| ២ | បង្កើនឱកាសការងារឲ្យបានច្រើនដល់ស្ត្រី និងបង្កើនប្រាក់បៀវត្សរ៍ឲ្យបាន សមរម្យ។ |
| ៣ | កាត់បន្ថយ និងលុបបំបាត់អំពើកេងប្រវ័ញ្ច ការជួញដូរផ្លូវភេទលើស្ត្រី និង កុមារ និងបញ្ជ្រាបការយល់ដឹងអំពីសិទ្ធិយេនឌ័រ។ |

## ❐ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦នៃរដ្ឋសភា

[6]យោងតាមប្រសាសន៍របស់លោកជំទាវ **អ៊ឹង កន្ថាផាវី** ជារដ្ឋមន្ត្រីនៃក្រសួងកិច្ចការនារី ក្នុងអាណត្តិថ្មី (នីតិកាលទី៦)នេះ ក្រសួងកិច្ចការនារីនឹងបន្តផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍធនធានមនុស្សជាពិសេសផ្តោតលើជំនាញភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងវិស័យនយោបាយ វិស័យសង្គម និងវិស័យសេដ្ឋកិច្ចនៅថ្នាក់ប្រទេសក៏ដូចជានៅថ្នាក់តំបន់។

ឆ្លើយតបទៅនឹងសកលភាវូបនីយកម្ម ក្រសួងកិច្ចការនារីនឹងពង្រឹងភាពអង់អាចដល់ស្ត្រីដើម្បីមានសមត្ថភាពចូលរួមប្រកួតប្រជែង និងច្នៃប្រឌិតថ្មីនៅក្នុងទីផ្សារការងារ ក៏ដូចជាបង្កើនសមត្ថភាពរបស់ពួកគេក្នុងការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរនិងរៀនដើម្បីមានភាពជោគជ័យផ្នែកសហគ្រិន។ ការគាំទ្រស្ត្រីផ្នែកសេដ្ឋកិច្ចគឺជាកាតាលីករយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពងាយរងគ្រោះរបស់ស្ត្រី ហើយនិងពង្រឹងភាពអង់អាចរបស់ស្ត្រីក្នុងតួនាទីជាដៃគូដ៏មានតម្លៃជាមួយនឹងបុរសនៅក្នុងសង្គម។ ដើម្បីអនុវត្តការងារនេះក្រសួងកិច្ចការនារីបាន និងកំពុងសហការជាមួយក្រសួងពាក់ព័ន្ធដើម្បីបន្តអប់រំ និងផ្សព្វផ្សាយដល់ស្ត្រីអំពីព័ត៌មានដែលពាក់ព័ន្ធនឹងច្បាប់ ច្បាប់ការងារ ហើយការពារសិទ្ធិរបស់ពួកគេ រួមទាំងបន្តអនុវត្តសកម្មភាពលើកកម្ពស់ជីវភាពរស់នៅរបស់ស្ត្រីជនបទឲ្យមានជំនាញវិជ្ជាជីវៈដើម្បីប្រកបមុខរបរកសិកម្ម ឬមិនកសិកម្មឲ្យស៊ីចង្វាក់ទៅនឹងតម្រូវការទីផ្សារដែលវិវត្តន៍យ៉ាងលឿន។

ដើម្បីលើកកម្ពស់សុខុមាលភាពរបស់ស្ត្រី និងកុមារ ក្រសួងកិច្ចការនារីសហការជាមួយក្រសួងពាក់ព័ន្ធកំពុងចូលរួមអនុវត្តគោលនយោបាយថ្មីរបស់រាជរដ្ឋាភិបាល ពោលគឺគោលនយោបាយគាំពារសង្គមដោយផ្តោតអាទិភាពទៅដល់មុខសញ្ញាមួយចំនួនក្នុងនោះមានស្ត្រីដែលមានផ្ទៃពោះ និងស្ត្រីដែលមានវ័យចំណាស់។ កិច្ចគាំពារសង្គមជាមូលដ្ឋានគ្រឹះដែលធានាថាមិនមាននរណាម្នាក់ទុកចោលឲ្យនៅឯកោ ឬគ្មាននរណានៅពីក្រោយ (No one is left behind) ហើយធានាថា ស្ត្រី ក្មេងស្រី និងក្រុមងាយរងគ្រោះទទួលបានអត្ថប្រយោជន៍នៃកំណើនសេដ្ឋកិច្ចដ៏រឹងមាំរបស់ប្រទេសជាតិយើង។ តាមការស្រាវជ្រាវមួយទៀតនៅក្នុងសកលលោក បានបង្ហាញថា ក្របខ័ណ្ឌគាំពារសង្គមជាកាតាលីករក្នុងការកាត់បន្ថយវិសមភាពយេនឌ័រ ហើយនឹងធានាសំណាញ់សុវត្ថិភាពជូនក្រុមងាយរងគ្រោះ។

ដើម្បីកាត់បន្ថយអំពើហឹង្សាលើស្ត្រី និងកុមារ ក្រសួងកិច្ចការនារីបានបន្តពង្រឹងការអនុវត្តផែនការទប់ស្កាត់រាល់ទម្រង់នៃអំពើហឹង្សាលើស្ត្រី និងក្មេងស្រីឆ្នាំ២០១៩-២០២៣ និងលើកកម្ពស់សីលធម៌សង្គមឡើងវិញ ដោយយកចិត្តទុកដាក់ខ្ពស់ចំពោះការអប់រំសង្គមឲ្យមានការផ្លាស់ប្តូរផ្នត់គំនិតកុំឲ្យមានការរើសអើងចំពោះស្ត្រីភេទ ហើយផ្នត់គំនិតនៃការទទួលខុសត្រូវខ្ពស់នៃការពិសារគ្រឿងស្រវឹង និងបង្ក្រាបការប្រើប្រាស់គ្រឿងញៀនដែលមានផលប៉ះពាល់អវិជ្ជមានធំទៅលើយុវវ័យ។ ចំណែកមាតាបិតាក៏មានតួនាទីសំខាន់ផងដែរក្នុងការលើកកម្ពស់សីលធម៌សង្គម ក្រសួងនឹងពង្រីកការអនុវត្តកម្មវិធីអប់រំកូនតាមបែបវិជ្ជមាន ហើយនឹងធ្វើការងារនេះជាមួយក្រុមគ្រួសារនៅគ្រប់មជ្ឈដ្ឋាន។ ស្របជាមួយគ្នានេះ ក្រសួងនឹងបន្តពង្រឹងវប្បធម៌សន្ទនាដើម្បីដោះស្រាយជំលោះដែលអាចនាំមកនូវអំពើហឹង្សានៅក្នុងគ្រួសារ និងពង្រីកយុទ្ធនាការបុរសល្អ ដោយ

[6]shorturl.at/qzNX6

ត្រូវធានាថាបុគ្គលណាដែលប្រព្រឹត្តសកម្មភាពបទល្មើសនេះ ត្រូវតែទទួលទោសចំពោះមុខច្បាប់។ បញ្ហាមួយទៀតគឺ ការវិវត្តន៍ជឿនលឿននៃបច្ចេកវិទ្យា និងការប្រើប្រាស់របស់យុវវ័យ ដូច្នេះក្រសួងត្រូវតែបំផុសឲ្យយុវវ័យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាដោយមានការទំនួលខុសត្រូវខ្ពស់ មិនប្រាស់ចាកពីទិសដៅនៃការអប់រំ និងចំណេះដឹង។

# III. ស្ថានភាពអ្នកនយោបាយស្ត្រីកម្ពុជា

ក្នុងដំណើរការនយោបាយ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៨ សកម្មជន និងអ្នកនយោបាយស្ត្រីនៃ គណបក្សប្រឆាំងសំខាន់(គណបក្សសង្គ្រោះជាតិ)ត្រូវបានគេមិនផ្ដល់អំណាច និងរារាំងមិនឲ្យចូលរួមក្នុងដំណើរការនយោបាយ និងការបោះឆ្នោត ដោយសារតែការរំលាយគណបក្សប្រឆាំងគណបក្សសង្គ្រោះជាតិ និងការហាមប្រាមអ្នកនយោបាយស្ត្រីរបស់គណបក្សប្រឆាំងចូលរួមក្នុងការបោះឆ្នោតជាតិ ឆ្នាំ២០១៨ បរិយាកាសនៃការភ័យខ្លាច និងការរិតត្បិតសេរីភាពនៃការបញ្ចេញមតិ។ អាសនៈស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ៥៥៣នាក់ ក្នុងនោះ ៣៦នាក់ជាមេឃុំ ចៅសង្កាត់ស្ត្រី និងតំណាងរាស្ត្រចំនួន៧រូបមកពីគណបក្សសង្គ្រោះជាតិត្រូវបានដកហូត ក្រោយពីគណបក្សប្រឆាំងគណបក្សសង្គ្រោះជាតិត្រូវបានរំលាយ។ ខណៈពេលនោះដែរ ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់នៃគណបក្សសង្គ្រោះជាតិមួយចំនួនក៏បានចុះចូលជាមួយគណបក្សប្រជាជនកម្ពុជាដើម្បីរក្សាតួនាទីរបស់ខ្លួនជាក្រុមប្រឹក្សាឃុំ សង្កាត់ និងជាមេឃុំ ចៅសង្កាត់ និងមិនចង់បាត់បង់ឱកាសក្នុងការជួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ពួកគាត់។

ចន្លោះពីដើមឆ្នាំ ដល់ពាក់កណ្ដាលឆ្នាំ២០១៩ អ្នកនយោបាយស្ត្រីដែលប្រើប្រាស់សិទ្ធិនយោបាយរបស់ខ្លួន និងសិទ្ធិស្ត្រីដើម្បីចូលរួមក្នុងដំណើរការប្រជាធិបតេយ្យនៅប្រទេសកម្ពុជាត្រូវបានប្រឈមការចោទប្រកាន់តាមផ្លូវតុលាការ រួមទាំង ការរើសអើង ការឃាយី ការគំរាមកំហែង និងការរិតត្បិតពីសំណាក់អាជ្ញាធរ សូម្បីតែការជួបប្រជុំគ្នា ការពិភាក្សាគ្នាអំពីរឿងនយោបាយរបស់ពួកគាត់ក៏ត្រូវបានរំខានផងដែរ។

ជាក់ស្ដែងសកម្មភាព គំរាមកំហែង យាយី រិតត្បិតមកលើអ្នកនយោបាយស្ត្រីដូចជា៖

សារព្រមានរបស់លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដែលបាននិយាយគំរាមកំហែងទៅដល់អ្នកនយោបាយស្ត្រីប៉ុន្មានថ្ងៃមុនទិវានារីអន្តរជាតិ៨មីនា ឆ្នាំ២០១៩៖ «**ឥឡូវខ្ញុំដឹង អ្នកឯងប្រជុំពីទីក្រុងភ្នំពេញតាមឡាន Bus ទៅភ្នំតាម៉ៅ បើខ្ញុំចង់ធ្វើ ខ្ញុំចាប់លើឡានក្រុងទាំងអស់។ អ្នកនៅភ្នំពេញលោកស្រីប្រធានចលនាស្ត្រី លោកស្រីត្រូវដឹងថា លោកស្រីមិនអាចលាក់បាំងពីអ្វីរបស់យើងបានទេ អ្នកណាដូចជានៅកំពង់ចាម គេប្រជុំលើឡានBus ទៅខាងកំពង់ធំ ត្រលប់មកវិញចូលចំការលើ ដូចជាថ្ងៃនេះ ថ្ងៃស្អែកគេត្រូវប្រជុំនៅបឹងត្រកួន ស្មានតែគេមិនដឹង! សូម្បីតែប្រជុំតាមឡានក៏គេត្រូវធ្វើដែរ ឥឡូវនឹងគេកំពុងដំណើរការរៀបចំបន្តទៀត ប្រយ័ត្ននាងប្រយ័ត្ន!**»។

អតីតចៅសង្កាត់រងទី១ នៅសង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ អ្នកស្រី **និត្យ សុផាត** រៀបរាប់ថា កន្លងមកអតីតសមាជិក និងមន្ត្រីបក្សបានជួបជុំទទួលទានអាហាររួមគ្នា ប៉ុន្តែត្រូវបានអាជ្ញាធរទៅរំខានដោយមិនអនុញ្ញាតឱ្យពួកគាត់ជួបជុំគ្នាឡើយ ដោយអះអាងថា ការជួបជុំនោះជារូបភាពនយោបាយប្រឆាំងទៅនឹងសាលដីកាតុលាការកំពូលចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧។ អ្នកស្រីថា៖ « *កំពុងញ៉ាំៗ គេទៅ [អាជ្ញាធរ] យើងបំបែកគ្នាអស់ទៅ ហើយក៏គេចេញដីកាឱ្យបិទហាងហ្នឹង ហាងហ្នឹងជារបស់អតីតសមាជិកសង្គ្រោះជាតិ* »។

កញ្ញា **ស៊ិន ចាន់ពៅរ៉ូហ្សេត** អតីតចៅសង្កាត់អូចារ ខេត្តបាត់ដំបង ត្រូវបានតុលាការកោះហៅជាបន្តបន្ទាប់។ កញ្ញាបានលើកជាចម្ងល់ចំពោះការកោះហៅនោះ ដោយសារតែខ្លួនបានវិលមកជីវភាពធម្មតាវិញតាំងពីគណបក្សសង្គ្រោះជាតិត្រូវបានរំលាយ កាលពីចុងឆ្នាំ២០១៧មកម្ល៉េះ។ *កញ្ញាបានបន្ថែមថា* « ***សម្រាប់ដីកាហ្នឹងខ្ញុំដូចជាចម្លែកដែរ។ តើខ្ញុំមានសកម្មភាពទៅប្រឆាំងដីកាតុលាការកំពូលរបៀបម៉េច បើការរំលាយគណបក្សសង្គ្រោះជាតិ កាលពី ថ្ងៃទី១៦ ហើយថ្ងៃទី១៧ គឺរដ្ឋបាលក្រុងបានទៅដកហូតយកត្រាខ្ញុំ ពេលនោះខ្ញុំបានប្រគល់ត្រាឱ្យដោយសន្តិវិធីទៅទៀត នេះទីមួយ។ ទីពីរ គឺខ្ញុំបានមកប្រកបរបររកស៊ីរបស់ខ្ញុំរហូតដល់មានអ្នកមករំខាន ថាខ្ញុំបង្កើតចលនាឧទ្ទាមរហូតដល់ដាច់ភ្លៀវលែងមកទទួលទាននំបញ្ចុកហាងនាងខ្ញុំទៅហើយប្រហែល៧០ភាគរយមកដល់ថ្ងៃនេះ*** »។

ក្រុមស្ត្រីដែលជា មេឃុំ សមាជិកក្រុមប្រឹក្សាខេត្ត និងស្រុក ដែលជាប់ឆ្នោតពីខាងគណបក្សសង្គ្រោះជាតិក្នុងខេត្តកំពង់ស្ពឺ ចំនួន **៦រូប**ត្រូវបង្ខំចិត្តរត់ភៀសខ្លួនមួយរយៈ ដើម្បីសុវត្ថិភាពចៀសពីការធ្វើទុក្ខបុកម្នេញពីអាជ្ញាធររបបក្រុងភ្នំពេញ និងដើម្បីរង់ចាំឱកាសវិល ត្រឡប់ទៅបំពេញការងារបម្រើសង្គម បម្រើប្រជាពលរដ្ឋ ចូលរួមដោះស្រាយបញ្ហាស្ត្រី និងកុមារនៅក្នុងមូលដ្ឋាន។ មេឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ កញ្ញា **គឹម តុលា** ថ្លែងក្នុងវេទិកាអ្នកស្តាប់វិទ្យុអាស៊ីសេរី កាលពីយប់ថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៩ ថា ចាប់តាំងពីការរំលាយគណបក្សប្រឆាំង និងដកហូតតួនាទីជាមេឃុំមក កញ្ញាបាត់បង់ឱកាសបន្តការងារជួយដោះស្រាយបញ្ហាស្ត្រី និងកុមារក្នុងមូលដ្ឋាន។ កញ្ញាចាត់ទុកទង្វើរបស់អាជ្ញាធរនេះថា ជាការរំលោភបំពានធ្ងន់ធ្ងរដល់សិទ្ធិស្ត្រី៖ «***យ៉ាងណាក៏ដោយក៏មិនអាចទទួលយកបានដែរ ដែលគេដាក់គំនាបលើពួកខ្ញុំដែលជាស្ត្រី ជាពិសេសទៅលើស្ត្រីផ្សេងទៀតទោះជាគាត់មិនមែនជាថ្នាក់ដឹកនាំ តែក៏ជាស្ត្រីក្នុងនាមប្រជាពលរដ្ឋ***»។

សកម្មភាពរបស់រដ្ឋាភិបាល និងទង្វើរបស់អាជ្ញាធរទាំងនេះជាការប្រព្រឹត្តិផ្ទុយនឹងអនុសញ្ញាស៊ី-ដ «***ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ***» មាត្រា៣ចែងថា « *ក្នុងគ្រប់វិស័យ ជាពិសេសវិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផងដើម្បីធានាការអភិវឌ្ឍន៍ និងការរីកចំរើនពេញលេញរបស់ស្ត្រី ដើម្បីធានាឲ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដោយសមភាពជាមួយបុរស* »។ *និងមាត្រា៧ បានចែងថា « រដ្ឋភាគី ត្រូវប្រកាន់យកវិធានការសមស្រប ដើម្បីលុបបំបាត់ចោលការរើសអើងប្រឆាំងនឹងស្ត្រីក្នុងជីវភាពនយោបាយ និងសាធារណៈរបស់ប្រទេស។...* »។ ទង្វើខាងលើនេះ ក៏ជាការរំលោភបំពានមកលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានការពារសិទ្ធិសេរីភាពបញ្ចេញមតិ និងការជួបប្រជុំដែលមានចែងក្នុងមាត្រា៤១ « *ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។...*» និងបានរំលោភបំពានយ៉ាងខ្លាំងចំពោះកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៩ កថាខណ្ឌ២ ចែងថា « *ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។...*»។ បន្ថែមពីលើនេះ បើទោះបីស្ត្រីមួយចំនួនអាចមិនមានការភ័យខ្លាច ឬបាក់ស្មារតីទៅនឹងការគំរាមកំហែង ការរិតត្បិតខាងលើនេះក៏ដោយ ប៉ុន្តែសកម្មភាពនេះបានជះឥទ្ធិពលមិនល្អទៅលើស្ត្រីមួយចំនួនទៀតដែលទើបចាប់ផ្តើម អាចមានការនឿយណាយមិនចង់ចូលរួមក្នុងកិច្ចការនយោបាយ ថ្វីបើពួកគាត់

កំពុងសកម្មក៏ដោយ ព្រោះពួកគាត់យល់ថាដើរទៅមុខទៀតវាអាចរងសម្ពាធខ្លាំង។ ដូច្នេះ វាបានប៉ះពាល់ និងបន្ថយបង្អាក់ទៅដល់សកម្មភាពរបស់ស្ត្រីចូលរួមដោយសកម្មក្នុងកិច្ចការនយោបាយ និងវាបានប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានកាតព្វកិច្ចជម្រុញការអនុវត្តដោយប្រសិទ្ធភាពនៃរដ្ឋធម្មនុញ្ញ និងអនុសញ្ញាអន្តរជាតិមួយចំនួនដែលកម្ពុជាបានទទួលយកក្នុងការគាំទ្រ និងលើកកម្ពស់ការចូលរួមដោយស្មើភាពរបស់ស្ត្រីលើគ្រប់វិស័យ ជាពិសេស វិស័យនយោបាយ ទាំងចំនួន សម្លេង សិទ្ធិអំណាច និងសកម្មភាព។

ដូច្នេះ រាជរដ្ឋាភិបាលត្រូវគោរពនូវសិទ្ធិនយោបាយរបស់ស្ត្រី និងធានាឲ្យបានក្នុងការអនុវត្តសិទ្ធិនេះដោយបង្កលក្ខណៈងាយស្រួលដល់ស្ត្រីធ្វើការជួបជជែកគ្នាអំពីកិច្ចការនយោបាយ និងកិច្ចការផ្សេងៗ ជាពិសេសសម្រាប់ស្ត្រីដែលមកពីគណបក្សប្រឆាំង ឬគណបក្សផ្សេងទៀត ប្រយោជន៍គាំទ្រ និងផ្តល់ឱកាសដល់ស្ត្រីចូលរួមកាន់តែច្រើនក្នុងកិច្ចការនយោបាយ និងថ្នាក់សម្រេចចិត្ត ស្របតាមអនុសញ្ញាស៊ី-ដ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា។

# IV.ការសិក្សាលើក្រុមគោលដៅស្ដីពី ការផ្ដល់អំណាចឱ្យស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែល

ក្នុងតំបន់គោលដៅរបស់ខុមហ្វ្រែលចំនួន **៥ខេត្ត** ដូចជា ខេត្តត្បូងឃ្មុំ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តតាកែវ និងខេត្តព្រះវិហារ បច្ចុប្បន្នមានស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន **៤៩៦នាក់ (១៩,០៤%)** ក្នុងចំណោម **២៦០៤នាក់**។ ជនបង្គោលស្ត្រីមូលដ្ឋាននៃខុមហ្វ្រែល (CFLFP)ចំនួន**១៩នាក់**ដែលជាអ្នកសង្កេតការណ៍ស្ត្រីត្រូវបានដាក់ពង្រាយនៅតំបន់គោលដៅខាងលើ ដោយផ្ដោតលើស្រុក ខ័ណ្ឌចំនួន**១១** និងឃុំ សង្កាត់ចំនួន **១៩** ដើម្បីសង្កេត ឃ្លាំមើលលើស្ថានភាព និងដំណើរការអនុវត្តកិច្ចការងារតាមតួនាទី ភារកិច្ចរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិទី៤ ឆ្នាំ២០១៩ និងធ្វើការជួបសម្ភាសន៍ផ្ទាល់ជាមួយស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន**៣៦នាក់** ព្រមទាំងធ្វើករណីសិក្សាផងដែរ។

## ១- ព័ត៌មានទូទៅទាក់ទងនឹងការចូលរួមនយោបាយរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់

### ១.១. ព័ត៌មានទូទៅរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់

ក្នុងចំណោមស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៣៦នាក់ គឺមានអាយុ ស្ថានភាពគ្រួសារ និងមកពីប្រភពខុសៗគ្នា ក្នុងនោះស្ត្រីវ័យក្មេងអាយុចន្លោះពី២៥ឆ្នាំដល់៣០ឆ្នាំមានចំនួន **៧នាក់ (១៩,៤៤%)**។ ស្ត្រីក្នុងវ័យកណ្ដាលអាយុចន្លោះពី៣១ឆ្នាំដល់៤០ឆ្នាំមានចំនួន**១១នាក់ (៣០,៥៥%)**។ ស្ត្រីក្នុងបជ្ឈិមវ័យអាយុចន្លោះពី៤១ឆ្នាំដល់៥០ឆ្នាំមានចំនួន**៣នាក់ (៨,៣៣%)** និងស្ត្រីវ័យចំណាស់អាយុលើសពី៥០ឆ្នាំមានចំនួនច្រើន**១៥នាក់ (៤១,៦៦%)**។ ចំណែកឯស្ថានភាពគ្រួសាររបស់ស្ត្រីទាំងនោះ **២២នាក់**មានគ្រួសារ **៦នាក់**ជាស្ត្រីមេម៉ាយ និង**៨នាក់**នៅលីវដែលមានប្រភពមកពីសមាជិកគណបក្សនយោបាយ ជនបង្គោលឃុំ និងជំនួយការរដ្ឋបាលឃុំ។ តួលេខឆ្នាំ២០១៩នេះ(អាណត្តិទី៤)ប្រហាក់ប្រហែលនឹងតួលេខឆ្នាំ២០១៥ (អាណត្តិទី៣)ដែរ គឺនៅតែបង្ហាញឲ្យឃើញថា ស្ត្រីវ័យក្មេងមានតួនាទីជាក្រុមប្រឹក្សាឃុំ សង្កាត់មានចំនួនតិចតួច ខណៈដែលស្ត្រីវ័យចំណាស់ និងស្ត្រីវ័យកណ្ដាលនៅតែមានវត្តមានច្រើន និងបង្ហាញអំពីទំនាក់ទំនងយ៉ាងខ្លាំងក្នុងការភ្ជាប់ខ្លួនចូលរួមក្នុងកិច្ចការនយោបាយ និងការចូលជាសមាជិកគណបក្សនយោបាយ ព្រមទាំងបង្ហាញពីឆន្ទៈមោះមុតក្នុងការធ្វើឲ្យខ្លួនក្លាយជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។

**ក្រាហ្វិកទី១ ៖**




## ១.២. ចំនួនអាណត្តិរបស់ស្ត្រីជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់

ក្នុងចំណោមស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ទាំង**៣៦នាក់** មាន**១០នាក់**ដែលទើបតែជាប់ឆ្នោតជាសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ នៅអាណត្តិទី៤ (១អាណត្តិ)។ **១៨នាក់**បានធ្វើជាសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន២អាណត្តិខុសៗគ្នា ( អាណត្តិទី១ និងទី៤ចំនួន៥នាក់។ **៧នាក់**ក្នុងអាណត្តិទី២ និងទី៤ និង៦នាក់ក្នុងអាណត្តិទី៣ និងទី៤) និង**១០នាក់**បានធ្វើជាសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៤អាណត្តិ។ តួលេខបញ្ជាក់ឲ្យឃើញថា ស្ត្រីភាគច្រើនមិនអាចមានឱកាសបានធ្វើជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំង៤អាណត្តិឡើយ ទោះបីពួកគេខិតខំប្រឹងប្រែង និងមានបទពិសោធយ៉ាងណាក៏ដោយ ហើយកាន់តែមានឱកាសតិចតួចទៅទៀតចំពោះស្ត្រីដែលនឹងត្រូវជាប់ឆ្នោតថ្មីជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់។នេះអាចមកពីខ្វះការយកចិត្តទុកដាក់ពីប្រធានគណបក្សនៅថ្នាក់ក្រោមជាតិ(ខេត្ត ស្រុក ឃុំ) ជាពិសេសប្រធានគណបក្សនៅថ្នាក់ឃុំ សង្កាត់ដែលភាគច្រើនជាបុរសមានតួនាទីជាមេឃុំ ចៅសង្កាត់បុរស និងខ្វះនូវគោលនយោបាយលើកស្ទួយស្ត្រីនៅក្នុងគណបក្សរបស់ខ្លួនផងដែរ។

## ក្រាហ្វិកទី២ ៖




## ១.៣. តួនាទីរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់

## ក្រាហ្វិកទី៣ ៖



ក្នុងចំណោមសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់**៣៦នាក់** មាន១នាក់មានតួនាទីជាប្រធានក្រុមប្រឹក្សាឃុំ និងជាមេឃុំ។ ២នាក់មានតួនាទីជាជំទប់ទី១ ៣នាក់មានតួនាទីជាជំទប់ទី២ និង២២នាក់មានតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ ក្នុងនោះភាគច្រើនទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ។ ចំណែកឯ៨នាក់ផ្សេងទៀតជាជំនួយការរដ្ឋបាលឃុំ និងជាជនបង្គោលឃុំ។ តួលេខបង្ហាញយ៉ាងច្បាស់ថាស្ត្រីនៅតែមានឱកាសតិចតួចក្នុងការទទួលបានតួនាទីជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬជាមេឃុំ ចៅសង្កាត់ ខណៈដែលភាគច្រើនលើសលុបគ្រាន់តែជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ធម្មតាប៉ុណ្ណោះ។

## ១.៤. មូលហេតុនៃការចូលប្រឡូកក្នុងកិច្ចការនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់

### ក្រាហ្វិកទី៤៖




សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ទាំង**៣៦នាក់** បានបង្ហាញពីមូលហេតុដែលពួកគាត់ចូលប្រឡូកក្នុងកិច្ចការនយោបាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ មានសរុប**១១២ចម្លើយ** ក្នុងនោះ**៣១ចម្លើយ**បង្ហាញថា ចង់ជួយសង្គមដោយផ្ទាល់ និង**៣១ចម្លើយ**ទៀតបង្ហាញថា ចង់លើកកម្ពស់ស្ត្រី និង**៣១ចម្លើយ**ផ្សេងទៀតចង់ការពារផលប្រយោជន៍ស្ត្រី និងកុមារ ដែលជាតួលេខនាំមុខគេ **១២ចម្លើយ**គិតពីអនាគតកូនចៅ និង**៧ចម្លើយ**គិតពីជីវភាពគ្រួសារប្រចាំថ្ងៃ។ ទោះបីចម្លើយមានផ្សេងៗគ្នាខ្លះក៏ដោយ ក៏ស្ត្រីទាំងអស់មានការប្តេជ្ញាចិត្តខ្ពស់ចូលរួមក្នុងកិច្ចការនយោបាយ និងចូលរួមដឹកនាំនៅថ្នាក់មូលដ្ឋាន ក្នុងគោលបំណងចូលរួមអភិវឌ្ឍន៍សង្គមជាតិ

ដូចគ្នា ជាពិសេសយកចិត្តទុកដាក់លើការដោះស្រាយបញ្ហាស្ត្រី និងកុមារ និងចង់លើកស្ទួយស្ថានភាពស្ត្រីឲ្យមានភាពប្រសើរឡើង។

# ២. ស្ថានភាពស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការបំពេញកិច្ចការនៅថ្នាក់មូលដ្ឋាន

## ២.១. ការរើសអើងស្ត្រី

### ២.១.១. អារម្មណ៍របស់អ្នកជិតខាង អ្នកស្គាល់ មិត្តភក្តិ និងគ្រួសារចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់

មិនខុសពីអាណត្តិមុន ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ទាំង**៣៦នាក់** បានបង្ហាញថា ពួកគាត់បានទទួលការគាំទ្រស្ទើរតែទាំងស្រុងពីក្រុមគ្រួសារ អ្នកជិតខាង អ្នកស្គាល់ និងមិត្តភក្តិ (លើកលែងតែ **១នាក់** មានការិះគន់ និង**១នាក់**ទៀតមានការមិនសប្បាយចិត្ត) ក្នុងនោះ **៣៤នាក់** បង្ហាញថាមានការអបអរសាទរពីប្រជាពលរដ្ឋចំពោះពួកគាត់ ពេញចិត្តការងាររបស់ពួកគាត់ មានសមត្ថភាពជួយធ្វើការងារប្រជាពលរដ្ឋទុកចិត្តប្រជាពលរដ្ឋពេញចិត្តឲ្យធ្វើការបន្តពីព្រោះប្រជាពលរដ្ឋអាចពឹងពាក់បាន ចង់ឲ្យមានវត្តមានស្ត្រីច្រើននៅក្នុងឃុំ សង្កាត់របស់គាត់។

នេះបង្ហាញពីការផ្លាស់ប្តូរជាវិជ្ជមាននៃផ្នត់គំនិតសង្គម ជាពិសេសប្រជាពលរដ្ឋនៅមូលដ្ឋានក្នុងការឲ្យតម្លៃ និងគាំទ្រយ៉ាងពេញទំហឹងចំពោះសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីជាអ្នកដឹកនាំ និងក្នុងវិស័យនយោបាយ ដែលជាកំលាំងជំរុញលើកទឹកចិត្តដល់ការចូលរួមរបស់ស្ត្រីកាន់តែខ្លាំង និងសកម្មថែមទៀត និងបានបង្ហាញពីសក្តានុពលរបស់ខ្លួន។

*យោងតាមសម្តីរបស់សមាជិកាក្រុមប្រឹក្សាឃុំ ៖*

◇ **លោកស្រី ខេង ផល្លា** បានមានប្រសាសន៍ថា *« អ្នកជិតខាងចូលរួមត្រេកអរជាមួយលទ្ធផលដែលខ្ញុំទទួលបាន ហើយកោតសសើរថា ខ្ញុំពិតជាស្ត្រីម្នាក់ដ៏អស្ចារ្យអាចឈានចូលទៅក្នុងដំណែងក្រុមប្រឹក្សាឃុំបាន »។*

◇ **លោកស្រី ដុំ សោភ័ណ្ឌ** បានបង្ហាញផងដែរថា *« ខ្ញុំទទួលបានការស្រលាញ់រាប់អានពីប្រជាពលរដ្ឋនៅក្នុងឃុំរបស់ខ្ញុំ រួមទាំងក្រុមប្រឹក្សាឃុំទាំងអស់ដោយពុំមានការរើសអើងស្ត្រីឡើយ។ រាល់ទុក្ខកង្វល់ ឬបញ្ហានានារបស់ប្រជាពលរដ្ឋដែលកើតមានឡើង គឺពួកខ្ញុំជាក្រុមប្រឹក្សាឃុំតែងតែរួមគ្នាដោះស្រាយទាន់ពេលវេលាជានិច្ច »។*

### ២.១.២. អាកប្បកិរិយារបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបុរសដែលបានបំពេញកិច្ចការជាមួយស្ត្រី

**ក្រាហ្វិកទី៥ ៖**




ក្នុងចំណោមស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ទាំង**៣៦នាក់** មាន**៣៥នាក់ (៩៧,២២%)**បញ្ជាក់ថា មានការគាំទ្រ និងលើកទឹកចិត្តពីបុរសក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះស្ត្រី ដោយបង្ហាញពីអារម្មណ៍សប្បាយរីករាយដែលមានស្ត្រីចូលរួមការងារជាមួយ មានទំនុកចិត្តធ្វើការជាមួយស្ត្រី ដោយចង់ឲ្យស្ត្រីច្រើនចូលរួមធ្វើការនៅក្នុងឃុំដើម្បីភាពរីកចំរើន និងចង់លើកកម្ពស់សមភាពយេនឌ័រ។ នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំក្តី កិច្ចប្រជុំឃុំក្តី បុរសក្រុមប្រឹក្សាឃុំបានទុកឱកាសឲ្យស្ត្រីបញ្ចេញមតិយោបល់បានច្រើន និងមុនសម្រេចកិច្ចការអ្វីតែងសួរយោបល់ពីស្ត្រីជាមុន។ បន្ថែមលើនេះទៀត ពេលស្ត្រីក្រុមប្រឹក្សាឃុំចុះធ្វើការតាមភូមិគឺមានការគាំទ្រ និងសហការយ៉ាងល្អពីមេភូមិផងដែរ។ ទោះបីយ៉ាងណាក៏ដោយ មានស្ត្រី១នាក់ **(២,៧៧%)**ផ្សេងទៀតបានប្រាប់ថា បុរសនៅមានការរិះគន់ចំពោះស្ត្រីនៅឡើយ។ បើប្រៀបធៀបនឹងឆ្នាំ២០១៥ ការគាំទ្រស្ត្រី ការលើកទឹកចិត្តស្ត្រី ការឲ្យតម្លៃស្ត្រី និងការសហការជាមួយស្ត្រីមានការ**កើនឡើង** ពី **៨២,៩២%** នៅឆ្នាំ២០១៥ (អាណត្តិទី៣) ឡើងដល់ **៩៧,២២%** នៅឆ្នាំ២០១៩ (អាណត្តិទី៤) ខណៈដែលការរើសអើងមានការ**ថយចុះ** គឺពី**១២,១៩%** ឆ្នាំ២០១៥ មកត្រឹម **២,៧៧%** នៅឆ្នាំ២០១៩។ តួលេខនេះ បង្ហាញថា ការរើសអើងចំពោះស្ត្រីនៅថ្នាក់មូលដ្ឋានមានការថយចុះ ខណៈដែលមានការគាំទ្រ និងលើកកម្ពស់ស្ត្រីពីបុរសក្រុមប្រឹក្សាឃុំ សង្កាត់ និងមេភូមិ ដោយបុរសទាំងនោះមានការផ្លាស់ប្តូរអាកប្បកិរិយាឲ្យតម្លៃស្ត្រី បានយល់ដឹងពីយេនឌ័រ គោរពសិទ្ធិស្ត្រី និងបានសហការល្អជាមួយស្ត្រីក្នុងការធ្វើការងារ ការដោះស្រាយបញ្ហា និងការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន។

## ២.២. ការទទួលបានភារកិច្ចការងារ សិទ្ធិអំណាចពេញលេញរបស់ស្ត្រី ស្របតាមច្បាប់

### ២.២.១. ការប្រគល់តួនាទី ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ទៅសមាជិការបស់ខ្លួន

**ក្រាហ្វិកទី៦ ៖**

**ការប្រគល់តួនាទីភារកិច្ចរបស់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ទៅសមាជិកស្ត្រី**




ក្នុងចំណោមសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់**៣៦នាក់** មាន**៣៥នាក់** (៩៧,២២%)ឆ្លើយថា ប្រធានក្រុមប្រឹក្សាបានប្រគល់ តួនាទី ភារកិច្ចជូនពួកគាត់ដែលជាសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ដូចមានចែងក្នុងច្បាប់។ **១នាក់ (២,៧៧%)** ឆ្លើយថា ប្រធានក្រុមប្រឹក្សាឃុំមិនដែលប្រគល់តួនាទី ភារកិច្ចឲ្យសោះ។ បើប្រៀបធៀបនឹងឆ្នាំ២០១៥ ការរើសអើងមិនប្រគល់ភារកិច្ចជូនដល់សមាជិកស្ត្រីក្រុមប្រឹក្សាឃុំ មានការ**ថយចុះ** ពី **៩,៧៥%** ឆ្នាំ២០១៥ មកត្រឹម **២,៧៧%** ឆ្នាំ២០១៩។

បើទោះបីតួលេខរើសអើងនេះមានការថយចុះក៏ដោយ ក៏នៅតែបង្ហាញនូវការរើសអើងកាន់តែខ្លាំងថែមទៀតមិនធ្លាប់បានឮពីមុន ដែលជាបញ្ហាបន្ទាន់ត្រូវយកចិត្តទុកដាក់ដោះស្រាយជាចាំបាច់ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាដែលមិនបានទទួលតួនាទី ភារកិច្ចរបស់ខ្លួនសោះ ឬទទួលមិនបានពេញលេញ ដើម្បីអនុវត្តការងារស្របតាមច្បាប់ ស្តីពី « *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់* » ដែលបានធានាដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវតែមានភារកិច្ចទៅតាមតួនាទីរៀងៗខ្លួន។

ជាក់ស្តែង កញ្ញា **សែម សៀខ** ជាសមាជិកក្រុមប្រឹក្សាឃុំ ទទួលបន្ទុកកិច្ចការនារី និងកុមារ មកពីគណបក្សប្រជាជនកម្ពុជា នៅឃុំពពេល ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ *មិនបានទទួលតួនាទី ភារកិច្ចសោះដើម្បីអនុវត្តការងារស្របតាមច្បាប់បានផ្តល់ឲ្យ។*

### ២.២.២. ការបញ្ឈប់សមាជិកស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់

យោងតាមចម្លើយរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់**៣៦នាក់** និងអ្នកសង្កេតការណ៍ស្ត្រី បានបង្ហាញថា មានការបញ្ឈប់សមាជិកក្រុមប្រឹក្សាឃុំ ចំនួន**៥នាក់**ដែលមកពីគណបក្សផ្សេងគ្នាដូចជា៖

១- លោកស្រី **ស្រី គីមសេខ** អាយុ ៥៧ឆ្នាំ មកពីគណបក្សសង្គ្រោះជាតិ នៅសង្កាត់អាចារ្យលាក់ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។ មូលហេតុដែលលោកស្រីត្រូវបានគេបញ្ឈប់គឺដោយសារលោកស្រី មិនព្រមចុះចូលគណបក្សប្រជាជនកម្ពុជា បន្ទាប់ពីមានការរំលាយគណបក្សសង្គ្រោះជាតិ និងលោកស្រីប្រឆាំង និងមិនគោរពគោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជា។ លោកស្រីធ្លាប់មានតំណែងជាជំទប់ទី១ ហើយតំណែងនេះត្រូវបានដាក់ជំនួសដោយបុរស។

២- លោកស្រី **ស្ងួន សាមាន** មានអាយុ ៥៦ឆ្នាំ មកពីគណបក្សសង្គ្រោះជាតិ មានតំណែងជាមេឃុំ នៅឃុំត្រពាំងចាន់ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។ មូលហេតុដែលលោកស្រីត្រូវបានគេបញ្ឈប់ គឺដោយសារលោកស្រីមិនព្រមចុះចូលគណបក្សប្រជាជនកម្ពុជា បន្ទាប់ពីមានការរំលាយគណបក្សសង្គ្រោះជាតិ។ តំណែងរបស់លោកស្រីត្រូវបានដាក់ជំនួសដោយបុរស។

៣- លោកស្រី **ញៀន សារី** មានអាយុ ៦២ឆ្នាំ មកពីគណបក្សសង្គ្រោះជាតិ ជាសមាជិកក្រុមប្រឹក្សាឃុំ ទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ នៅឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ។ មូលហេតុដែលលោកស្រីត្រូវបានគេបញ្ឈប់គឺដោយសារលោកស្រីមិនព្រមចុះចូលគណបក្សប្រជាជនកម្ពុជាបន្ទាប់ពីមានការរំលាយគណបក្សសង្គ្រោះជាតិ។ តំណែងរបស់លោកស្រីត្រូវបានដាក់ជំនួសដោយបុរស។

៤- លោកស្រី **ឯម ពៅ** អាយុ ៦៣ឆ្នាំ មកពីគណបក្សប្រជាជនកម្ពុជា នៅឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ មូលហេតុដោយសារ លោកស្រីចាស់ជរាដើរមិនបាន មើលអក្សរមិនច្បាស់។

៥- លោកស្រី **សំ យ៉ុន** មកពីគណបក្សប្រជាជនកម្ពុជា នៅសង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ។ មូលហេតុដែលលោកស្រីត្រូវបានគេបញ្ឈប់ គឺដោយសារលោកស្រី មានជម្ងឺមិនអាចធ្វើការកើត។

## ២.២.៣. ការចុះចូលគណបក្សផ្សេងរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

ឆ្នាំ២០១៩នេះ យ៉ាងហោចណាស់មានសមាជិកគណបក្សផ្សេងចំនួន**៨នាក់** ក្នុងនោះមាន ស្ត្រី**៣នាក់** និងបុរស**៥នាក់** បានចុះចេញពីគណបក្សខ្លួនទៅចុះចូលគណបក្សប្រជាជនកម្ពុជា៖

១). លោកស្រី **ជា ចាន់ណេត** មានអាយុ ៣៥ឆ្នាំ បានចុះចេញពីគណបក្សសង្គ្រោះជាតិទៅចុះចូលគណបក្សប្រជាជនកម្ពុជា។ លោកស្រីបានទទួលតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៅឃុំអញ្ចាញរូង ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។ មូលហេតុដែលលោកស្រីចុះចូលគណបក្សប្រជាជនកម្ពុជាគឺដោយសារលោកស្រី ចង់មានការងារធ្វើ ជាពិសេសលោកស្រីនៅតែមានឆន្ទៈក្នុងការធ្វើការងារ មិនចង់បាត់បង់ឱកាសក្នុងការជួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់លោកស្រី។

២). លោកស្រី **ឆាំង ឈួរ** មានអាយុ ៣៩ឆ្នាំ បានចុះចេញពីគណបក្សសង្គ្រោះជាតិទៅចុះចូលគណបក្សប្រជាជនកម្ពុជា។ លោកស្រីបានទទួលតួនាទីជាជំទប់ទី២ នៅឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ។ មូលហេតុដែលលោកស្រីចុះចូលគណបក្សប្រជាជនកម្ពុជា គឺដោយសារលោកស្រីចង់បន្តការងារ និងមិនចង់បាត់បង់ឱកាសក្នុងការជួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់លោកស្រី។

៣). លោកស្រី **អួន មៀត** មានអាយុ ៧០ឆ្នាំ បានចុះចេញពីគណបក្សសង្គ្រោះជាតិទៅចុះចូលគណបក្សប្រជាជនកម្ពុជា។ លោកស្រីបានទទួលតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ នៅឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ។ មូលហេតុដែលលោកស្រីចុះចូលគណបក្សប្រជាជនកម្ពុជា គឺដោយសារលោកស្រីចង់បន្តការងារ និងមិនចង់បាត់បង់ឱកាសក្នុងការជួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់លោកស្រី។

៤). លោក **ម៉ៅ ម៉ូ** មានអាយុ ៦០ឆ្នាំ បានចុះចេញពីគណបក្សសង្គ្រោះជាតិទៅចុះចូលគណបក្សប្រជាជនកម្ពុជា។ លោកបានទទួលតួនាទីជាជំទប់ទី២ នៅឃុំពេជ្រចង្វារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។ មូលហេតុដែលលោកចុះចូលគណបក្សប្រជាជនកម្ពុជា គឺដោយសារលោកចង់មានការងារធ្វើ មិនចង់បាត់បង់ឱកាសក្នុងការជួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។

៥). លោក **ឆន ឆុំ** មានអាយុ ៥៩ឆ្នាំ បានចុះចេញពីគណបក្សសង្គ្រោះជាតិទៅចុះចូលគណបក្សប្រជាជនកម្ពុជា។ លោកបានទទួលតួនាទីជាជំទប់ទី១ នៅឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ។ មូលហេតុដែលលោកចុះចូលគណបក្សប្រជាជនកម្ពុជា គឺដោយសារលោក ចង់មានការងារធ្វើ មិនចង់បាត់បង់ឱកាសក្នុងការជួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។

៦). លោក **ស គួន** មានអាយុ ៥៥ឆ្នាំ បានចុះចេញពីគណបក្សសង្គ្រោះជាតិទៅចុះចូលគណបក្សប្រជាជនកម្ពុជា។ លោកបានទទួលតួនាទីជាជំទប់ទី២ នៅឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ។ មូលហេតុដែលលោកចុះចូលគណបក្សប្រជាជនកម្ពុជាគឺដោយសារលោក ចង់មានការងារធ្វើ មិនចង់បាត់បង់ឱកាសក្នុងការជួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។

៧). លោក **សាយ សុគន្ធា** មានអាយុ ៥៥ឆ្នាំ បានចុះចេញពីគណបក្សសង្គ្រោះជាតិទៅចុះចូលគណបក្សប្រជាជនកម្ពុជា។ លោកបានទទួលតួនាទីជាជំទប់ទី២ នៅឃុំសំរោង ស្រុកសំរោង ខេត្តតាកែវ។ មូលហេតុ

ដែលលោកចុះចូលគណបក្សប្រជាជនកម្ពុជា គឺដោយសារលោកចង់មានការងារធ្វើ មិនចង់បាត់បង់ឱកាសក្នុងការជួយប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។

៨). លោក **ឡុង សុទ្ធ** មានអាយុ ៧៣ឆ្នាំ បានចុះចេញពីគណបក្សសង្គ្រោះជាតិទៅចុះចូលគណបក្សប្រជាជនកម្ពុជា។ លោកបានទទួលតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ នៅឃុំសំរោង ស្រុកសំរោង ខេត្តតាកែវ។ មូលហេតុដែលលោកចុះចូលគណបក្សប្រជាជនកម្ពុជា គឺដោយសារលោកចង់មានការងារធ្វើមិនចង់បាត់បង់ឱកាសក្នុងការជួយប្រជាពលរដ្ឋនៅមូលដ្ឋាន។

## ២.៣. ការបំពេញការងារទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ និងភាពសកម្មរបស់ស្ត្រី

ស្ថិតក្នុងតួនាទីរបស់ខ្លួន ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ទាំង**៣៦នាក់** បាន និងកំពុងធ្វើការយ៉ាងសកម្មនាពេលបច្ចុប្បន្ន។ ជាក់ស្តែង **ស្ត្រីដែលមានតួនាទីជាជំទប់ទី១ និងជំទប់ទី២** ព្រមទាំង**ស្ត្រីដែលមានតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ**ដែលភាគច្រើន**ទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ** កំពុងជាប់រវល់ជាមួយនឹងការដោះស្រាយបញ្ហាទំនាស់ក្នុងគ្រួសារ បញ្ហាអំពើហិង្សា បញ្ហារំលោភផ្លូវភេទ បញ្ហាសុខភាព និងអនាម័យ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យមានការយល់ដឹងអំពីយេនឌ័រ ចុះស្រង់ស្ថិតិគ្រួសារក្រីក្រ និងជនពិការ និងចែកអំណោយដល់ប្រជាពលរដ្ឋក្រីក្រ។ បន្ថែមពីនេះទៀត ពួកគាត់កំពុងប្រតិបត្តិការយ៉ាងមមាញឹកជាមួយនឹងកិច្ចការមួយចំនួនរួមមាន ដោះស្រាយលើបញ្ហាសុខភាព និងអនាម័យ ដូចជា៖ ចុះផ្សព្វផ្សាយព័ត៌មានអំពីជំងឺ អេដស៍ ជំងឺគ្រុនឈាម ជំងឺគ្រុនចាញ់ និងការសម្អាតបរិស្ថាន ជាពិសេសផ្សព្វផ្សាយឲ្យស្ត្រីកំពុងមានផ្ទៃពោះ និងស្ត្រីសម្រាលកូនរួចបានយល់ដឹងអំពីការថែទាំសុខភាពមុន និងក្រោយពេលសម្រាលកូន។ ផ្តល់ថវិកាដល់ស្ត្រីពេលសម្រាលកូន និងណែនាំស្ត្រីមានផ្ទៃពោះមកពិនិត្យសុខភាពនៅតាមមណ្ឌលសុខភាពឲ្យបានទៀងទាត់ និងផ្តល់ព័ត៌មានដល់មាតាបិតា ឬអាណាព្យាបាលឲ្យនាំកុមារទៅទទួលសេវាចាក់វ៉ាក់សាំង។ បន្ថែមលើនេះទៀត ស្ត្រីក្រុមប្រឹក្សាឃុំទាំងនេះ បានចុះតាមផ្ទះប្រជាពលរដ្ឋដើម្បីសួរសុខទុក្ខ និងផ្តល់ជាស្បៀង ថវិកាដល់ស្ត្រីមេម៉ាយ ចាស់ជរាគ្មានទីពឹងទីទាល់ក្រលំបាក ជួយដល់ស្ត្រីចាស់ជរា និងក្មេងកំព្រាគ្មានទីពឹង ដោយក្នុង១គ្រួសារ ចំនួន១០ម៉ឺនរៀល និងបានខ្នះខ្នែងជួយរកជំនួយថវិកាតាមរយៈសប្បុរសជនថែមទៀត ដើម្បីជួយដល់កុមារដែលរងអំពើហិង្សាលើផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ។ ទាក់ទងនឹងការអប់រំ បានជួយដល់កុមារដែលខ្វះខាតសម្ភារៈប្រើប្រាស់ក្នុងការសិក្សា ណែនាំកុមារគ្រប់អាយុឲ្យមកចុះឈ្មោះចូលរៀន និងចុះតាមសាលារៀនមើលការសិក្សារបស់ក្មេងៗ ព្រមទាំងចុះផ្សព្វផ្សាយអំពីបញ្ហាគ្រឿងញៀន និងគ្រឿងស្រវឹងនៅតាមសាលារៀន និងតាមមូលដ្ឋាន។ ការដោះស្រាយបញ្ហាទំនាស់ក្នុងមូលដ្ឋាន និងពង្រឹងការងារទំនាស់ដីធ្លី ការចុះអត្រានុកូលដ្ឋាន (ការចុះ និងបញ្ជាក់សំបុត្រកំណើត ចុះសំបុត្រអាពាហ៍ពិពាហ៍ និងបញ្ជាក់សំបុត្រមរណភាព)ដល់ប្រជាពលរដ្ឋ ចុះផ្សព្វផ្សាយព័ត៌មានដែលទាក់ទងទៅនឹងអំពើហិង្សាក្នុងគ្រួសារ និងសម្របសម្រួលនៅក្នុងគ្រួសារដែលមានអំពើហិង្សា ជួយពង្រឹងការងារដល់ស្ត្រីសមាជិកភូមិ ចុះតាមដានវាយតម្លៃ គណៈកម្មការស្ត្រីនៅតាមភូមិ និងរៀបចំកិច្ចប្រជុំប្រចាំខែ។

ដោយឡែក ក្នុងតួនាទីជា**ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និងជាមេឃុំ ចៅសង្កាត់** បាន និងកំពុងជាប់រវល់ជាមួយនឹងការទទួលខុសត្រូវរួមលើការគ្រប់គ្រងឃុំ សង្កាត់ ធ្វើយ៉ាងណាដើម្បីឲ្យឃុំ សង្កាត់របស់ខ្លួនមានការអភិវឌ្ឍន៍ និងសុវត្ថិភាព។ ចុះពិនិត្យ តាមដានសកម្មភាពការងារសមាជិកទាំងអស់ជាប្រចាំដើម្បីឲ្យមានគុណភាពខ្ពស់ និង ផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

## ២.៤. ការចូលរួមធ្វើសេចក្តីសម្រេចចិត្ត

### ២.៤.១. ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ និងកិច្ចប្រជុំប្រចាំខែ

ក្នុងចំណោមសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន៣៦នាក់ មាន២១នាក់ បានចូលរួមប្រជុំ មួយដងក្នុង១ខែជាទៀងទាត់ និងមានការកើនឡើង១៥នាក់បានចូលរួមប្រជុំពីរដងក្នុង១ខែ បើធៀបនឹងឆ្នាំ២០១៦មានត្រឹមតែ១៨នាក់។ ប្រហាក់ប្រហែលនឹងឆ្នាំ២០១៦ដែរ ស្ត្រីពិតជាមានឱកាសចូលរួមប្រជុំដោយពេញលេញស្របតាមច្បាប់ និងបទបញ្ញាផ្ទៃក្នុងសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់។ ដោយឡែក ឆ្នាំ២០១៩ យើងរកឃើញថា មានភាពប្រសើរឡើងក្នុងការចូលរួមបញ្ចេញមតិ យោបល់ និងការចូលរួមធ្វើសេចក្តីសម្រេចចិត្តរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ដូចបុរសដែរ បើទោះបីចំនួនបុរសមានច្រើនជាងស្ត្រីក៏ដោយ។

ទោះបីជាយ៉ាងណាក៏ដោយ យើងនៅតែមានការព្រួយបារម្ភ និងហាក់បីដូចជាពុំទាន់មានទំនុកចិត្តខ្លះនៅឡើយអំពីការបញ្ចេញមតិ យោបល់ និងការចូលរួមធ្វើសេចក្តីសម្រេចរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយបុរសភាគច្រើននៅតំបន់គោលដៅផ្សេងៗទៀត។ ជាទូទៅ ឃុំ សង្កាត់ទូទាំងព្រះរាជាណាចក្រកម្ពុជា ឃុំ សង្កាត់ខ្លះមានស្ត្រីក្រុមប្រឹក្សាជាអតិបរមា ៤នាក់ ឃុំ សង្កាត់ខ្លះមានស្ត្រី៣នាក់ ឃុំសង្កាត់ខ្លះទៀតមានស្ត្រី២នាក់ ឃុំ សង្កាត់ខ្លះមានស្ត្រី១នាក់ និងឃុំខ្លះទៀតពុំមានស្ត្រីសោះ។ ចំនួនស្ត្រីតិចនេះបានបន្ថយអំណាច និងឥទ្ធិពលរបស់ស្ត្រី និងជាកត្តាធ្វើឲ្យការចូលរួមសម្រេចចិត្តរបស់ស្ត្រីជួបនូវការលំបាក និងត្រូវរងឥទ្ធិពលពីការសម្រេចចិត្តរបស់បុរសដែលជាមតិភាគច្រើន។

### ២.៤.២. ការបញ្ចេញមតិយោបល់ ឬ សំណើររបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងកិច្ចប្រជុំ

ក្នុងចំណោមស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់**៣៦នាក់**ដែលបានចូលរួមប្រជុំ ស្ទើរតែទាំងអស់ **៣៥នាក់**ហ៊ានបញ្ចេញមតិយោបល់ និងលើកសំណើរដើម្បីឲ្យមានការដោះស្រាយ និងមានតែ១នាក់ប៉ុណ្ណោះដែលមិនធ្លាប់បានបញ្ចេញមតិយោបល់ ឬសំណើរអ្វីសោះដោយសារគាត់ជាសមាជិកក្រុមប្រឹក្សាឃុំថ្មី។ លទ្ធផលនេះបញ្ជាក់ថា ស្ត្រីបានបង្ហាញពីសក្តានុពលរបស់ខ្លួន ភាពជឿជាក់លើខ្លួនឯង និងបានប្រើប្រាស់សិទ្ធិក្នុងការឡើងបញ្ចេញមតិយោបល់ក្នុងពេលធ្វើការងារ និងក្នុងកិច្ចប្រជុំដែលភាគច្រើនផ្តោតលើបញ្ហាស្ត្រី កុមារ និងចាស់ជរា។ ទោះជាយ៉ាងនេះក្តី យើងនៅតែប្រាថ្នាចង់ឃើញស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ចូលរួមបញ្ចេញមតិ យោបល់ក្នុងអង្គប្រជុំឲ្យបានគ្រប់ៗគ្នា ដោយមានការលើកទឹកចិត្ត និងផ្តល់ឱកាសពីមេឃុំ ចៅ

សង្កាត់ជាបុរស និងសមាជិកបុរសភាគច្រើន និងផ្តល់អំណាចឲ្យស្ត្រីដោយពេញលេញក្នុងតួនាទី ភារកិច្ចរបស់ខ្លួន។

តារាងទី៨ ៖

| សំណើរ និងយោបល់របស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងអង្គប្រជុំ ដើម្បីដោះស្រាយ |
|---|
| ស្នើជួយដល់កុមារក្រីក្រ ជនពិការ និងចាស់ជរានៅក្នុងសហគមន៍ និងស្ត្រីដែលជួបការលំបាកនៅតំបន់ដាច់ស្រយាល |
| ស្នើមេភូមិជួយរាយការណ៍ពីស្ថានភាពស្ត្រី និងកុមារនៅក្នុងភូមិនីមួយៗ |
| សំណើរជួយដល់ស្ត្រីពពោះ និងសម្រាលកូន ដោយសាងសង់បន្ទប់សង្គ្រោះបឋមសម្រាប់ស្ត្រីពេលឆ្លងទន្លេ |
| ស្នើជួយធ្វើផ្ទះឲ្យស្ត្រីចាស់ជរា ជនគ្មានទីពឹង |
| ស្នើរកដំណោះស្រាយជួយដល់គ្រួសារមានផ្ទុកជំងឺអេដស៍ ជនរងគ្រោះដោយសារគ្រោះធម្មជាតិ គ្រួសារក្រីក្រ កុមារកំព្រា និងកុមារដែលបោះបង់ចោលការសិក្សា |
| ស្នើសុំឲ្យមានថវិកាលើកទឹកចិត្តពេលសម្រាលកូនដល់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ |
| បញ្ហាបរិស្ថាន អនាម័យ និងបញ្ហារៀបចំសន្តិសុខក្នុងឃុំ សង្កាត់ |
| សំណើរទៅប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ស្នើបន្តកម្មវិធីចុះតាមភូមិដើម្បីជួយដល់ម្តាយ និងកុមារ |
| សម្រួលក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋឲ្យបានលឿន |
| ស្នើគំរោងអភិវឌ្ឍ ដូចជា ហេដ្ឋារចនាសម្ព័ន្ធក្នុងភូមិ ឃុំ និងផ្សព្វផ្សាយពីបច្ចេកទេសកសិកម្ម |
| លើកពីបញ្ហាចំណាកស្រុក |
| ចង់ឲ្យមានវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពបំពេញការងារដល់ស្ត្រីដែលធ្វើការនៅ ឃុំ សង្កាត់ |

### ២.៤.៣. ការឆ្លើយតបទៅលើយោបល់ ឬសំណើររបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងកិច្ចប្រជុំ

ក្នុងចំណោមស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ **៣៦នាក់**បានលើកសំណើ និងយោបល់ មាន**៣៤នាក់**ឆ្លើយថា សំណើ និងយោបល់របស់ពួកគាត់ត្រូវបានគេសម្រេចក្នុងអង្គប្រជុំ និងយកទៅដោះស្រាយ។ **២នាក់**ទៀត ឆ្លើយថា បានត្រឹមតែយកសំណើ និងយោបល់របស់គាត់ទៅទុកពិចារណាដើម្បីសម្រេចពេលក្រោយដោយពុំមានកំណត់ពេលវេលាច្បាស់លាស់។ បើប្រៀបធៀបនឹង ឆ្នាំ២០១៤ និងឆ្នាំ២០១៥ ការធ្វើសេចក្តីសម្រេចក្នុងអង្គប្រជុំ និងដោះស្រាយលើសំណើរ និងយោបល់របស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មានការកើនឡើងជាបន្តបន្ទាប់ពី **៨៨,៨៨%** ឆ្នាំ២០១៤ ទៅ **៩២,៣០%** ឆ្នាំ២០១៥ និងទៅ **៩៤,៤៤%** ឆ្នាំ២០១៩។

<u>តារាងទី៩ ៖</u> សំណើរ និងយោបល់របស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានសម្រេចក្នុងអង្គប្រជុំ និងដំណោះស្រាយ

| សំណើរ និងយោបល់របស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងអង្គប្រជុំ ដើម្បីដោះស្រាយ | ការសម្រេចចិត្ត និងដំណោះស្រាយ |
|---|---|
| ស្នើជួយដល់កុមារក្រីក្រ ជនពិការ និងចាស់ជរានៅក្នុងសហគមន៍ និងស្ត្រីដែលជួបការលំបាកនៅតំបន់ដាច់ស្រយាល | **ទទួលយកតាមសំណើរ** |
| ស្នើមេភូមិជួយរាយការណ៍ពីស្ថានភាពស្ត្រី និងកុមារនៅក្នុងភូមិនីមួយៗ | ឯកភាពតាមសំណើរ |
| សំណើរជួយដល់ស្ត្រីពពោះ និងសម្រាលកូន ដោយសាងសង់បន្ទប់សង្គ្រោះបឋមសម្រាប់ស្ត្រីពេលឆ្លងទន្លេ | **សំណើរត្រូវបានគាំទ្រ និងយកទៅសម្រេច** |
| ស្នើជួយធ្វើផ្ទះឲ្យស្ត្រីចាស់ជរាគ្មានទីពឹង | សម្រេចសាងសង់ផ្ទះឲ្យស្ត្រីចាស់ជរាគ្មានទីពឹងបានចំនួន២ខ្នង និងមាន២គ្រួសារ |
| ស្នើរកដំណោះស្រាយជួយដល់គ្រួសារមានផ្ទុកជំងឺអេដស៍ ជនរងគ្រោះដោយសារគ្រោះធម្មជាតិ គ្រួសារក្រីក្រ កុមារកំព្រា និងកុមារដែលបោះបង់ចោលការសិក្សា | **បានសម្រេចតាមសំណើរ ដោយបានចុះទៅផ្ទាល់ ចែកអំណោយ និងជួយជម្រុញឲ្យកុមារទៅសាលារៀនឲ្យបានទៀងទាត់** |
| ស្នើសុំឲ្យមានថវិកាលើកទឹកចិត្តពេលសម្រាលកូនដល់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ | ត្រឹមពិចារណាទុកពេលយូរដើម្បីសម្រេច |
| បញ្ហាបរិស្ថាន អនាម័យ និងបញ្ហារៀបចំសន្តិសុខក្នុងឃុំ សង្កាត់ | **ទទួលយកតាមសំណើរ** |
| សំណើរទៅប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ស្នើបន្តកម្មវិធីចុះតាមភូមិដើម្បីជួយដល់ម្តាយ និងកុមារ | សម្រេចភ្លាមៗដោយបញ្ជូនសំណើរទៅថ្នាក់លើបន្តទៀត |

| | |
|---|---|
| សម្រួលក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋឲ្យបានលឿន | **ឯកភាពតាមសំណើរ** |
| ស្នើគំរោងអភិវឌ្ឍ ដូចជា ហេដ្ឋារចនាសម្ព័ន្ធក្នុងភូមិ ឃុំ និង ផ្សព្វផ្សាយពីបច្ចេកទេសកសិកម្ម | ទទួលយកតាមសំណើរ ព្រោះជាវាជាការចាំបាច់ ដែលស្របតាមតម្រូវការរបស់ប្រជាពលរដ្ឋជាក់ស្តែង និងដើម្បីអភិវឌ្ឍន៍នៅក្នុងភូមិ ឃុំទាំងអស់គ្នា |
| លើកពីបញ្ហាចំណាកស្រុក | **មិនទទួលបានការឆ្លើយតប** |
| ចង់ឲ្យមានវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពបំពេញការងារដល់ស្ត្រីដែលធ្វើការនៅ ឃុំ សង្កាត់ | ទទួលយកតាមសំណើរ |

## ៣. ថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារនៅឃុំ សង្កាត់

របាយការណ៍ឃ្លាំមើលរបស់ខុមហ្វ្រែល ទាក់ទិននឹងថវិកាប្រើប្រាស់លើកិច្ចការស្ត្រី និងកុមារសំរាប់ឃុំ សង្កាត់ប្រចាំឆ្នាំបានបង្ហាញតាមរយៈស្ត្រីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន**៣៦នាក់**មកពីឃុំ សង្កាត់ចំនួន **១៩** ក្នុងនោះឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សាចំនួន៥រូប មានចំនួន**៥ឃុំ។** ឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សាចំនួន**៧រូប** មានចំនួន**២ឃុំ។** ឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សាចំនួន**៩រូប** មានចំនួន៣ឃុំ និងឃុំសង្កាត់ដែលមានសមាជិកក្រុមប្រឹក្សាចំនួន១១រូប មានចំនួន**៤ឃុំ** ដែលលទ្ធផលបានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ៖

**តារាងទី១០ ៖ ថវិកាសរុបប្រចាំឆ្នាំ**

| ថវិកាសរុបប្រចាំឆ្នាំ ដែលក្រុមប្រឹក្សា ឃុំ សង្កាត់ទទួលបានសម្រាប់កិច្ចការស្ត្រី និងកុមារ | | | |
|---|---|---|---|
| ឃុំតូច | ឃុំមធ្យម | | ឃុំធំ |
| ក្រុមប្រឹក្សា ឃុំ សង្កាត់ សមាជិក ៥រូប | ក្រុមប្រឹក្សា ឃុំ សង្កាត់ សមាជិក ៧រូប | ក្រុមប្រឹក្សា ឃុំ សង្កាត់ សមាជិក ៩រូប | ក្រុមប្រឹក្សា ឃុំ សង្កាត់ សមាជិក ១១រូប |
| • ៤ 000 000 រៀល (បួនលានរៀល) នៅសង្កាត់អាចារ្យលាក់ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ<br>• ២ 000 000 រៀល (ពីរលានរៀល) នៅឃុំក្តីដូង ស្រុកកំពង់ស្វាយ | • នៅឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង និង ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ទទួលបន្ទុកកិច្ចការនារី មិនដឹងពី | • ២ 000 000 រៀល (ពីរលានរៀល) នៅ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ<br>• ប្រហែល ៧ 000 | • ២ ១៨២ ២00 រៀល (ពីរលាន មួយសែនប៉ែតសិបពីរម៉ឺន ពីររយរៀល) នៅឃុំជាស្រុកមេមត់ ខេត្តត្បូងឃ្មុំ<br>• ១ ៨00 00 រៀល (មួយលាន បួន |

| | | | |
|---|---|---|---|
| ខេត្តកំពង់ធំ<br>• ២ ០០០ ០០០ រៀល (ពីរលានរៀល) នៅសង្កាត់កំពង់ធំ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ<br>• នៅឃុំអញ្ចាញរូង ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង សមាជិកក្រុមប្រឹក្សាឃុំហាក់មិនដឹងច្បាស់ពីកញ្ចប់ថវិកាសម្រាប់ស្ត្រី និងកុមារទេ ព្រោះថវិកាស្ថិតនៅក្នុងការគ្រប់គ្រងរបស់ស្មៀន<br>• ៨០០ ០០០ រៀល (ប៉ែតសិបម៉ឺនរៀល) នៅឃុំពោធិ៍ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ | ខ្វះចំណាយលើស្ត្រី និងកុមារ ច្បាស់លាស់ទេ | ០០០ រៀល (ប្រាំពីរលានរៀល) នៅឃុំសិដ្ឋ ស្រុកសំរោង ខេត្តតាកែវ<br>• ប្រហែល ៨ ០០០ ០០០ រៀល (ប្រាំបីលានរៀល) នៅឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ | សែនរៀល) នៅឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ<br>• ៧ ៣៣៤ ៤០០ រៀល (ប្រាំពីរលាន បីសែន បីម៉ឺន បួនពាន់ បួនរយរៀល) នៅឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ<br>• ៦ ០០០ ០០០ រៀល (ប្រាំមួយលានរៀល) នៅឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ |

## ៣.១. តម្លាភាពថវិកា

### ក្រាហ្វិកទី៧ ៖ តម្លាភាពថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ




ថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ ឃុំខ្លះនៅមានការលំបាកក្នុងការដកយកមកប្រើប្រាស់ យឺតយ៉ាវ និងមិនគ្រប់គ្រាន់តាមតម្រូវការនៃការងារ ព្រមទាំងតម្លាភាពថវិកាក៏នៅមានកម្រិតនៅឡើយ។

របាយការណ៍រកឃើញទៀតថា តម្លាភាពថវិកានៅមានកម្រិតសម្រាប់កិច្ចការស្ត្រី និងកុមារនៅឃុំ សង្កាត់មួយចំនួន។ ការមិនសូវមានតម្លាភាពថវិកានេះ ដោយសារកញ្ចប់ថវិការបស់ពួកគេមានការលាក់បាំងខ្លះៗ។ ឃុំ សង្កាត់ខ្លះថវិកាទាំងនោះមិនបានផ្សព្វផ្សាយ ឬបិទជាព័ត៌មាន ឬប្រជុំធ្វើបទបង្ហាញអ្វីឡើយ។ ជាក់ស្តែង នៅក្នុងឃុំចំនួន៥ ដូចជា នៅ***ឃុំពពេល*** ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នៅ***ឃុំកោងកាង*** ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នៅ***ឃុំអញ្ចាញរូង*** ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង និងនៅ***ឃុំក្រាំងស្គារ*** ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង សមាជិកក្រុមប្រឹក្សាឃុំមិនដឹងអំពីថវិកាមានប៉ុន្មាននោះទេ។ រីឯ ***នៅឃុំពពេល*** ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង មិនមានខ្ទង់ថវិកាច្បាស់លាស់សម្រាប់ការចំណាយលើកិច្ចការស្ត្រី និងកុមារទេ។

**លោកស្រី ថៃ សារ៉ាន់** ជាជំទប់ទី១ ទទួលបន្ទុកការងារអប់រំ និងរដ្ឋបាល នៅឃុំពពេល ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង មកពីគណបក្សប្រជាជនកម្ពុជា បានមានប្រសាសន៍ថា « *នាងខ្ញុំមិនដឹងពីចំនួនថវិកាសំរាប់ស្ត្រី និងកុមារទេ ព្រោះមិនមានការបែងចែកច្បាស់លាស់ មិនបានបែងចែកឲ្យបានត្រឹមត្រូវទៅតាមផ្នែកនោះទេ*»។

## ៣.២. ការដកថវិកា

**ក្រាហ្វិកទី៨ ៖ ការដកថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ**




ក្នុងចំណោមស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់៣៦នាក់នៃ១៩ឃុំ សង្កាត់ មាន៣១នាក់ (**១៦ឃុំ**)មានភាព**ងាយស្រួល**ក្នុងការដកថវិកាមកប្រើប្រាស់លើកិច្ចការស្ត្រី និងកុមារ ខណៈដែល៥នាក់ (**៣ឃុំ**)ទៀតមាន**ការពិបាក**ក្នុងការដកថវិកាពីរតនាគារ ស្មៀនជាអ្នកចាត់ចែងថវិកា និងពុំមានបែងចែកកញ្ចប់ថវិកាច្បាស់លាស់ទៅតាមផ្នែកនីមួយៗ។ ឃុំដែលមានការពិបាកដកថវិកាគឺ ឃុំអញ្ចាញរូង និងឃុំពពេល (ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង) និង ឃុំក្រាំងស្គារ (ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង)។ ដោយឡែកមានមតិផ្ទុយគ្នានៅក្នុង ឃុំក្រាំង

ស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ម្នាក់ថាងាយស្រួលដក ម្នាក់ទៀតថាពិបាកដក។ **លោកស្រី ខៀវ សៅ** មានតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំទទួលបន្ទុកការងារទូទៅបានមានប្រសាសន៍ថា៖ « *មានការពិបាកក្នុងការដកថវិកា ដោយសារត្រូវទៅដកនៅរតនាគារ ដែលត្រូវចំណាយពេលយូរ និងមានដំណើរការស្មុគស្មាញ* » ចំណែក **លោកស្រី ព្រាប ឡា** មានតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទទួលបន្ទុកការកិច្ចការស្ត្រី និងកុមារ បានមានប្រសាសន៍ថា៖ « *ការដកថវិកាសម្រាប់ប្រើប្រាស់លើកិច្ចការស្ត្រី និងកុមារ គឺមានភាពងាយស្រួល គ្មានការពិបាកអ្វីទេ គ្រាន់តែថវិកានឹងមានចំនួនតិច ខ្ញុំចង់បានច្រើនជាងនេះ* »។

សរុបសេចក្តីមក ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់បានប្រើប្រាស់សក្តានុពលរបស់ខ្លួនពេញលេញ មានភាពជឿជាក់លើខ្លួនឯង និងក្លាហានក្នុងការឡើងបញ្ចេញមតិយោបល់ក្នុងពេលធ្វើការងារ និងក្នុងកិច្ចប្រជុំនានាបើទោះបីជួបនូវឧបសគ្គខ្លះៗក៏ដោយ។ កិច្ចការ និងមតិយោបល់របស់ស្ត្រីភាគច្រើនផ្តោតលើផលប្រយោជន៍ស្ត្រី និងកុមារជាសំខាន់រួមទាំងកិច្ចការអភិវឌ្ឍន៍ឃុំ សង្កាត់ផងដែរ ខណៈដែលបុរសភាគច្រើនលើសលុបរួមទាំងផ្នត់គំនិតសង្គម មានការប្តូរឥរិយាបថមកឲ្យតម្លៃស្ត្រី យល់ថាការចូលរួមរបស់ស្ត្រីនៅថ្នាក់មូលដ្ឋានពិតជាមានសារៈសំខាន់ ជាពិសេសការចូលរួមនៅថ្នាក់សម្រេចចិត្ត មានទំនុកចិត្តធ្វើការជាមួយស្ត្រី ដោយចង់ឲ្យស្ត្រីច្រើនចូលរួមធ្វើការនៅក្នុងឃុំដើម្បីភាពរីកចំរើន និងចង់លើកកម្ពស់សមភាពយេនឌ័រ។ នៅក្នុងកិច្ចប្រជុំបុរសក្រុមប្រឹក្សាឃុំបានទុកឱកាសឲ្យស្ត្រីបញ្ចេញមតិយោបល់បានច្រើន និងមុនសម្រេចកិច្ចការអ្វីតែងសួរយោបល់ពីស្ត្រីជាមុន។ បន្ថែមលើនេះទៀត មានការគាំទ្រ និងសហការយ៉ាងល្អពីមេភូមិផងដែរ ជាមួយនឹងការគាំទ្រស្ទើរតែទាំងស្រុងពីក្រុមគ្រួសារ និងប្រជាពលរដ្ឋ ដែលបង្ហាញពីការយល់ដឹងអំពីយេនឌ័រក្នុងការជម្រុញ លើកទឹកចិត្តយ៉ាងខ្លាំងដល់ការចូលរួមរបស់ស្ត្រីឲ្យមានភាពកាន់តែសកម្មថែមមួយកម្រិតទៀត និងឈានទៅរកសមភាពរវាងស្ត្រី និងបុរសក្នុងកិច្ចការសង្គម។ លើសពីនេះ បញ្ហាស្ត្រី និងកុមារក៏ត្រូវបានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងបុរស ទាំងស្ត្រី ចាត់ជាបញ្ហាចម្បង និងត្រូវយកចិត្តទុកដាក់ដោះស្រាយជាបន្តបន្ទាប់។ ចំណែកឯថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារក៏មានភាពងាយស្រួលក្នុងការដកយកមកប្រើប្រាស់សម្រាប់ឃុំ សង្កាត់ភាគច្រើន ប៉ុន្តែថវិកានៅមានចំនួនតិច។

ទោះជាយ៉ាងនេះក្តី ការរើសអើងចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួនក៏នៅតែបន្តមាននៅឡើយ បើទោះបីតួលេខរើសអើងនេះមានការថយចុះខ្លាំងក៏ដោយ ប៉ុន្តែបានបង្ហាញនូវភាពរើសអើងកាន់តែខ្លាំងថែមទៀតមិនធ្លាប់បានឮពីមុន ដែលជាបញ្ហាបន្ទាន់ត្រូវយកចិត្តទុកដាក់ដោះស្រាយជាចាំបាច់ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាដែលមិនបានទទួលតួនាទី ភារកិច្ចរបស់ខ្លួនសោះ ឬទទួលមិនបានពេញលេញដើម្បីអនុវត្តការងារស្របតាមច្បាប់ ស្តីពី « *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់* » ដែលបានធានាដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវតែមានភារកិច្ចទៅតាមតួនាទីរៀងៗខ្លួន។ រីឯថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ ឃុំខ្លះនៅមានការលំបាកក្នុងការដកយកមកប្រើប្រាស់ យឺតយ៉ាវ និងមិនគ្រប់គ្រាន់តាមតម្រូវការនៃការងារ ព្រមទាំងតម្លាភាពថវិកាក៏នៅមានកម្រិត។

# ៤. ករណីសិក្សា

## ៤.១ សកម្មភាពលេចធ្លោរបស់ស្ត្រីនៅថ្នាក់មូលដ្ឋាន

### ករណីសិក្សាទី១

> ***មូលហេតុដែលជម្រុញឲ្យលោកស្រី សំរិត អៀង ចូលប្រឡូកក្នុងការងារនយោបាយ គឺ ដោយសារលោកស្រីចង់ជួយសង្គមដោយផ្ទាល់ ចង់ការពារផលប្រយោជន៍របស់ស្ត្រី និងកុមារ ចង់ជួយលើកកម្ពស់ស្ត្រីក្នុងឃុំឱ្យមានឆន្ទៈមុតមាំក្លាហានឡើង និងចង់ជួយដោះស្រាយបញ្ហាជូនស្ត្រីនៅពេលដែលជួបបញ្ហា ។***

លោកស្រី **សំរិត អៀង** មានតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ ទទួលបន្ទុកផ្នែកកិច្ចការស្ត្រី និងកុមារ មកពីគណបក្សប្រជាជនកម្ពុជា នៅឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ក្នុងអាណត្តិទី៤ (ឆ្នាំ២០១៧-ឆ្នាំ២០២២) ដែលមានសមាជិកក្រុមប្រឹក្សាឃុំ សរុប ១១រូប ក្នុងនោះមានស្ត្រី ២រូប (១៨,១៨%) មានសមាសភាព ពីរគណបក្សនយោបាយ៖

| | | |
|---|---|---|
| ១. ប្រធានក្រុមប្រឹក្សាឃុំ (មេឃុំ) | គណបក្សប្រជាជនកម្ពុជា | (បុរស) |
| ២. សមាជិកក្រុមប្រឹក្សាឃុំ (ជំទប់ទី១) | គណបក្សប្រជាជនកម្ពុជា | (បុរស) |
| ៣. សមាជិកក្រុមប្រឹក្សាឃុំ (ជំទប់ទី២) | គណបក្សហ៊្វុនស៊ិនប៉ិច | (បុរស) |
| ៤. សមាជិកក្រុមប្រឹក្សាឃុំ | គណបក្សប្រជាជនកម្ពុជា | (ស្ត្រី) |
| ៥. សមាជិកក្រុមប្រឹក្សាឃុំ | គណបក្សហ៊្វុនស៊ិនប៉ិច | (បុរស) |
| ៦. សមាជិកក្រុមប្រឹក្សាឃុំ | គណបក្សប្រជាជនកម្ពុជា | (ស្ត្រី) |
| ៧. សមាជិកក្រុមប្រឹក្សាឃុំ | គណបក្សប្រជាជនកម្ពុជា | (បុរស) |
| ៨. សមាជិកក្រុមប្រឹក្សាឃុំ | គណបក្សប្រជាជនកម្ពុជា | (បុរស) |
| ៩. សមាជិកក្រុមប្រឹក្សាឃុំ | គណបក្សប្រជាជនកម្ពុជា | (បុរស) |
| ១០. សមាជិកក្រុមប្រឹក្សាឃុំ | គណបក្សប្រជាជនកម្ពុជា | (បុរស) |
| ១១. សមាជិកក្រុមប្រឹក្សាឃុំ | គណបក្សប្រជាជនកម្ពុជា | (បុរស) |

នៅក្នុងឃុំកំពង់ស្វាយនេះមានភូមិ**ចំនួន១២** និងមាន**៣៣៥៩គ្រួសារ** ដែលមានប្រជាពលរដ្ឋសរុបប្រមាណជាង**១៥៣៦៤នាក់** ក្នុងនោះស្ត្រីមានចំនួន**៧៧០៤នាក់**។

បច្ចុប្បន្នលោកស្រី **សំរិត អៀង** មានអាយុ៣៨ឆ្នាំ មានបងប្អូនបង្កើតចំនួន៥នាក់ លោកស្រីជាកូនទី២ និងបានរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ២០០៥ ដែលស្វាមីរបស់លោកស្រីជាកសិករធ្វើស្រែចម្ការធម្មតា មានកូនស្រីប្រុសចំនួន ២នាក់។

លោកស្រីមានប្រវត្តិ បទពិសោធការងារ និងកម្រិតវប្បធម៌ ដូចខាងក្រោម៖

- នៅឆ្នាំ១៩៩៦ បញ្ចប់ការសិក្សាថ្នាក់អនុវិទ្យាល័យ
- នៅឆ្នាំ២០១២ បញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ បន្ទាប់មកលោកស្រីរកស៊ីបន្តិចបន្តួច ហើយក្រោយមកឆ្នាំ២០១៧ក៏ជាប់ឆ្នោតជាស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់។

លោកស្រី **សំរិត អៀង** បានជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ តាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧។ មុនជាប់ជាសមាជិកក្រុមប្រឹក្សាឃុំ លោកស្រីជាប្រជាពលរដ្ឋសកម្មម្នាក់នៅក្នុងភូមិ ឃុំរបស់លោកស្រី។

លោកស្រីទទួលបានការគាំទ្រពីសំណាក់ក្រុមគ្រួសាររបស់លោកស្រីផ្ទាល់ ថែមទាំងមានការអបអរសារទពីសំណាក់ញាតិជិតខាង និងទទួលបានការលើកទឹកចិត្ត គាំទ្រពីបុរសៗនៅក្នុងឃុំ សង្កាត់។ ចំណែកឯបុរសក្រុមប្រឹក្សាឃុំដែលធ្វើការជាមួយលោកស្រីពេញចិត្តនឹងសហការការងារជាមួយគ្នា និងមានការជំរុញលើកទឹកចិត្តចំពោះលោកស្រីថែមទៀត។ លោកស្រីបានបញ្ជាក់ថា « *មិនមានការរើសអើងតូចទ្បកត់សម្គាល់ណាមួយមកលើរូបលោកស្រី ឬស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ដទៃទៀតទេ* »។

មូលហេតុដែលជម្រុញឲ្យលោកស្រីចូលប្រឡូកក្នុងការងារនយោបាយគឺ ដោយសារលោកស្រីចង់ជួយសង្គមដោយផ្ទាល់ ចង់ការពារផលប្រយោជន៍របស់ស្ត្រី និងកុមារ ចង់ជួយលើកកម្ពស់ស្ត្រីក្នុងឃុំឲ្យមានឆន្ទៈមុតមាំក្លាហានឡើង ហើយចង់ជួយដោះស្រាយបញ្ហាជូនស្ត្រីនៅពេលដែលជួបបញ្ហា និងជួយពន្យល់ដល់ស្ត្រីឲ្យយល់ដឹងកាន់តែច្រើនជាងមុន និងជួយផ្សព្វផ្សាយពីច្បាប់ផ្សេងៗ។ ជាងនេះទៅទៀត លោកស្រីស្រលាញ់ និងចង់ធ្វើការមួយនេះជាខ្លាំង ព្រោះលោកស្រីចង់អភិវឌ្ឍន៍ភូមិ ឃុំរបស់ខ្លួនឲ្យមានភាពរីកចម្រើនទៅមុខ។

ចំណុចដែលជំរុញឲ្យលោកស្រី **សំរិត អៀង** បានជាប់ជាស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់គឺដោយសារគាត់ទទួលបានគាំទ្រ ស្រលាញ់ពេញចិត្តពីសំណាក់ប្រជាពលរដ្ឋនៅក្នុងភូមិ។ លោកស្រី **សំរិត អៀង** បានមានប្រសាសន៍ថា « *ការដែលខ្ញុំជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំនេះ គឺជាភាពជោគជ័យ និងសម្រេចបាននូវគោលបំណងដែលខ្ញុំចង់បាន ព្រោះខ្ញុំចង់ធ្វើការងារនេះដើម្បីជួយសង្គម ជាពិសេសចង់ជួយដោះស្រាយបញ្ហាស្ត្រី និងកុមារ នៅក្នុងភូមិ ឃុំរបស់ខ្ញុំ* »។ ពីមុនមកលោកស្រីជាសមាជិកគណបក្សសមរង្ស៊ី និងបានចូលបម្រើការងារឲ្យគណបក្ស។ បន្ទាប់មកលោកស្រីបានទទួលការបោះឆ្នោតគាំទ្រពីសមាជិកបក្សសម្រាប់ជាបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧។

នៅតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ លោកស្រី **សំរិត អឿន** បានចូលរួមប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ជារៀងរាល់ខែ ដែលជាទូទៅគេធ្វើការប្រជុំមួយដងក្នុងមួយខែ។ នៅក្នុងអំឡុងពេលប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ លោកស្រីក៏ធ្លាប់បានបញ្ចេញយោបល់ ឬធ្វើជាសំណើរផ្សេងៗ ដោយភាគច្រើនលោកស្រីបានលើកឡើងពីបញ្ហាកុមារកំព្រា ស្ត្រីចាស់ជរាគ្មានទីពឹង អំពើហឹង្សាក្នុងគ្រួសារជាដើម។ រាល់សំណើរគាត់ត្រូវបានគេស្តាប់ និងពិភាក្សាព្រោះជាកិច្ចការដែលត្រូវចូលរួមធ្វើទាំងអស់គ្នាផងដែរ។

ថវិកាសរុបប្រចាំឆ្នាំសម្រាប់ការងារស្ត្រី និងកុមារនៅក្នុងឃុំកំពង់ស្វាយមានចំនួន ១ ៤០០ ០០០ *រៀល* (មួយលានបួនសែនរៀល)។ សម្រាប់ការចំណាយលើថវិកានេះគឺមានតម្លាភាពណាស់ដោយសារតែមានរបាយការណ៍ និងការផ្សព្វផ្សាយជាសាធារណៈដោយមិនមានការលាក់លាមអ្វីឡើយ។ អ្នកដែលកាន់កាប់ថវិកាគឺស្មៀន ហើយការដកថវិកាយកមកប្រើប្រាស់ គឺមានភាពងាយស្រួល ដោយសារគាត់បានទៅប្រមូលព័ត៌មានពីសហគមន៍យកមកធ្វើរបាយការណ៍ជូនមេឃុំជាទៀងទាត់។ ក្នុងដំណើរការនៃការប្រើប្រាស់កញ្ចប់ថវិកាស្ត្រី និងកុមារនេះគឺត្រូវដកតាមជុំ (៨ជុំក្នុង១ឆ្នាំ) សម្រាប់យកទៅដោះស្រាយបញ្ហាស្ត្រី កុមារ និងជនក្រីក្រដែលកំពុងតែកើតមាន។ នៅជុំទី១ លោកស្រីនឹងធ្វើការស្នើទៅកាន់ស្មៀនដើម្បីយកថវិកានោះមកប្រើប្រាស់ទៅតាមតម្រូវការជាក់ស្តែង បន្ទាប់មកលោកស្រីបន្តធ្វើបែបនេះរហូតអស់ជុំក្នុងការដកថវិកានោះ។ ប៉ុន្តែទោះជាយ៉ាងណា កញ្ចប់ថវិកានេះវាគ្រាន់តែជួយដោះស្រាយទៅលើបញ្ហារបស់ស្ត្រី និងកុមារនៅក្នុងភូមិឃុំបានតិចតួចតាមលទ្ធភាព និងធនធានដែលយើងមានតែប៉ុណ្ណោះ ព្រោះថវិកាប៉ុណ្ណឹងវាមិនគ្រប់គ្រាន់តាមតម្រូវការជាក់ស្តែងនៅក្នុងឃុំនោះទេ។

បច្ចុប្បន្ននេះលោកស្រី **សំរិត អឿន** កំពុងមានភាពមមាញឹកជាមួយនឹងការងារស្ត្រី និងកុមារ ដូចជាចុះទៅផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋពីបញ្ហាសុខភាព ការអប់រំ អំពើហឹង្សាក្នុងគ្រួសារ ចុះត្រួតពិនិត្យសហគមន៍ដែលនៅតំបន់ដាច់ស្រយាល ដោះស្រាយបញ្ហាជនចាស់ជរាគ្មានទីពឹង និងកុមារកំព្រា និងបញ្ហាអំពើហឹង្សាមកលើស្ត្រីជាដើម។

ឆន្ទៈ និងគម្រោងរបស់លោកស្រីនៅតែមាន ដោយប្តេជ្ញាចិត្តថានឹងខិតខំប្រឹងប្រែងធ្វើការងារបន្តទៀត ដូចជាខិតខំផ្សព្វផ្សាយអំពីច្បាប់ ដើម្បីឲ្យប្រជាពលរដ្ឋ ជាពិសេសស្ត្រីឲ្យបានយល់ដឹងអំពីច្បាប់ផ្សេងៗ។ លោកស្រីមានការតាំងចិត្តថា នឹងខិតខំប្រឹងប្រែងបំពេញការងារនេះឲ្យបានល្អ ដើម្បីជាប្រយោជន៍ដល់សង្គមជាតិ និងជួយដោះស្រាយ បញ្ហាស្ត្រី និងកុមារដែលនៅតែបន្តកើតមាន។

សំណូមពររបស់លោកស្រី **សំរិត អឿន** « *សូមរដ្ឋាភិបាលបន្ថែមកញ្ចប់ថវិកាឲ្យបានច្រើនសម្រាប់ការងារស្ត្រី និងកុមារ ដើម្បីជួយដោះស្រាយបញ្ហាជូនស្ត្រី និងកុមារប្រកបដោយប្រសិទ្ធភាព ព្រោះថាកន្លងមកលោកស្រីធ្វើទៅតាមធនធាន ដែលមានវាមិនគ្រប់គ្រាន់ទេ។ ជាងនេះទៅទៀត សូមថ្នាក់លើជួយបន្ថែមក្នុងការពង្រឹងយុទ្ធសាស្ត្រលើកិច្ចការពារស្ត្រី និងកុមារឲ្យបានច្រើន និងពង្រឹងសមត្ថភាពស្ត្រីប្រឹក្សាឃុំ សង្កាត់ឲ្យបានយល់ដឹងច្រើនជាងមុន ប្រយោជន៍ងាយស្រួលប្រតិបត្តិការងារ* »។

## ករណីសិក្សាទី២

*[ គោលដៅសំខាន់បំផុតរបស់លោកស្រី **ដុំ សោភ័ណ្ឌ**ចូលរួមធ្វើការងារជាស្ត្រីក្រុមប្រឹក្សាឃុំនេះ គឺចង់ជួយអ្នកក្រីក្រ ជួយសម្រាលទុក្ខលំបាករបស់ស្ត្រី កុមារកំព្រា និងចង់លុបបំបាត់អំពើហិង្សាក្នុងគ្រួសារនៅក្នុងមូលដ្ឋានរបស់លោកស្រី។ លោកស្រីចង់លើកកម្ពស់ស្ត្រី ដោយធ្វើជាគំរូល្អដល់ក្មេងជំនាន់ក្រោយ និងដើម្បីឲ្យប្រជាពលរដ្ឋឃើញថា ស្ត្រីក៏មានសមត្ថភាពក្នុងការចូលប្រឡូកក្នុងកិច្ចការនយោបាយ និងការដឹកនាំបានដែរ។]*

លោកស្រី **ដុំ សោភ័ណ្ឌ** មកពីគណបក្សប្រជាជនកម្ពុជា មានតួនាទីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ នៅឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន១១រូប ក្នុងនោះ មានស្រី **៣រូប (២៧,២៧%)** មានតែមួយគណបក្សប្រជាជនកម្ពុជា។

| | |
|---|---|
| ១. ប្រធានក្រុមប្រឹក្សាឃុំ (មេឃុំ) | (ប្រុស) |
| ២. សមាជិកក្រុមប្រឹក្សាឃុំ (ជំទប់ទី១) | (ប្រុស) |
| ៣. សមាជិកក្រុមប្រឹក្សាឃុំ (ជំទប់ទី២) | (ប្រុស) |
| ៤. សមាជិកក្រុមប្រឹក្សាឃុំ | (ស្ត្រី) |
| ៥. សមាជិកក្រុមប្រឹក្សាឃុំ | (ស្ត្រី) |
| ៦. សមាជិកក្រុមប្រឹក្សាឃុំ | (ប្រុស) |
| ៧. សមាជិកក្រុមប្រឹក្សាឃុំ | (ប្រុស) |
| ៨. សមាជិកក្រុមប្រឹក្សាឃុំ | (ប្រុស) |
| ៩. សមាជិកក្រុមប្រឹក្សាឃុំ | (ប្រុស) |
| ១០. សមាជិកក្រុមប្រឹក្សាឃុំ | (ប្រុស) |
| ១១. សមាជិកក្រុមប្រឹក្សាឃុំ | (ប្រុស) |

នៅក្នុងឃុំអង្គតាសោមមានចំនួន២២ភូមិ មានគ្រួសារចំនួន៣៦១៥ និងមានប្រជាពលរដ្ឋប្រមាណជាង១៩ ១១៦នាក់ ក្នុងនោះមានស្រីចំនួន ៩ ៩២៨នាក់។

លោកស្រី **ដុំ សោភ័ណ្ឌ** មានអាយុ៥០ឆ្នាំ នៅលីវ ជាកូនកំព្រាឪពុកម្តាយតាំងពីឆ្នាំ២០១៥ និងមានបងប្អូន៤នាក់ ស្រី២នាក់ ប្រុស២នាក់។ សព្វថ្ងៃនេះលោកស្រីរស់នៅជាមួយបងស្រីបង្កើត។

លោកស្រីមានប្រវត្តិ បទពិសោធការងារ និងកម្រិតវប្បធម៌ ដូចខាងក្រោម៖

- ឆ្នាំ១៩៨៨ — បានបញ្ចប់ថ្នាក់ទី៩ (ឌីប្លូម)
- ឆ្នាំ១៩៨៨-ឆ្នាំ១៩៩០ — ធ្វើការស្ម័គ្រចិត្តនៅសាលាស្រុកដោយមិនទទួលបានកម្រៃ
- ឆ្នាំ២០០០ — ជាសមាជិកកាកបាទក្រហមស្រុក តួនាទីជាបេឡា
- ឆ្នាំ២០០២ ដល់ ឆ្នាំ២០១៧ — ជាប់ឆ្នោតជាស្ត្រីក្រុមប្រឹក្សាឃុំ

លោកស្រី **ដុំ សោភ័ណ្ឌ** បានជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំអង្គតាសោម និងបានជាប់ឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់នេះចំនួន៤អាណត្តិ (ចាប់ពីអាណត្តិទី១ ដល់ អាណត្តិទី៤)។ លោកស្រីបានបញ្ជាក់ថា ប្រធានក្រុម

ប្រឹក្សាឃុំ សង្កាត់បានប្រគល់តួនាទី ភារកិច្ចជូនលោកស្រីជាសមាជិកដូចមានចែងក្នុងច្បាប់។ ចំណុចខ្លាំងដែលជំរុញឲ្យលោកស្រីបានជាប់ឆ្នោតជាក្រុមប្រឹក្សា ឃុំ សង្កាត់ជាបន្តបន្ទាប់ គឺដោយសារទង្វើ និងភាពសកម្មនៅក្នុងភូមិ ឃុំរបស់លោកស្រី។ ជាងនេះទៀត លោកស្រីជាមនុស្សដែលស្រលាញ់ និងចូលចិត្តក្នុងការងារជួយស្ត្រី ជនក្រីក្រ និងកុមារកំព្រា ទើបប្រជាពលរដ្ឋមើលឃើញថា « ***លោកស្រីជាស្ត្រីដែលមានសមត្ថភាព មានការប្តេជ្ញាចិត្តខ្ពស់ និងមានទឹកចិត្តជួយប្រជាពលរដ្ឋពិតៗ*** »។ ដូច្នេះទើបមានការបោះឆ្នោតគាំទ្រឲ្យលោកស្ត្រីបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាបន្តបន្ទាប់មកដល់ពេលបច្ចុប្បន្ននេះ។ លោកស្រីបានបញ្ជាក់ថា « ***ទាំងបុរសៗជាប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន និងបុរសៗជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់គឺមិនមានការរើសអើងមកលើរូបលោកស្រីទេ*** »។

មុននឹងជាប់ឆ្នោតជាស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ លោកស្រី **ជុំ សោភ័ណ្ឌ** មានតួនាទីជាសមាជិកកាកបាទក្រហមស្រុកដែលចាំជួយប្រជាពលរដ្ឋក្រីក្រ ខ្វះខាត និងជាសមាជិកគណបក្សប្រជាជនកម្ពុជាផងដែរ។ លោកស្រីបានលើកឡើងថា « ***ការតាំងចិត្តរបស់ខ្ញុំនៅតែមានក្នុងការបំពេញការងារ ប៉ុន្តែអ្វីដែលជាទុក្ខលំបាករបស់ខ្ញុំក៏មានច្រើនណាស់ដែរ ដូចជាបញ្ហាទាក់ទងនឹងប្រាក់ឧបត្ថម្ភចំពោះខ្ញុំគឺមានចំនួនតិចតួចពេកដែលធ្វើឲ្យការចំណាយរបស់ខ្ញុំមានការខ្វះខាត ពេលខ្លះខ្ញុំត្រូវយកលុយអ្នកផ្ទះចាយវាយដដែល ខណៈដែលការងារកាន់តែស្មុគស្មាញថែមទៀត*** »។ ទោះបីជាមានបញ្ហាការលំបាកយ៉ាងណាក៏ដោយ ក៏លោកស្រីនៅតែមានឆន្ទៈខ្ពស់ក្នុងការបំពេញការងារជាស្ត្រីក្រុមប្រឹក្សាឃុំដើម្បីចាំជួយស្ត្រី កុមារ និងប្រជាពលរដ្ឋក្រីក្រនៅក្នុងភូមិ ឃុំរបស់លោកស្រីដដែល។ លោកស្រីបានបន្តទៀតថា « ***ដោយសារខ្ញុំបានលះបង់ទាំងពេលវេលា កំលាំងកាយ និងចិត្តខិតខំជួយបម្រើប្រជាពលរដ្ឋនៅក្នុងភូមិ ឃុំខ្លាំងពេក ជាហេតុធ្វើឲ្យខ្ញុំបាត់បង់ពេលវេលាសម្រាប់ជួយខ្លួនឯង និងគ្រួសារ ទើបជួបបញ្ហាសេដ្ឋកិច្ចៗ ដូច្នេះ ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជា តម្លើងប្រាក់បៀវត្សរ៍ដល់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិច ១ ០០០ ០០០ រៀល (មួយលានរៀល)ក្នុងមួយខែនោះ ខ្ញុំនឹងមានជីវភាពប្រសើរ និងងាយស្រួលក្នុងការបន្តដំណើរទៅមុខទៀតក្នុងការជួយស្ត្រី កុមារ និងប្រជាពលរដ្ឋក្រីក្រនៅក្នុងភូមិ ឃុំរបស់ខ្ញុំ*** »។

បច្ចុប្បន្ននេះ លោកស្រីកំពុងមានភាពមមាញឹកណាស់ទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ ដោយសារមានស្ត្រីទើបតែសម្រាលកូនរួចជាច្រើននាក់ និងមានកុមារជាច្រើនដែលកំពុងជួបបញ្ហា។ លោកស្រីក៏មានភាពមមាញឹកផងដែរក្នុងការដោះស្រាយបញ្ហាជំលោះដីធ្លី បញ្ហាអំពើហឹង្សាក្នុងគ្រួសារ ជាដើម។

ដំណើរការដកថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារមកប្រើប្រាស់ក្នុង១ឆ្នាំ មានបីដំណាក់កាល ដោយក្នុងមួយត្រីមាសដកម្តង ដែលមានថវិកាសរុបប្រចាំឆ្នាំចំនួន **៧ ៣៣៤ ៤០០រៀល** ហើយអនុវត្តដោយមានតម្លាភាព ព្រោះរាល់ការចំណាយទាំងអស់សុទ្ធតែមានវិក័យប័ត្រត្រឹមត្រូវ និងមានរបាយការណ៍ច្បាស់លាស់ព្រមទាំងមានការទទួលស្គាល់ដឹងឮពីមេឃុំ និងសមាជិកក្រុមប្រឹក្សាឃុំ ផ្សេងទៀត។ ទោះបីជាយ៉ាងណា លោកស្រីបានបន្ថែមថា « ថវិកាសម្រាប់ការងារស្ត្រី និងកុមារនេះវាមិនគ្រប់គ្រាន់ទេ ពីព្រោះការចុះបំពេញកិច្ចការងារខ្លះត្រូវមានការចំណាយច្រើនលើសពីថវិកាដែលបានផ្តល់ឲ្យ »។ បន្ថែមលើនេះទៀត កញ្ចប់ថវិកានេះត្រូវបានកាន់កាប់ដោយមេឃុំ និងស្មៀន ជាហេតុធ្វើឲ្យដំណើរការនៃការដកថវិកាមកប្រើប្រាស់ក្នុងសកម្មភាពការងារស្ត្រី និងកុមារពុំសូវជាមានភាពងាយស្រួល។ លោកស្រីត្រូវធ្វើលិខិតស្នាមដែលមានភាពស្មុគស្មាញ

ពេកដើម្បីអាចដកថវិកានេះមកប្រើប្រាស់បាន បណ្តាលឲ្យពិបាកក្នុងការអនុវត្តការងារ។ លោកស្រីមានសំណូមពរថា « *ថ្នាក់លើគួរតែប្រគល់ថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារឲ្យអ្នកដែលទទួលបន្ទុកការងារស្ត្រី និងកុមារជាអ្នកកាន់កាប់វិញ នោះវានឹងមានភាពងាយស្រួលជាងមុន* »។

ក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ លោកស្រី **ជុំ សោភ័ណ្ឌា** ធ្លាប់បានបញ្ចេញយោបល់ ឬធ្វើសំណើដោយបានលើកឡើងអំពីបញ្ហាស្ត្រី និងកុមារដើម្បីឲ្យសមាជិកក្រុមប្រឹក្សាឃុំបានដឹងពីបញ្ហានេះ និងបានស្នើទៅមេឃុំឲ្យជួយរកដំណោះស្រាយលើបញ្ហាស្ត្រី និងកុមារ។ លោកស្រីបានសង្កេតឃើញថា រាល់ពេលប្រជុំម្តងៗ ក្នុងពេលបញ្ចេញមតិយោបល់របស់លោកស្រី គឺនៅមានគំនាបដោយសារលោកស្រីមានឋានៈទាបជាងគេ ដែលរាល់ការបញ្ចេញយោបល់ផ្សេងៗនៅមានការភ័យខ្លាចច្រើន។

លោកស្រី **ជុំ សោភ័ណ្ឌា** បានបង្ហាញថា « *ខ្ញុំទទួលបានចំណេះដឹង និងបទពិសោធជាច្រើនពីការប្រឡូកក្នុងវិស័យនយោបាយ និងការធ្វើជាសមាជិកក្រុមប្រឹក្សាឃុំ* »។ លោកស្រីតាំងចិត្តថា នឹងព្យាយាមធ្វើការងារនេះឲ្យបានល្អប្រសើរបំផុតទៅតាមសមត្ថភាពដែលលោកស្រីមាន ដើម្បីជួយសង្គមឲ្យបានរីកចម្រើនព្រមទាំងលើកកម្ពស់ស្ត្រី និងជួយអភិវឌ្ឍន៍ឃុំរបស់លោកស្រីផ្ទាល់ ដើម្បីឲ្យប្រជាពលរដ្ឋទទួលបាលភាពកក់ក្តៅ និងភាពរីកចម្រើន។

សំណូមពររបស់លោកស្រី **ជុំ សោភ័ណ្ឌា** « *សូមរដ្ឋាភិបាលបន្ថែមថវិកាសម្រាប់កិច្ចការស្ត្រី និងកុមារ និងសូមតំឡើងប្រាក់បៀវត្សរ៍ឲ្យស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ យ៉ាងតិច១ ០០០ ០០០ រៀល (មួយលានរៀល) ក្នុងមួយខែ* »។

# V. សេចក្តីសន្និដ្ឋាន និងសង្ខេប

ចំនួនតំណាងរាស្ត្រស្ត្រី និងតំណាងរាស្ត្របុរសដែលបានឡើងបញ្ចេញមតិក្នុងកិច្ចប្រជុំសភាពេញអង្គរដ្ឋសភា សម្រាប់ឆ្នាំទី១ នីតិកាលទី៦នេះនេះ គឺមានកម្រិតទាបបំផុត **៩,៦០% (១២នាក់)** បើធៀបនឹងចំនួនអ្នកតំណាងរាស្ត្រសរុប **១២៥នាក់។** ក្នុងឆ្នាំទី១នៃនីតិកាលទី៦នេះ ***បញ្ហាស្ត្រី និងកុមារ*** មិនត្រូវបានលើកយកមកដាក់ក្នុងរបៀបវារៈនៃកិច្ចប្រជុំទេ ហើយរាល់កិច្ចពិភាក្សាពុំបានឆ្លុះបញ្ចាំងពីផលប្រយោជន៍ និងផលប៉ះពាល់ដល់ស្ត្រី និងកុមារ។

ភាគរយសរុបរបស់អ្នកតំណាងរាស្ត្រស្ត្រីបានចុះបេសកកម្ម **ប្រហាក់ប្រហែលនឹង**ភាគរយសរុបរបស់អ្នកតំណាងរាស្ត្របុរសដែលបានចុះបេសកកម្ម គឺ ៥៣,៨៤% ស្មើនឹងចំនួនតំណាងរាស្ត្រស្ត្រី១៤នាក់ក្នុងចំណោមសមាជិកសភាស្ត្រី២៦នាក់ ច្រើនជាងបន្តិចភាគរយរបស់អ្នកតំណាងរាស្ត្របុរសចំនួន **៥០,៥០%** ស្មើនឹង៥០នាក់ក្នុងចំណោមសមាជិកសភាបុរស៩៩នាក់។

ភាគរយអ្នកតំណាងរាស្ត្រស្ត្រីចុះបេសកកម្ម មានការ**ថយចុះខ្លាំង** ពី **៨៣,៣៣%** នីតិកាលទី៥ ឆ្នាំ២០១៦ មកត្រឹម**៥៣,៨៤%** នីតិកាលទី៦ ឆ្នាំ២០១៩ ខណៈដែលភាគរយអ្នកតំណាងរាស្ត្របុរសចុះបេសកកម្មក៏មានការ**ថយចុះខ្លាំងដែរ** គឺពី **៧៨,៧៩%** នីតិកាលទី៥ ឆ្នាំ២០១៦ មកត្រឹម **៥០,៥០ %** នីតិកាលទី៦ ឆ្នាំ២០១៩។

តំណាងរាស្ត្រស្ត្រីចំនួន១៤នាក់ នៃគណបក្សប្រជាជនកម្ពុជាដែលមានអាសនៈនៅក្នុងរដ្ឋសភាបានធ្វើសកម្មភាពនៅមូលដ្ឋានសរុបចំនួន **២២៩លើក**។ ចំនួនសកម្មភាពនេះ បាន**ថយចុះ**ចំនួន **១១០លើក** ពី **៣៣៩លើក** នីតិកាលទី៥ ឆ្នាំ២០១៦ មកត្រឹម **២២៩លើក** នីតិកាលទី៦ ក្នុងឆ្នាំ២០១៩។

សកម្មភាពនៃការចុះសំណេះសំណាលសួរសុខទុក្ខ ចែកអំណោយ និងសម្ពោធសមិទ្ធិផលនានា និងការចុះពង្រឹងផ្ទៃក្នុង និងបណ្តាញគណបក្សរបស់អ្នកតំណាងរាស្ត្រស្ត្រីនៅតែជាសកម្មភាពអាទិភាព និងសកម្មដដែល ខណៈដែលមិនមានការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋ។

សម្រាប់នីតិកាលទី៦នេះ រាជរដ្ឋាភិបាលតាមរយៈក្រសួងកិច្ចការនារីនឹងបន្តផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍធនធានមនុស្ស ជាពិសេសផ្តោតលើជំនាញភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងវិស័យនយោបាយ វិស័យសង្គម និងវិស័យសេដ្ឋកិច្ចនៅថ្នាក់ប្រទេសក៏ដូចជានៅថ្នាក់តំបន់ រួមទាំងពង្រឹងភាពអង់អាចដល់ស្ត្រីដើម្បីមានភាពជោគជ័យផ្នែកសហគ្រិន។ ក្រសួងកិច្ចការនារីបានបន្តពង្រឹងការអនុវត្តផែនការទប់ស្កាត់រាល់ទម្រង់នៃអំពើហឹង្សាលើស្ត្រី និងក្មេងស្រីឆ្នាំ២០១៩-២០២៣ និងលើកកម្ពស់សីលធម៌សង្គមឡើងវិញ ដោយយកចិត្តទុកដាក់ខ្ពស់ចំពោះការអប់រំសង្គមឲ្យមានការផ្លាស់ប្តូរផ្នត់គំនិត កុំឲ្យមានការរើសអើងចំពោះស្ត្រីភេទ និងផ្នត់គំនិតនៃការទទួលខុសត្រូវខ្ពស់នៃការពិសារគ្រឿងស្រវឹង និងបង្រ្កាបការប្រើប្រាស់គ្រឿងញៀនដែលមានផលប៉ះពាល់អវិជ្ជមានធំទៅលើយុវវ័យ។

ចន្លោះពីដើមឆ្នាំ ដល់ពាក់កណ្តាលឆ្នាំ២០១៩ អ្នកនយោបាយស្ត្រីដែលប្រើប្រាស់សិទ្ធិនយោបាយរបស់ខ្លួន និងសិទ្ធិស្ត្រីដើម្បីចូលរួមក្នុងដំណើរការប្រជាធិបតេយ្យនៅប្រទេសកម្ពុជាត្រូវបានប្រឈមការចោទប្រកាន់តាមផ្លូវតុលាការ ការរើសអើង ការឃាយី ការគំរាមកំហែង និងការរិតត្បិតពីសំណាក់អាជ្ញាធរ សូម្បីតែការជួបប្រជុំគ្នា ការពិភាក្សាគ្នាអំពីរឿងនយោបាយរបស់ស្ត្រីក៏ត្រូវបានរំខាន។

អាកប្បកិរិយារើសអើងចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មានការ**ថយចុះខ្លាំង** ខណៈដែលមានការគាំទ្រ និងលើកកម្ពស់ស្ត្រីខ្លាំងពីបុរសក្រុមប្រឹក្សាឃុំ សង្កាត់ និងមេភូមិ ដោយបុរសទាំងនោះមានការផ្លាស់ប្តូរអាក្សកិរិយាឲ្យតម្លៃស្ត្រី បានយល់ដឹងពីយេនឌ័រ គោរពសិទ្ធិស្ត្រី និងបានសហការល្អជាមួយស្ត្រី។ ទោះបីយ៉ាងណាក៏ដោយ ការរើសអើងចំពោះស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួននៅតែបន្តមាននៅឡើយ។

ការរើសអើងមិនប្រគល់ភារកិច្ចជូនដល់សមាជិកស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ មានការ**ថយចុះ** ពី **៩,៧៥%** ឆ្នាំ២០១៥ (អាណត្តិទី៣) មកត្រឹម **២,៧៧%** ឆ្នាំ២០១៩ (អាណត្តិទី៤) និងមានភាពប្រសើរក្នុងការចូលរួមបញ្ចេញមតិ យោបល់ និងការចូលរួមធ្វើសេចក្តីសម្រេចចិត្តរបស់ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់។

ស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ បាន និងកំពុងធ្វើការយ៉ាងមមាញឹកនាពេលបច្ចុប្បន្នក្នុងតួនាទីរបស់ខ្លួនទាំងស្ត្រីដែលមានតួនាទីជាជំទប់ទី១ ជំទប់ទី២ សមាជិកក្រុមប្រឹក្សាឃុំ និងស្ត្រីមេឃុំ ចៅសង្កាត់ ទាក់ទងនឹងបញ្ហាស្ត្រី និងកុមារ អំពើហិង្សាក្នុងគ្រួសារ ការអប់រំផ្សព្វផ្សាយ ការដោះស្រាយទំនាស់ដីធ្លី និងកិច្ចការផ្សេងៗដើម្បីមានការអភិវឌ្ឍន៍ និងសុវត្ថិភាពនៅឃុំ សង្កាត់របស់ខ្លួន។ល។ និង។ល។

តម្លាភាពថវិកានៅមានកម្រិតសម្រាប់កិច្ចការស្ត្រី និងកុមារនៅឃុំ សង្កាត់មួយចំនួន។ ឃុំ សង្កាត់ភាគច្រើនមានភាពងាយស្រួលក្នុងការដកថវិកាមកប្រើប្រាស់លើកិច្ចការស្ត្រី និងកុមារ ប៉ុន្តែថវិកានៅមានចំនួនតិចមិនសមស្របនឹងបញ្ហាស្ត្រី និងកុមារដែលកើតមាននៅក្នុងភូមិ រីឯឃុំមួយចំនួនតូចមានការពិបាកក្នុងការដកថវិកា។

# VI. អនុសាសន៍

១. តំណាងរាស្ត្រស្ត្រី និងតំណាងរាស្ត្រប្រុសត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការចុះអន្តរាគមន៍ និងដោះស្រាយបញ្ហានានារបស់ម្ចាស់ឆ្នោត។

២. តំណាងរាស្ត្រស្ត្រី និងតំណាងរាស្ត្រប្រុសគួរតែបង្ហាញអំពីលទ្ធផលនៃការចុះបេសកកម្មតាមមូលដ្ឋានរបស់ខ្លួនដល់សាធារណជនទូទៅឲ្យបានដឹង។

៣. រាល់ការពិភាក្សា និងអនុម័តក្នុងកិច្ចប្រជុំពេញអង្គរបស់សភា ត្រូវដាក់បញ្ចូលអំពីការឆ្លើយតបនឹងយេនឌ័រនៅក្នុងច្បាប់ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

៤. រាជរដ្ឋាបាលកម្ពុជាត្រូវគោរពនូវសិទ្ធិនយោបាយរបស់ស្ត្រី និងធានាឲ្យបានក្នុងការអនុវត្តសិទ្ធិនេះ ដោយបង្កលក្ខណៈងាយស្រួលដល់ស្ត្រីធ្វើការជួបជជែកគ្នាអំពីកិច្ចការនយោបាយ និងកិច្ចការផ្សេងៗ ជាពិសេសសម្រាប់អ្នកនយោបាយស្ត្រីដែលមកពីគណបក្សប្រឆាំង និងគណបក្សផ្សេងទៀតប្រយោជន៍គាំទ្រ និងផ្តល់ឱកាសឱ្យស្ត្រីចូលរួមកាន់តែច្រើនក្នុងកិច្ចការនយោបាយ និងថ្នាក់សម្រេចចិត្ត ស្របតាមអនុសញ្ញាស៊ី-ដរ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា ។

៥. រាជរដ្ឋាភិបាលកម្ពុជាត្រូវពិនិត្យមើលឡើងវិញ និងយកចិត្តទុកដាក់បន្ថែមចំពោះអ្នកនយោបាយស្ត្រីនៅក្នុងគណបក្សដែលខ្លួនកំពុងដឹកនាំរដ្ឋាភិបាល ឬក៏អ្នកនយោបាយស្ត្រីផ្សេងៗដែលមានសម្លេង និងសកម្ម ឬស្ត្រីដែលបំរុងនឹងចូលរួមក្នុងវិស័យនយោបាយ ដោយលើកទឹកចិត្ត ការពារ ផ្តល់ឱកាស និងធានាឲ្យបាននូវការចូលរួមដោយពេញលេញក្នុងកិច្ចការនយោបាយរបស់ស្ត្រី ។

៦. ក្រសួងមហាផ្ទៃ រួមទាំងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប) ត្រូវធានាចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ ជាពិសេសស្ត្រីទទួលបាននូវតួនាទី ភារកិច្ច និងសិទ្ធិអំណាចពេញលេញស្របតាមច្បាប់ស្តីពី «ការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់»។

៧. ត្រូវផ្តល់ការគាំទ្រគ្រប់បែបយ៉ាងឲ្យស្ត្រីជាប់ឆ្នោត និងអ្នកដឹកនាំជាស្ត្រី ដូចជា ផ្តល់ថវិកាស្របជាមួយនឹងបញ្ហាដែលស្ត្រីកំពុងធ្វើ ផ្តល់នូវធនធានសម្ភារៈ ធនធានមនុស្ស និងមធ្យោបាយនានា ដើម្បីបង្កលក្ខណៈងាយស្រួល និងបង្កើនប្រសិទ្ធភាពការងាររបស់ស្ត្រី ប្រយោជន៍ស្ត្រីចូលរួមដោយគុណភាពក្នុងតួនាទីជាតំណាង និងជាអ្នកដឹកនាំ ។

ផ្ទះលេខ១៣៨ ផ្លូវលេខ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
P.O.Box: 114, CCC Box: 439, Phnom Penh: (023) 884 150 / 012 942 019 / 012 942 017

Fax: (855-23) 883 750, Phnom Penh, Email: comfrel@online.com.kh

Website: http://www.comfrel.org